**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ព្រឹទ្ធសភា**

**អគ្គលេខាធិការដ្ឋាន**

លេខ ០៥២/០២៤២៥/អ.ពស.គ.ជ.ប

# លិខិតបញ្ជូន

គោរពជូន: - គណៈកម្មការជំនាញទាំង១០ព្រឹទ្ធសភា

- អគ្គាធិការដ្ឋាន
- អគ្គនាយកដ្ឋានទាំង៥

| ល.រ | រាយមុខលិខិត | ចំនួន | សេចក្តីផ្សេងៗ |
|---|---|---|---|
| ០១ | របាយការណ៍ស្តីពីសកម្មភាពការងារប្រចាំខែមីនា ឆ្នាំ២០២៤ របស់ក្រសួងអធិការកិច្ច។ (ច្បាប់ថតចម្លង) | ០១ច្បាប់ | "ដើម្បីជូនជ្រាបជាព័ត៌មាន" |

ថ្ងៃព្រហស្បតិ៍ ២ រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០២៤

**ជ.អគ្គលេខាធិការ**

**អគ្គលេខាធិការរង**

**ខេង សិទ្ធិគុណា**


វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: secretariat@senate.gov.kh

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអធិការកិច្ច**

លេខ: ០១៣ /២៤ អ.ធ.ក. រ.ស.ក

ថ្ងៃព្រហស្បតិ៍ ១១ រោច ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ៤ ខែមេសា ឆ្នាំ ២០២៤

**សូមគោរពជូន**
**ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការគណៈរដ្ឋមន្ត្រី**

**កម្មវត្ថុ៖** របាយការណ៍ ស្តីពីសកម្មភាពការងារប្រចាំខែមីនា ឆ្នាំ២០២៤ របស់ក្រសួងអធិការកិច្ច។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូន **ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ** មេត្តាជ្រាបថា ខ្ញុំបាទសូមគោរពជូននូវរបាយការណ៍ ស្តីពីសកម្មភាពការងារប្រចាំខែមីនា ឆ្នាំ២០២៤ របស់ក្រសួងអធិការកិច្ច ដើម្បីជាធាតុចូលសម្រាប់រៀបចំជារបាយការណ៍សកម្មភាពរួមរបស់រាជរដ្ឋាភិបាល ប្រចាំខែមីនា ឆ្នាំ២០២៤។

សូមគោរពជូនភ្ជាប់នូវឯកសាររបាយការណ៍សកម្មភាពការងាររបស់ក្រសួងអធិការកិច្ច។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ** មេត្តាជ្រាប ជារបាយការណ៍ដ៏ខ្ពង់ខ្ពស់។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ។

**រដ្ឋមន្ត្រីក្រសួងអធិការកិច្ច**

**ហួត ហាក់**

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអធិការកិច្ច**

លេខៈ ០១៥ / ២៤ អ.ធ.ក. ត.ស.ក

# របាយការណ៍
# ស្ដីពី
# សកម្មភាពការងាររបស់ក្រសួងអធិការកិច្ច
# ប្រចាំខែមីនា ឆ្នាំ២០២៤

ក្នុងខែមីនា ឆ្នាំ២០២៤ កន្លងទៅ ក្រសួងអធិការកិច្ចបានអនុវត្តការងារសំខាន់ៗស្របតាមយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ និងកម្មវិធីនយោបាយសំខាន់ៗ របស់រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៧ នៃរដ្ឋសភា ក្រោមការដឹកនាំដ៏ប៉ិនប្រសប់ និងឈ្លាសវៃ ប្រកបដោយចក្ខុវិស័យវែងឆ្ងាយ និងប្រាកដនិយម របស់ សម្ដេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។

ចំពោះវឌ្ឍនភាពការងារសំខាន់ៗរបស់ក្រសួងអធិការកិច្ច ប្រចាំខែមីនា ឆ្នាំ២០២៤ កន្លងទៅរួមមានៈ

## I.សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ

### ១.ការងារថ្នាក់ដឹកនាំក្រសួងក្នុងការចូលរួមកម្មវិធីជាមួយប្រមុខរដ្ឋ និងប្រមុខរាជរដ្ឋាភិបាល

ឯកឧត្តមរដ្ឋមន្ត្រី បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំ វេទិកា និងកម្មវិធីមួយចំនួនក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្ដេចធិបតីនាយករដ្ឋមន្ត្រី** មានជាអាទិ៍ៈ

- កិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាព **សម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី** នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៤
- បិទកិច្ចប្រជុំគណៈកម្មាធិការកណ្ដាលសហភាពសហព័ន្ធយុវជនកម្ពុជា នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៤
- ពិធីអបអរសាទរទិវាវប្បធម៌ជាតិ៣មីនា លើកទី២៦ ឆ្នាំ២០២៤ នៅថ្ងៃទី៧ ខែមីនា ឆ្នាំ២០២៤
- ពិធីបើកវេទិការដ្ឋាភិបាលឌីជីថលលើកទី១ ឆ្នាំ២០២៤ និងពិព័រណ៍បច្ចេកវិទ្យាឌីជីថល នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៤
- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការមន្ទីរពេទ្យ "តេជោសែនកោះធំ" នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤
- ពិធីបុណ្យទន្លេលើកទី៨ ឆ្នាំ២០២៤ ក្រោមប្រធានបទ "ទន្លេដើម្បីសន្តិភាព និងការអភិវឌ្ឍ" នៅខេត្តសៀមរាប នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤
- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៣ និងលើកទិសដៅការងារឆ្នាំ២០២៤ របស់ក្រសួងសុខាភិបាល នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៤
- ពិធីបើកទិវាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍លើកទី២ ក្រោមប្រធានបទ "សហគ្រាសធុនតូច និងមធ្យម ឆ្ពោះទៅវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍" នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៤

ព្រះរាជាណាចក្រកម្ពុជា ក្រសួងអធិការកិច្ច



អគារលេខ១២៦ ផ្លូវលេខ៣ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
Tel / Fax: (855) 23 221 458 (855) 23 220 648
www.inspection.gov.kh

- ពិធីសម្ពោធឆ្លងព្រះបទុមចេតិយ និងសមិទ្ធផលនានា នៅវត្តមណីរតនារាម ស្ថិតនៅសង្កាត់លោប ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៤។

**២.ការងារជាមួយថ្នាក់ដឹកនាំ**

- ពិធីសម្ពោធសមិទ្ធផលនានាក្នុងវត្តវេឡុវៃន (ហៅវត្តទួលរកា) ក្រោមអធិបតីភាព ឯកឧត្តមសន្តិបណ្ឌិត **នេត សាវឿន** ឧបនាយករដ្ឋមន្ត្រី ស្ថិតនៅភូមិទួលរកា ឃុំពាមកោះស្នា ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម កាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៤

- ដឹកនាំគណៈប្រតិភូក្រសួងអធិការកិច្ច គោរពវិញ្ញាណក្ខន្ធសព ឯកឧត្តម **ឃួន ផល្លារិទ្ធ** នាយករងខុទ្ទកាល័យ និងជាប្អូនបង្កើត សម្តេចមហារដ្ឋសភាធិការធិបតី **ឃួន សុដារី** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៤

- ដឹកនាំគណៈប្រតិភូក្រសួងអធិការកិច្ចចូលរួមកិច្ចប្រជុំពិភាក្សាការងារជាមួយគណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង និងអង្កេត និងអធិការកិច្ច នៃរដ្ឋសភា នៅថ្ងៃទី៧ ខែមីនា ឆ្នាំ២០២៤។

**៣.ការងារថ្នាក់ដឹកនាំក្រសួងលើការពង្រឹងសមត្ថភាពស្ថាប័ន**

ឯកឧត្តមរដ្ឋមន្ត្រី បានអញ្ជើញដឹកនាំនៅក្នុងកិច្ចប្រជុំ និងកម្មវិធីមួយចំនួនដូចខាងក្រោម៖

- ដឹកនាំកិច្ចប្រជុំថ្នាក់ដឹកនាំក្រសួងប្រចាំខែកុម្ភៈ និងលើកទិសដៅការងារខែមីនា ត្រួតពិនិត្យវឌ្ឍនភាពការងារក្រសួងអធិការកិច្ច នៅថ្ងៃទី៤ ខែមីនា ឆ្នាំ២០២៤

- ដឹកនាំកិច្ចប្រជុំថ្នាក់ដឹកនាំក្រសួងប្រចាំសប្តាហ៍ ត្រួតពិនិត្យវឌ្ឍនភាពការងារក្រសួងអធិការកិច្ច នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៤ និងនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៤

- ដឹកនាំកិច្ចប្រជុំត្រួតពិនិត្យវឌ្ឍនភាពការងារនាយកដ្ឋានអធិការកិច្ចទី១ នាយកដ្ឋានអធិការកិច្ចទី២ និងនាយកដ្ឋានអធិការកិច្ចទី៣ នៃអគ្គនាយកដ្ឋានអធិការកិច្ច នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៤។

**៤.ការងារថ្នាក់ដឹកនាំក្រសួងលើការកសាង និងអភិវឌ្ឍមូលធនមនុស្ស**

- ឯកឧត្តមរដ្ឋមន្ត្រី បានអញ្ជើញជាអធិបតីក្នុងពិធីសំណេះសំណាលជាមួយនិស្សិតជ័យលាភីអាហារូបករណ៍រដ្ឋាភិបាលអូស្ត្រាលីចំនួន១២រូប នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៤

- ក្រសួងអធិការកិច្ច បានចុះអនុស្សរណៈ នៃការយោគយល់គ្នាជាមួយក្រសួងព័ត៌មានស្តីពីកិច្ចសហប្រតិបត្តិការផ្សព្វផ្សាយព័ត៌មាន និងព្រឹត្តិការណ៍ នៅប្រព័ន្ធផ្សព្វផ្សាយរបស់ក្រសួងព័ត៌មាន នៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៤

- ក្រសួងបានចាត់បញ្ជូនមន្ត្រីរាជការចំនួន២០រូប ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីគោលនយោបាយសាធារណៈ និងអភិបាលកិច្ចសម្រាប់មន្ត្រីរាជការស៊ីវិល នៅសាធារណរដ្ឋឥណ្ឌា

- ក្រសួងបានចាត់បញ្ជូនមន្ត្រីរាជការចំនួន៧រូប ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីជំនាញបច្ចេកទេសកម្រិតវិញ្ញាបនបត្រផ្សារភ្ជាប់មុខតំណែងឆ្នាំ២០២៤ នៅវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- ក្រសួងបានចាត់បញ្ជូនមន្ត្រីរាជការចំនួន៣រូប ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីភាពជាអ្នកដឹកនាំ និងនវានុវត្តន៍តាមប្រព័ន្ធអនឡាញ ។

ព្រះរាជាណាចក្រកម្ពុជា
ក្រសួងអធិការកិច្ច

- គណៈប្រតិភូក្រសួងអធិការកិច្ច ដឹកនាំដោយលោកជំទាវ **សុខ ទិឡាយ** រដ្ឋលេខាធិការប្រចាំការ បានអញ្ជើញទៅទស្សនកិច្ចនៅសាធារណរដ្ឋសង្គមនិយមវៀតណាម ដើម្បីដកស្រង់បទពិសោធការងារ កាលពីថ្ងៃទី១០-១៧ ខែមីនា ឆ្នាំ២០២៤។

**៥.ការងារថ្នាក់ដឹកនាំក្រសួងលើការរៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត**

- ក្រសួងអធិការកិច្ច បានចេញសេចក្តីសម្រេចលេខ០០៤/២៤ អ.ធ.ក. ស.ស.រ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៤ ស្តីពីការបង្កើតក្រុមការងាររៀបចំសេចក្តីព្រាងគោលនយោបាយជាតិអធិការកិច្ច និងស្តង់ដាជាតិអធិការកិច្ច

- ក្រសួងអធិការកិច្ច បានចេញសេចក្តីសម្រេចលេខ០០៥/២៤ អ.ធ.ក. ស.ស.រ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៤ ស្តីពីការបង្កើតគណៈកម្មការទទួលមូលនិធិគន្ធបុប្ផាកម្ពុជា ប្រចាំក្រសួងអធិការកិច្ច

- ក្រសួងអធិការកិច្ច បានចេញសេចក្តីសម្រេចលេខ០០៦/២៤ អ.ធ.ក. ស.ស.រ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលក្រុមការងារទទួលបន្ទុកសរសេររបាយការណ៍ស្តីពីសិទ្ធិមនុស្សជូនអង្គការសហប្រជាជាតិ នៃក្រសួងអធិការកិច្ច

- ក្រសួងអធិការកិច្ច បានចេញសេចក្តីសម្រេចលេខ០០៧/២៤ អ.ធ.ក. ស.ស.រ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៤ ស្តីពីការបង្កើតគណៈកម្មាធិការសុខភាពសិក្សា នៃក្រសួងអធិការកិច្ច។

**៦.ការងារថ្នាក់ដឹកនាំក្រសួងលើការដោះស្រាយបណ្តឹង**

- ដឹកនាំកិច្ចប្រជុំអន្តរក្រសួងស្តីពីលទ្ធផលការចុះអង្កេតស្រាវជ្រាវលើករណីភាពមិនប្រក្រតី នៃគម្រោងអភិវឌ្ឍន៍ទេសចរណ៍ភ្ជាប់នឹងធម្មជាតិខ្នាតតូច របស់លោកស្រី ស៊ឹង សុខអាង ស្ថិតនៅចំណុចជើងភ្នំ១៥០០ ក្នុងភូមិដីក្រហម ឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់ នៅថ្ងៃទី៥ ខែមីនា ឆ្នាំ២០២៤។

**៧.ការងារថ្នាក់ដឹកនាំក្រសួងលើការទំនាក់ទំនងអន្តរជាតិ**

- ទទួលជួបពិភាក្សាការងារជាមួយលោក Wood Haung ប្រធានក្រុមហ៊ុនតំបន់សេដ្ឋកិច្ចពិសេស Hi-park និងសហការី នៅថ្ងៃទី៥ ខែមីនា ឆ្នាំ២០២៤

- ទទួលជួបពិភាក្សាការងារជាមួយលោក Fan Fangnian នាយកប្រតិបត្តិក្រុមហ៊ុនសម្ព័ន្ធNingbo និងជាប្រធានសមាគមNingbo Leather Association នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៤

- ពិធីសំណេះសំណាល និងអាហារសាមគ្គីជាមួយឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត និងអតីតឯកអគ្គរាជទូត នៅតាមបណ្តាប្រទេសនានាក្នុងទ្វីបអឺរ៉ុប នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៤។

**៨.ការងារថ្នាក់ដឹកនាំក្រសួងលើការថែរក្សាបរិយាកាសសុខដុមនីយកម្មនៅក្នុងក្រសួង និងអង្គភាពចំណុះទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ**

- ក្រសួងអធិការកិច្ចបានរៀបចំពិធីសម្ពោធសាលប្រជុំសម្តេចកិត្តិសង្គហបណ្ឌិតម៉ែន សំអន និងរៀបចំពិធីអបអរសាទរទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០២៤ ខួបលើកទី១១៣ ក្រោមប្រធានបទ "ស្ត្រី និងក្មេងស្រីក្នុងបរិវត្តកម្មឌីជីថល" ក្រោមអធិបតីភាពសម្តេចកិត្តិសង្គហបណ្ឌិតម៉ែន សំអន ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៅថ្ងៃទី៦ ខែមីនា ឆ្នាំ២០២៤។

- ឯកឧត្តមរដ្ឋមន្ត្រី បានអញ្ជើញជាអធិបតីក្នុងពិធីផ្សព្វផ្សាយការអនុវត្តរបបសន្តិសុខសង្គម ផ្នែកថែទាំសុខភាព តាមរបបភាគទានដោយស្ម័គ្រចិត្ត សម្រាប់អ្នកនៅក្នុងបន្ទុកសមាជិក ប.ស.ស ជាមន្ត្រីសាធារណៈ ជូនថ្នាក់ដឹកនាំ និងមន្ត្រីក្រោមឱវាទក្រសួងអធិការកិច្ច នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៤

- ឯកឧត្តមរដ្ឋមន្ត្រី បានអញ្ជើញជាអធិបតីក្នុងពិធីសំណេះសំណាលជាមួយសិក្ខាកាមក្រសួងអធិការកិច្ចចំនួន ២០រូប ដែលត្រូវចូលរួមវគ្គបណ្តុះបណ្តាលស្តីពីគោលនយោបាយសាធារណៈ និងអភិបាលកិច្ចសម្រាប់មន្ត្រីរាជការស៊ីវិល នៅសាធារណរដ្ឋឥណ្ឌា នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៤

- ឯកឧត្តមរដ្ឋមន្ត្រី បានអញ្ជើញជាអធិបតីក្នុងពិធីបើកសិក្ខាសាលាស្តីពី ការផ្សព្វផ្សាយកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៤ និងបទពិសោធការរៀបចំថវិកាព័ត៌មានសមិទ្ធកម្ម នៃការអនុវត្តកិច្ចព្រមព្រៀងសមិទ្ធកម្មរបស់ក្រសួងអធិការកិច្ច នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៤

- ឯកឧត្តមរដ្ឋមន្ត្រី បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០២៣ និងលើកទិសដៅការងារឆ្នាំ២០២៤ របស់សហភាពសហព័ន្ធយុវជនកម្ពុជាវិស័យអធិការកិច្ច នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៤

- ឯកឧត្តមរដ្ឋមន្ត្រី បានដឹកនាំគណៈប្រតិភូក្រសួងអធិការកិច្ចចុះសួរសុខទុក្ខ ឯកឧត្តម វ៉ាន់ ផាន ទីប្រឹក្សាក្រសួងអធិការកិច្ច ដែលមានបញ្ហាសុខភាព កំពុងសម្រាកព្យាបាល នៅមន្ទីរពេទ្យកាល់ម៉ែត នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៤។

## II.**សកម្មភាពការងារ**

### ១.**សកម្មភាពការងាររដ្ឋបាលកិច្ចការទូទៅ**

១.១.ការងាររដ្ឋបាល

- បានទទួលលិខិតចូលពីក្រសួង ស្ថាប័ននានាចំនួន២៤៧ច្បាប់ និងបញ្ជូនលិខិតចេញចំនួន៦៧ច្បាប់ និងថតចម្លងតម្កល់ទុកជាឯកសារ

- បានរៀបចំប្រជុំតាមកម្មវិធីប្រជុំចំនួន២២លើក នៅទីស្តីការក្រសួង

- បានចូលរួមពិធីសម្ពោធសាលប្រជុំសម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន និងពិធីអបអរសាទរទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០២៤ ខួបលើកទី១១៣ ក្រោមប្រធានបទ "ស្ត្រី និងក្មេងស្រីក្នុងបរិវត្តកម្មឌីជីថល" នៅទីស្តីការក្រសួង

- បានចូលរួមពិធីផ្សព្វផ្សាយការអនុវត្តរបបសន្តិសុខសង្គម ផ្នែកថែទាំសុខភាព តាមរបបភាគទានដោយស្ម័គ្រចិត្ត សម្រាប់អ្នកនៅក្នុងបន្ទុកសមាជិកប.ស.ស ជាមន្ត្រីសាធារណៈ ជូនថ្នាក់ដឹកនាំ និងមន្ត្រីក្រោមឱវាទក្រសួងអធិការកិច្ច នៅទីស្តីការក្រសួង

- បានចូលរួមសិក្ខាសាលាស្តីពី ការផ្សព្វផ្សាយកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤ និងបទពិសោធការរៀបចំថវិកាព័ត៌មានសមិទ្ធកម្ម នៃការអនុវត្តកិច្ចព្រមព្រៀងសមិទ្ធកម្មរបស់ក្រសួងអធិការកិច្ច នៅសណ្ឋាគារSUN & MOON

- បានគ្រប់គ្រងសរសេរខ្លឹមសារ និងថតសកម្មភាពការងារថ្នាក់ដឹកនាំ និងមន្ត្រីរាជការបញ្ចូលក្នុងគេហទំព័រផ្លូវការរបស់ក្រសួង

- បានត្រួតពិនិត្យ និងថែទាំម៉ាស៊ីនមេ (Server) និងស្រាវជ្រាវឯកសារពាក់ព័ន្ធនឹងបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍

- បានតាមដានរាល់សកម្មភាពព័ត៌មានដែលចេញតាមវេបសាយក្រសួង និងតាមប្រព័ន្ធFacebook page

- ផេកក្រសួង (Facebook page) មានអ្នក Followerpage ចំនួន៤៨k ចុចLikepage ចំនួន៤៥k និងShare page ចំនួន៣k

- បានរៀបចំកិច្ចប្រជុំនាយកដ្ឋានរដ្ឋបាល និងគណៈប្រតិភូនាយកដ្ឋានសវនកម្មដើម្បីតាមដានវឌ្ឍនភាពការងារ ចំណុចខ្វះខាត និងបញ្ហាប្រឈម លើការប្រើប្រាស់សម្ភារបរិក្ខារផ្សេងៗ រួមទាំងសម្ភារបរិក្ខារបច្ចេកវិទ្យា និងសម្ភារបរិក្ខារមិនមែនបច្ចេកវិទ្យារបស់នាយកដ្ឋានរដ្ឋបាល ចំនួន១លើក នៅទីស្តីការក្រសួង

- បានចូលរួមកិច្ចប្រជុំស្តីពីការត្រួតពិនិត្យវឌ្ឍនភាពការងាររបស់ក្រសួងអធិការកិច្ចចំនួន៣លើក នៅទីស្តីការក្រសួង។

១.២.ការងារបុគ្គលិក និងធនធានមនុស្ស

ក.ការងារបុគ្គលិក

- ក្រសួងអធិការកិច្ចមានមន្ត្រីរាជការចំនួន៤៥៥រូប គឺក្របខ័ណ្ឌក១ ចំនួន១២១រូប ក្របខ័ណ្ឌក២ ចំនួន១៧៧រូប ក្របខ័ណ្ឌក៣ ចំនួន១២៩រូប ក្របខ័ណ្ឌខ១ ចំនួន៧រូប ក្របខ័ណ្ឌខ២ ចំនួន៧រូប ក្របខ័ណ្ឌខ៣ ចំនួន៥រូប ក្របខ័ណ្ឌគ ចំនួន៩រូប និងមន្ត្រីជាប់កិច្ចសន្យាចំនួន១៣៩រូប

- បានធ្វើរបាយការណ៍ស្តីពីបច្ចុប្បន្នភាពរបស់ថ្នាក់ដឹកនាំ មន្ត្រីរាជការ ដែលបើកប្រាក់បៀវត្សតាមប្រព័ន្ធធនាគារ

- បានធ្វើលិខិតស្តីពីការចាត់មន្ត្រីរាជការចំនួន១រូប ថ្នាក់រដ្ឋលេខាធិការ ចូលរួមជាសមាជិក នៃគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់

- បានធ្វើលិខិតស្តីពីការចាត់មន្ត្រីរាជការចំនួន២រូប ថ្នាក់រដ្ឋលេខាធិការ និងថ្នាក់អគ្គនាយក ចូលរួមជាសមាជិកគណៈកម្មការចំពោះកិច្ចចុះបញ្ជីដីតំបន់ទន្លេសាប និងមន្ត្រីជំនាញថ្នាក់អគ្គនាយកដ្ឋាន

- បានធ្វើលិខិតស្តីពីការចាត់មន្ត្រីរាជការចំនួន១រូប ថ្នាក់អនុរដ្ឋលេខាធិការ ដែលទទួលបន្ទុកការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ចូលរួមជាសមាជិកក្នុងក្រុមការងារអន្តរក្រសួង របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

- បានធ្វើលិខិតស្តីពីការសុំដំឡើងឋានន្តរស័ក្តិ និងថ្នាក់ជូនមន្ត្រីរាជការចំនួន៥៦១រូប ប្រចាំឆ្នាំ២០២៤ របស់ក្រសួងអធិការកិច្ច

- បានធ្វើលិខិតស្តីពីការចាត់មន្ត្រីរាជការចំនួន៥រូប ថ្នាក់អគ្គនាយករង ប្រធាននាយកដ្ឋាន នាយករងវិទ្យាស្ថាន និងមន្ត្រីខុទ្ទកាល័យ ចូលរួមសិក្ខាសាលាស្តីពីបញ្ហាប្រឈម នៃការវាយតម្លៃគោលនយោបាយ និងការចូលរួមរបស់រាជរដ្ឋាភិបាលជប៉ុនឆ្ពោះទៅកាន់អភិបាលកិច្ចល្អនៅកម្ពុជា នៅសណ្ឋាគារភ្នំពេញ

- បានធ្វើលិខិតស្តីពីសំណើសុំពិនិត្យ និងផ្តល់នីត្យានុកូលភាពសម្រាប់ការតែងតាំងជំនួយការរដ្ឋលេខាធិការនៃក្រសួងអធិការកិច្ចចំនួន១៨រូប

- បានធ្វើលិខិតស្តីពីការចាត់មន្ត្រីរាជការចំនួន៥៦រូប ចូលរួមវេទិការដ្ឋាភិបាលឌីជីថលឆ្នាំ២០២៤ និងពិព័រណ៍រដ្ឋាភិបាលឌីជីថល និងបច្ចេកវិទ្យាឌីជីថលកម្ពុជា-អន្តរជាតិ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ

- បានធ្វើលិខិតស្តីពីការអនុញ្ញាតច្បាប់ជូនមន្ត្រីរាជការចំនួន២រូប ថ្នាក់ប្រធានមន្ទីរទំនាក់ទំនងរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចរាជធានីភ្នំពេញ និងថ្នាក់អនុប្រធានការិយាល័យ ឈប់សម្រាកពីការងារដើម្បីការពារស្នា និងទំនាក់ទំនងសាលារៀនឱ្យកូនទៅសិក្សានៅប្រទេសអូស្ត្រាលី

- បានធ្វើ និងបញ្ជូនលិខិតស្តីពីសំណើសុំពិនិត្យ និងផ្តល់ទិដ្ឋាការលើសំណុំឯកសារផ្លាស់ប្តូរស្ថានភាពរដ្ឋបាល និងស្ថានភាពគ្រួសាររបស់មន្ត្រីរាជការស៊ីវិល នៃក្រសួងអធិការកិច្ច សម្រាប់ខែមីនា ឆ្នាំ២០២៤ ជូនទៅក្រសួងមុខងារសាធារណៈ

- បានធ្វើ និងបញ្ជូនលិខិតស្តីពីការបើកប្រាក់បៀវត្សជូនថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា សម្រាប់ខែមីនា ឆ្នាំ២០២៤ ជូនទៅធនាគារអេស៊ីលីដា។

ខ.ការងារបណ្តុះបណ្តាល

- បានចាត់បញ្ជូនមន្ត្រីរាជការចំនួន២០រូប ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីគោលនយោបាយសាធារណៈ និងអភិបាលកិច្ចសម្រាប់មន្ត្រីរាជការស៊ីវិល នៅសាធារណរដ្ឋឥណ្ឌា

- បានចាត់បញ្ជូនមន្ត្រីរាជការចំនួន៧រូប ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីជំនាញបច្ចេកទេសកម្រិតវិញ្ញាបនបត្រផ្សារភ្ជាប់មុខតំណែងឆ្នាំ២០២៤ នៅវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានចាត់បញ្ជូនមន្ត្រីរាជការចំនួន៣រូប ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីភាពជាអ្នកដឹកនាំ និងនវានុវត្តន៍ តាមប្រព័ន្ធអនឡាញ។

១.៣.ការងារហិរញ្ញវត្ថុ និងផ្គត់ផ្គង់

- បានទំនាក់ទំនងការងារជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រតនាគារជាតិ និងធនាគារជាតិ ក្នុងកិច្ចការស្នើសុំថវិកានានាតាមខ្ទង់ ជំពូក ដើម្បីបម្រើការងារក្រសួងឱ្យដំណើរការល្អប្រសើរ ដូចជាថវិកាសម្រាប់បៀវត្ស ដំណើរការរដ្ឋបាលទូទៅ បេសកកម្មក្នុងប្រទេស និងក្រៅប្រទេស។ល។

១.៤.ការងារផែនការ និងស្ថិតិ

- បានរៀបចំកែសម្រួលឡើងវិញ និងសម្រេចបន្ថែមធាតុចូលថ្មីៗមួយចំនួនលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ) ឆ្នាំ២០២៤-២០២៨ របស់ក្រសួងអធិការកិច្ច ដើម្បីផ្ញើជូនក្រសួងផែនការ

- បានរៀបចំការងារពិភាក្សាសម្រេចលើសូចនាករសមិទ្ធកម្ម និងគោលដៅសូចនាករលើគម្រោងថវិកាកម្មវិធីឆ្នាំ២០២៤

- បានរៀបចំធាតុចូលសម្រាប់រៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រកម្ពុជាឆ្នាំ២០២៤-២០៣០ ដើម្បីអនុវត្តកម្មវិធីសកម្មភាពនៃសន្និសីទអន្តរជាតិស្តីពីប្រជាជន និងអភិវឌ្ឍន៍

- បានរៀបចំបូកសរុប និងពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យស្ថិតិផ្លូវការ ដែលមានការចាត់តាំងតាមវិស័យ ទទួលបានពីថ្នាក់កណ្តាល នឹងថ្នាក់មន្ទីររាជធានី ខេត្ត ដើម្បីសរុបជារបាយការណ៍សមិទ្ធិផលរបស់ក្រសួង និងត្រៀមផ្ញើជូនក្រសួងផែនការ និងទីស្តីការគណៈរដ្ឋមន្ត្រី

- បានរៀបចំបូកសរុបគម្រោងរបាយការណ៍ស្តីពីលទ្ធផលការអនុវត្តថវិកាកម្មវិធីប្រចាំឆ្នាំ២០២៣ របស់អគ្គនាយកដ្ឋានទាំងបី និងមន្ទីររាជធានី ខេត្តទាំង២៥ នៃក្រសួងអធិការកិច្ច

- បានរៀបចំផែនការតាមដានសមិទ្ធកម្មប្រចាំឆ្នាំ២០២៤ របស់អគ្គនាយកដ្ឋានទាំងបី និងមន្ទីររាជធានី ខេត្ត នៃក្រសួងអធិការកិច្ច

- បានរៀបចំមេរៀនវគ្គបណ្តុះបណ្តាលស្តីពី ការតាមដាន ត្រួតពិនិត្យតាមដាន វាយតម្លៃក្នុង...

- បានរៀបចំបញ្ជីសមាសភាពមន្ត្រីរាជការក្នុងនាយកដ្ឋានផែនការ និងស្ថិតិ ចូលរួមវគ្គបណ្ដុះបណ្ដាលស្ដីពីការតាក់តែងលិខិតរដ្ឋបាល និងលិខិតគតិយុត្ត នៅសាលាភូមិន្ទរដ្ឋបាល

- បានចូលរួមកិច្ចប្រជុំពិនិត្យ និងពិភាក្សាសម្រេចលើសូចនាករ និងគោលដៅសូចនាករ ផែនការសមិទ្ធកម្ម និងរបាយការណ៍សង្ខេបស្ដីពីអាទិភាពសំខាន់ៗ នៃការវិភាគថវិកាថ្នាក់ជាតិ របស់ក្រសួងអធិការកិច្ចឆ្នាំ២០២៤ នៅទីស្ដីការក្រសួងចំនួន១លើក

- បានចូលរួមកិច្ចប្រជុំអន្តរក្រសួងស្ដីពីការពិនិត្យ និងពិភាក្សាលើសេចក្ដីព្រាងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល២០២៥-២០២៧ នៅទីស្ដីការគណៈរដ្ឋមន្ត្រីចំនួន១លើក។

១.៥.ការងារសហប្រតិបត្តិការអន្តរជាតិ

- បានបកប្រែលិខិតផ្សេងៗចំនួន៤ច្បាប់ មាន៨ទំព័រ

- បានរៀបចំសេចក្ដីព្រាងខ្លឹមសារអនុស្សរណៈ រវាងក្រសួងអធិការកិច្ច ជាមួយគណៈកម្មាធិការជាតិត្រួតពិនិត្យចិន

- បានរៀបចំលិខិតស្ដីពីរបាយការណ៍វឌ្ឍនភាពទ្វេភាគី រវាងកម្ពុជា-ព្រុយណេ កម្ពុជា-វៀតណាម និងកម្ពុជា-នូវែលសេឡង់ ជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

- បានរៀបចំសម្របសម្រួលការងារផ្សេងៗ ជូនគណៈប្រតិភូក្រសួងអធិការកិច្ច ដឹកនាំដោយលោកជំទាវ សុខ វិឡាយ រដ្ឋលេខាធិការប្រចាំការ អញ្ជើញទៅបំពេញទស្សនកិច្ចការងារ នៅសាធារណរដ្ឋសង្គមនិយមវៀតណាម ចាប់ពីថ្ងៃទី១០-១៧ ខែមីនា ឆ្នាំ២០២៤

- បានរៀបចំសម្របសម្រួលការងារផ្សេងៗ ជូនសិក្ខាកាមក្រសួងអធិការកិច្ចចំនួន២០រូប ចូលរួមវគ្គបណ្ដុះបណ្ដាលស្ដីពីគោលនយោបាយសាធារណៈ និងអភិបាលកិច្ចសម្រាប់មន្ត្រីរាជការស៊ីវិល នៅសាធារណរដ្ឋឥណ្ឌា ចាប់ពីថ្ងៃទី២៦ ខែមីនា ដល់ថ្ងៃទី៦ ខែមេសា ឆ្នាំ២០២៤

- បានចូលរួមកិច្ចជំនួបពិភាក្សាការងារ រវាងក្រសួងអធិការកិច្ច និងអង្គការមូលនិធិអាស៊ីប្រចាំកម្ពុជា នៅទីស្ដីការក្រសួង។

**២.សកម្មភាពការងារទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា**

២.១.ការងារនីតិកម្ម

- បានរៀបចំកិច្ចប្រជុំពិនិត្យ និងពិភាក្សាលើសេចក្ដីព្រាងប្រកាសស្ដីពីតួនាទីភារកិច្ច របស់ការិយាល័យទាំង៤ នៃនាយកដ្ឋាននីតិកម្ម នៅទីស្ដីការក្រសួងចំនួន៣លើក

- បានរៀបចំកិច្ចប្រជុំពិនិត្យ និងពិភាក្សាលើវឌ្ឍនភាពការងារស្ដីពីការកែសម្រួលកម្រងសំណួរស្ទង់មតិច្បាប់ភូមិបាលថ្មីសម្រាប់ឆ្នាំ២០២៤ នៅទីស្ដីការក្រសួងចំនួន៣លើក

- បានចូលរួមវគ្គបណ្ដុះបណ្ដាលគោលការណ៍ណែនាំស្ដីពីការតាមដាន និងវាយតម្លៃថវិកាសមិទ្ធកម្ម នៅសណ្ឋាគារសុខាភ្នំពេញចំនួន១លើក

- បានចាត់បញ្ជូនមន្ត្រីរាជការចំនួន៦រូបចូលរួមវគ្គបណ្ដុះបណ្ដាលស្ដីពីការតាក់តែងលិខិតរដ្ឋបាល និងលិខិតបទដ្ឋានគតិយុត្ត នៅសាលាភូមិន្ទរដ្ឋបាលចំនួន១លើក

- បានបញ្ចូលឯកសារច្បាប់ចំនួន៤ច្បាប់ទៅក្នុងបណ្ណាល័យអេឡិចត្រូនិក គឺ (១) អនុក្រឹត្យ ស្ដីពីការរៀបចំ

និងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល (២)អនុក្រឹត្យស្តីពីគុណវុឌ្ឍិវិជ្ជាជីវៈជំនាញហិរញ្ញវត្ថុសាធារណៈ (៣)អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការសន្តិសុខឌីជីថល (៤)ប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណជាអភិបាលបណ្តោះអាសន្នក្នុងសំណុំរឿងក្ស័យធន

- បានចុះស្ទង់មតិប្រជាពលរដ្ឋស្តីពីការយល់ដឹងលើច្បាប់ចំនួន៩លើក (អគ្គនាយកដ្ឋានទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភាចំនួន២លើក និងមន្ទីររាជធានី ខេត្តចំនួន៧លើក) រួមមាន៖ (១)ច្បាប់ភូមិបាលចំនួន២លើក នៅស្រុកស្វាយទាបចំនួន១លើក និងស្រុករមាសហែកចំនួន១លើក ក្នុងខេត្តស្វាយរៀង (២)ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនចំនួន៥លើក នៅស្រុកបន្ទាយមាសចំនួន៤លើក ក្នុងខេត្តកំពត និងស្រុកចំការលើចំនួន១លើក ក្នុងខេត្តកំពង់ចាម (៣)ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកចំនួន១លើក នៅស្រុកព្រៃឈរចំនួន១លើក ក្នុងខេត្តកំពង់ចាម (៤) ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក និងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនចំនួន១លើក នៅស្រុកពញាឮចំនួន១លើក ក្នុងខេត្តកណ្តាល ដោយមានអ្នកចូលរួមចំនួន៦៩៤នាក់ (ស្ត្រីចំនួន៣៧០នាក់)។

### ២.២.ការងារអប់រំផ្សព្វផ្សាយច្បាប់

- បានចុះផ្សព្វផ្សាយច្បាប់ចំនួន២១លើក (អគ្គនាយកដ្ឋានទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភាចំនួន២លើក និងមន្ទីររាជធានី ខេត្តចំនួន១៩លើក) រួមមាន៖ (១)ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកចំនួន១០លើក នៅស្រុកភ្នំស្រួចចំនួន១លើក និងស្រុកថ្ពងចំនួន១លើក ក្នុងខេត្តកំពង់ស្ពឺ ស្រុកព្រៃឈរចំនួន១លើក និងស្រុកជើងព្រៃចំនួន១លើក ក្នុងខេត្តកំពង់ចាម ស្រុកស្វាយជ្រំចំនួន១លើក ក្នុងខេត្តស្វាយរៀង ស្រុកស្វាយចេកចំនួន១លើក ក្នុងខេត្តបន្ទាយមានជ័យ ស្រុកបរកែវចំនួន១លើក ក្នុងខេត្តរតនគិរី ស្រុកបារាយណ៍ចំនួន១លើក ក្នុងខេត្តកំពង់ធំ ស្រុកឆ្លូងចំនួន១លើក ក្នុងខេត្តក្រចេះ និងខណ្ឌឫស្សីកែវចំនួន១លើក ក្នុងរាជធានីភ្នំពេញ (២)ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនចំនួន៨លើក នៅស្រុកស្រីសន្ធរចំនួន២លើក ស្រុកកងមាសចំនួន១លើក និងស្រុកចំការលើចំនួន១លើក ក្នុងខេត្តកំពង់ចាម ស្រុកត្បូងឃ្មុំចំនួន១លើក ក្នុងខេត្តត្បូងឃ្មុំ ស្រុកទ្រាំងចំនួន១លើក ក្នុងខេត្តតាកែវ ស្រុកអន្លង់វែងចំនួន១លើក ក្នុងខេត្តឧត្តរមានជ័យ និងស្រុកឱរ៉ាល់ចំនួន១លើក ក្នុងខេត្តកំពង់ស្ពឺ (៣)ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះចំនួន១លើក នៅស្រុកឆ្លូងចំនួន១លើក ក្នុងខេត្តក្រចេះ (៤)ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកចំនួន១លើក នៅក្រុងព្រះវិហារចំនួន១លើក ក្នុងខេត្តព្រះវិហារ (៥) ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងក្រមព្រហ្មទណ្ឌចំនួន១លើក នៅក្រុងព្រៃវែងចំនួន១លើក ក្នុងខេត្តព្រៃវែង ដោយមានអ្នកចូលរួមចំនួន៥,៨៤៦នាក់ (ស្ត្រីចំនួន២,៧៣៤នាក់) និងបានទទួលសំណួរចំនួន៦៣៦សំណួរ

- បានចុះវិភាគស្ថានភាព និងវាយតម្លៃអំពីការយល់ដឹងរបស់ប្រជាពលរដ្ឋមុនពេលចុះផ្សព្វផ្សាយច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក នៅឃុំអមលាំង និងឃុំមនោរម្យ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ដោយមានអ្នកចូលរួមចំនួន១១៩នាក់ (ស្ត្រីចំនួន២៣នាក់)

- បានតាមដានផេកហ្វេកបុកនាយកដ្ឋានអប់រំ ផ្សព្វផ្សាយច្បាប់ ដោយទទួលបានអ្នកFollow page ចំនួន[illegible]នាក់

- បានតាមដានពីវឌ្ឍនភាព នៃការផ្សព្វផ្សាយច្បាប់តាមរយៈវីដេអូឃ្លីបចំនួន២១វីដេអូឃ្លីប លើបណ្តាញសង្គម ដែលមានផេកហ្វេកបុក (Facebook Page) ចំនួន៦ គឺ (១)ផេកហ្វេកបុកក្រសួងអធិការកិច្ច **Ministry of Inspection**

(២)ផេកហ្វេកបុកអគ្គនាយកដ្ឋានទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា (៣)ផេកហ្វេកបុកនាយកដ្ឋានអប់រំផ្សព្វផ្សាយច្បាប់ (៤)ផេកហ្វេកបុកបណ្ណាល័យច្បាប់ cll-monasri (៥)ផេកហ្វេកបុក Apsara TV11 (៦)ផេកហ្វេកបុកទូរទស្សន៍ជាតិកម្ពុជា ទទក-TVK ដោយមានអ្នកចូលទស្សនាចំនួន២១៥នាក់

- បានផ្សព្វផ្សាយច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន(អំពីទោសទណ្ឌនៃការប្រើប្រាស់ និងជួញដូរគ្រឿងញៀន) ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក លក្ខណៈសម្បត្តិភូមិ-ឃុំមានសុវត្ថិភាព និងលិខិតបទដ្ឋានគតិយុត្តនានា តាមរយៈវិទ្យុជាតិ FM 92. 5ភ្នំប្រុសភ្នំស្រី និងផេកមន្ទីរព័ត៌មានខេត្តកំពង់ចាមចំនួន៩០លើក។

២.៣.ការងារទំនាក់ទំនងជាមួយរាជរដ្ឋាភិបាល និងរដ្ឋសភា ព្រឹទ្ធសភា

- បានចូលរួមប្រជុំអន្តរក្រសួងនៅទីស្តីការគណៈរដ្ឋមន្ត្រីលើសេចក្តីព្រាងគោលការណ៍ណែនាំស្តីពីនីតិវិធី និងវិធាននៃការតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតចំនួន២លើក

- បានចូលរួមស្តាប់សម័យប្រជុំវិសាមញ្ញរបស់រដ្ឋសភាលើ (១)សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារសម្រាប់ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងម៉ារ៉ាកេសស្តីពីការបង្កើតអង្គការពាណិជ្ជកម្មពិភពលោក ដើម្បីបញ្ចូលកិច្ចព្រមព្រៀងស្តីពីការឧបត្ថម្ភធនជលផលចំនួន១លើក (២)សេចក្តីព្រាងច្បាប់ស្តីពីការដឹកជញ្ជូនតាមផ្លូវទឹកចំនួន១លើក (៣)ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី៥ ចំនួន២រូប ចំនួន១លើក

- បានចូលរួមស្តាប់សម័យប្រជុំវិសាមញ្ញរបស់ព្រឹទ្ធសភាលើ (១)សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារសម្រាប់ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងម៉ារ៉ាកេសស្តីពីការបង្កើតអង្គការពាណិជ្ជកម្មពិភពលោកដើម្បីបញ្ចូលកិច្ចព្រមព្រៀងស្តីពីការឧបត្ថម្ភធនជលផលចំនួន១លើក (២)សេចក្តីព្រាងច្បាប់ស្តីពីការដឹកជញ្ជូនតាមផ្លូវទឹកចំនួន១លើក

- ត្រៀមរៀបចំធ្វើវេទិកាសាធារណៈ ដើម្បីទទួលសំណូមពរពីប្រជាពលរដ្ឋ នៅខេត្តបាត់ដំបង ស្រុកកំរៀង (ឃុំអូរដា និងឃុំបឹងរាំង) នៅថ្ងៃទី២៦-២៧ ខែមីនា ឆ្នាំ២០២៤

- បានធ្វើសំណើចាត់បញ្ជូនមន្ត្រីចំនួន៦រូប ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការតាក់តែងលិខិតរដ្ឋបាល និងលិខិតបទដ្ឋានគតិយុត្ត នៅសាលាភូមិន្ទរដ្ឋបាល

- បានធ្វើសំណើចាត់បញ្ជូនមន្ត្រីចំនួន៦រូប ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីនីតិវិធី នៃការធ្វើបទបង្ហាញនៅទីសាធារណៈ និងការកែប្រែខ្លួនជាអ្នកដឹកនាំ។

## ៣.សកម្មភាពការងារអធិការកិច្ច

### ៣.១.ការងារអធិការកិច្ចទី១ លើវិស័យសេដ្ឋកិច្ច

- បានបញ្ចប់ការចុះធ្វើអធិការកិច្ចលើ (១)ការអនុវត្តតួនាទីភារកិច្ច (២)ការគ្រប់គ្រងការផ្តល់សេវាសាធារណៈ (៣)ការអនុវត្តគម្រោងសាងសង់ ជួសជុល ថែទាំហេដ្ឋារចនាសម្ព័ន្ធ ក្នុងការិយបរិច្ឆេទ២០២២ និងបណ្តាឆ្នាំពាក់ព័ន្ធនៅខេត្តរតនគិរី ស្ទឹងត្រែង ឧត្តរមានជ័យ និងខេត្តព្រះសីហនុ

- ត្រៀមឆ្លងរបាយការណ៍ជាមួយថ្នាក់ដឹកនាំក្រសួងអធិការកិច្ចស្តីពីលទ្ធផលការចុះធ្វើអធិការកិច្ចលើ (១)ការអនុវត្តតួនាទីភារកិច្ច (២)ការគ្រប់គ្រងការផ្តល់សេវាសាធារណៈ ក្នុងការិយបរិច្ឆេទ២០២២ និងបណ្តាឆ្នាំពាក់ព័ន្ធនៅរាជធានីភ្នំពេញ ខេត្តបន្ទាយមានជ័យ បាត់ដំបង តាកែវ និងខេត្តស្ទឹងត្រែង

- កំពុងដាក់ឆ្លងរបាយការណ៍ជាមួយរដ្ឋបាលខេត្តរតនគិរី ស្ទឹងត្រែង ឧត្តរមានជ័យ និងខេត្តព្រះសីហនុស្តីពី

លទ្ធផលការចុះធ្វើអធិការកិច្ចលើ (១)ការអនុវត្តតួនាទីភារកិច្ច (២)ការគ្រប់គ្រងការផ្តល់សេវាសាធារណៈ (៣)ការអនុវត្តគម្រោងសាងសង់ ជួសជុល ថែទាំហេដ្ឋារចនាសម្ព័ន្ធ ក្នុងការិយបរិច្ឆេទ២០២២ និងបណ្តាឆ្នាំពាក់ព័ន្ធ។

**៣.២.ការងារអធិការកិច្ចទី២ លើវិស័យរដ្ឋបាល**

- បានបញ្ចប់ការចុះធ្វើអធិការកិច្ចលើ (១)ការអនុវត្តតួនាទីភារកិច្ច (២)ការគ្រប់គ្រងការផ្តល់សេវាសាធារណៈ (៣)ការអនុវត្តគម្រោងសាងសង់ ជួសជុល ថែទាំហេដ្ឋារចនាសម្ព័ន្ធ ក្នុងការិយបរិច្ឆេទ២០២២ និងបណ្តាឆ្នាំពាក់ព័ន្ធ នៅខេត្តកណ្តាល ត្បូងឃ្មុំ និងខេត្តកំពង់ស្ពឺ
- កំពុងដាក់ឆ្លងរបាយការណ៍ជាមួយរដ្ឋបាលខេត្តកណ្តាល កំពង់ស្ពឺ និងខេត្តត្បូងឃ្មុំស្តីពីលទ្ធផលការចុះធ្វើអធិការកិច្ចលើ (១)ការអនុវត្តតួនាទីភារកិច្ច (២)ការគ្រប់គ្រងការផ្តល់សេវាសាធារណៈ (៣)ការអនុវត្តគម្រោងសាងសង់ ជួសជុល ថែទាំហេដ្ឋារចនាសម្ព័ន្ធ ក្នុងការិយបរិច្ឆេទ២០២២ និងបណ្តាឆ្នាំពាក់ព័ន្ធ
- បានដាក់ឆ្លងរបាយការណ៍ជាមួយថ្នាក់ដឹកនាំក្រសួងអធិការកិច្ចស្តីពីលទ្ធផលការចុះធ្វើអធិការកិច្ចលើ (១)ការអនុវត្តតួនាទីភារកិច្ច (២)ការគ្រប់គ្រងការផ្តល់សេវាសាធារណៈ (៣)ការអនុវត្តគម្រោងសាងសង់ ជួសជុល ថែទាំហេដ្ឋារចនាសម្ព័ន្ធ ក្នុងការិយបរិច្ឆេទ២០២២ និងបណ្តាឆ្នាំពាក់ព័ន្ធ នៅខេត្តកោះកុង ព្រៃវែង និងខេត្តកំពង់ចាម
- បានទទួលលិខិតលេខ៣៦៨ ស.អ.យ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាស្តីពីវិធានការកែលម្អកំហុសឆ្គងលើការអនុវត្តនីតិវិធីក្នុងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ក្នុងការិយបរិច្ឆេទ២០២១ នៅមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តរតនគិរី ស្ទឹងត្រែង ឧត្តរមានជ័យ បន្ទាយមានជ័យ បាត់ដំបង តាកែវ ក្រចេះ កោះកុង កណ្តាល ប៉ៃលិន ព្រៃវែង ត្បូងឃ្មុំ កំពង់ស្ពឺ កំពង់ចាម កែប ព្រះសីហនុ និងរាជធានីភ្នំពេញ។

**៣.៣.ការងារអធិការកិច្ចទី៣ លើវិស័យសង្គមកិច្ច**

- បានបញ្ចប់ការចុះធ្វើអធិការកិច្ចលើ (១)ការអនុវត្តតួនាទីភារកិច្ច (២)ការគ្រប់គ្រងការផ្តល់សេវាសាធារណៈ (៣)ការអនុវត្តគម្រោងសាងសង់ ជួសជុល ថែទាំហេដ្ឋារចនាសម្ព័ន្ធ ក្នុងការិយបរិច្ឆេទ២០២២ និងបណ្តាឆ្នាំពាក់ព័ន្ធ នៅរដ្ឋបាលខេត្តកំពង់ឆ្នាំង កំពង់ធំ និងខេត្តមណ្ឌលគិរី
- កំពុងដាក់ឆ្លងរបាយការណ៍ជាមួយរដ្ឋបាលខេត្តកំពង់ឆ្នាំង កំពង់ធំ និងខេត្តមណ្ឌលគិរីស្តីពីលទ្ធផលការចុះធ្វើអធិការកិច្ចលើ (១)ការអនុវត្តតួនាទីភារកិច្ច (២)ការគ្រប់គ្រងការផ្តល់សេវាសាធារណៈ (៣)ការអនុវត្តគម្រោងសាងសង់ ជួសជុល ថែទាំហេដ្ឋារចនាសម្ព័ន្ធ ក្នុងការិយបរិច្ឆេទ២០២២ និងបណ្តាឆ្នាំពាក់ព័ន្ធ។

**៣.៤.ការងារតាមដានការអនុវត្តច្បាប់**

- បានបញ្ចប់ការចុះតាមដានត្រួតពិនិត្យអនុក្រឹត្យលេខ៦៤ អនក្រ.បក ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកំណត់ និងការគ្រប់គ្រងទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ នៅខេត្តកណ្តាល ស្វាយរៀង និងខេត្តព្រះសីហនុ
- កំពុងដាក់ឆ្លងរបាយការណ៍ជាមួយរដ្ឋបាលខេត្តកណ្តាល ស្វាយរៀង និងខេត្តព្រះសីហនុស្តីពីលទ្ធផលការចុះតាមដានត្រួតពិនិត្យអនុក្រឹត្យលេខ៦៤ អនក្រ.បក ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកំណត់ និងការគ្រប់

គ្រងទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

៣.៥.ការងារតាមដានការអនុវត្តច្បាប់ (មន្ទីររាជធានី ខេត្ត)

- បានចុះតាមដានការអនុវត្តច្បាប់ស្តីពីព្រៃឈើ និងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន នៅស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ

- បានចុះតាមដានការអនុវត្តប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង កិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុ ការគ្រប់គ្រងថវិកាតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន នៅការិយាល័យអប់រំស្រុកបាទី សាលាបឋមសិក្សាអង្គ សាលាបឋមសិក្សាត្នោត វិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនបាទី វិទ្យាល័យហ៊ុនសែន១មិថុនា វិទ្យាល័យសុខអានទន្លេបាទី សាលាបឋមសិក្សាទន្លេបាទី កម្រងបឋមក្រាំងពង្រ កម្រងទន្លេបាទី និងវិទ្យាល័យឈើទាលជ្រុំ នៅស្រុកបាទី ខេត្តតាកែវ

- បានចូលរួមជាមួយគណៈបញ្ជាការឯកភាពស្រុកឯកភ្នំចុះតាមដានការអនុវត្តច្បាប់ស្តីពីជលផល នៅស្រុកឯកភ្នំ ចូលរួមបង្ក្រាបបទល្មើសទន្រ្ទានដីតំបន់៣ នៅចំណុចឃុំជ្រៃ ស្រុកមោងឫស្សី និងតាមដានការចុះបញ្ជីដីធ្លី ការកំណត់តំបន់វិនិច្ឆ័យដីធ្លីមានលក្ខណៈជាប្រព័ន្ធជូនប្រជាពលរដ្ឋតំបន់២ តាមបណ្តាស្រុកជាប់បឹងទន្លេសាប ខេត្តបាត់ដំបង

- បានចូលរួមជាមួយក្រុមការងាររដ្ឋបាលខេត្តកំពង់ធំចុះពិនិត្យករណីឈូសឆាយដីព្រៃសហគមន៍អូរចិញ្ចៀន ស្ថិតនៅភូមិត្រពាំងព្រីង ឃុំសាគ្រាម ស្រុកប្រាសាទបល្ល័ង្គ និងចុះតាមដានការអនុវត្តកិច្ចព្រមព្រៀងផ្គត់ផ្គង់ទឹក ស្ថិតនៅភូមិខ្សាច់ជីរស់ ឃុំកំពង់គោ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ

- បានចូលរួមជាមួយក្រុមការងាររដ្ឋបាលខេត្តកំពត និងជំនាញពាក់ព័ន្ធចុះអង្កេតតាមដានបទល្មើសព្រៃឈើ និងច្បាប់ស្តីពីការអនុញ្ញាតធ្វើសិប្បកម្មកែច្នៃផល-អនុផលព្រៃឈើ និងរោងសន្និធិ នៅតាមបណ្តាក្រុង ស្រុកមួយចំនួន ខេត្តកំពត

- បានចុះក្តាប់សភាពការណ៍លើការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត នៅតាមស្ថានីយប្រេងឥន្ធនៈចំនួន ៤ទីតាំង នៅស្រុកស្ទួល និងស្រុកឆ្លូង ខេត្តក្រចេះ

- បានចុះតាមដានការអនុវត្តច្បាប់ នៅតាមស្ថានីយប្រេងឥន្ធនៈ និងឧស្ម័នឥន្ធនៈចំនួន២៥ទីតាំង នៅក្រុងសំពៅពូន ខេត្តកណ្តាល។

៣.៦.ការងារតាមដានអនុសាសន៍នាយករដ្ឋមន្ត្រី

- ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៤ នៅសណ្ឋាគារសុខាភ្នំពេញ ក្នុងពិធីបិទកិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០២៣ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៤ **សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី** បានផ្តល់អនុសាសន៍ចំនួន៧ចំណុចរួមមាន៖

១.របៀបវារៈគោលនយោបាយអាទិភាព របស់រាជរដ្ឋាភិបាល នីតិកាលទី៧ ត្រូវបានរំលេចច្បាស់លាស់រួចហើយ ក្នុងកម្មវិធីនយោបាយ យុទ្ធសាស្ត្រ និងគោលនយោបាយតាមវិស័យនានា ជាពិសេសក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព: កសាងមូលដ្ឋានគ្រឹះឆ្ពោះសម្រេច ចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០ ដែល សម្តេច បានប្រកាសដាក់ឱ្យអនុវត្ត ក្នុងកិច្ចប្រជុំពេញអង្គលើកដំបូង នៃគណៈរដ្ឋមន្ត្រី នីតិកាលទី៧ នៃរដ្ឋសភា កាលពីថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣។ សម្តេច បានទាញចំណាប់អារម្មណ៍អំពីជំហ៊ា

"ស្នូល" នៃយុទ្ធសាស្ត្របញ្ចកោណ គឺការកែទម្រង់ និងការពង្រឹងអភិបាលកិច្ច ហើយកាលណានិយាយពីការកែទម្រង់អភិបាលកិច្ច គឺយើងត្រូវគិតដល់ការកែទម្រង់ផ្នែកគ្រប់គ្រងស្ថាប័ន ប្រព័ន្ធថវិកា ក្របខ័ណ្ឌគតិយុត្ត និងធនធានមនុស្សជាកញ្ចប់តែមួយ សំដៅធ្វើទំនើបកម្មស្ថាប័នរដ្ឋ ឱ្យក្លាយជារដ្ឋបាលសាធារណៈទំនើប ប្រកបដោយសមត្ថភាពខ្ពស់ ខ្លាំង វៃឆ្លាត និងស្អាតស្អំ តាមរយៈការអនុវត្តសិទ្ធិអំណាចរដ្ឋខាងផ្នែកនយោបាយ សេដ្ឋកិច្ច និងរដ្ឋបាល ក្នុងការដឹកនាំការគ្រប់គ្រង និងការចាត់ចែងកិច្ចការប្រទេសជាតិ ពិសេសការធានានិរន្តរភាព នៃតួនាទី និងដំណើរការរដ្ឋបាលសាធារណៈ ដោយយកចិត្តទុកដាក់លើផលប្រយោជន៍ប្រជាជន ព្រមជាមួយនឹងការកសាងជាតិ និងការពង្រឹងនីតិរដ្ឋ សំដៅគាំទ្រដល់ការអភិវឌ្ឍសង្គម សេដ្ឋកិច្ច ប្រកបដោយបរិយាបន្ន និងចីរភាព។ ក្នុងស្មារតីនេះ សម្តេច បានសម្រេចចិត្តទទួលដឹកនាំផ្ទាល់ លើការងារពាក់ព័ន្ធនឹង "វិធានការគន្លឹះ" ចំនួន៣ ក្នុងចំណោមវិធានការគន្លឹះទាំង៥ ដែលបានប្រកាសដាក់ចេញជាមួយយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ក្នុងសម័យប្រជុំដំបូង នៃគណៈរដ្ឋមន្ត្រី គឺ៖ (១)ការកែទម្រង់គុណភាពរដ្ឋបាលសាធារណៈ ដោយផ្តោតជាពិសេសលើការជ្រើសរើសមន្ត្រី ការពង្រឹងប្រសិទ្ធភាពស្ថាប័ន និងការរៀបចំនូវប្រព័ន្ធលើកទឹកចិត្តមួយដែលផ្អែកលើសមិទ្ធកម្ម (២)ការកែទម្រង់គុណភាពវិស័យអប់រំ ជាពិសេសពីថ្នាក់មត្តេយ្យសិក្សា ដល់មធ្យមសិក្សា (៣)ការកែទម្រង់គុណភាពវិស័យសុខាភិបាល ជាពិសេសនៅតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែកនៅទូទាំងប្រទេស។ ច្បាស់ណាស់ថា របៀបវារៈជាអាទិភាពទាំងអស់នេះសុទ្ធតែមានការពាក់ព័ន្ធដោយផ្ទាល់ជាមួយនឹង "កម្មវិធី កែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ"

២.ពិតណាស់ ការកំណត់ និងការដាក់ចេញ នូវគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីអាទិភាពនានា ដែលមានភាពច្បាស់លាស់ ចំគោលដៅ និងគ្រប់ជ្រុងជ្រោយ សំដៅឆ្លើយតបទៅនឹងសំណូមពរ នៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ក៏ដូចជាឆ្លើយតបនឹងបំណងប្រាថ្នារបស់ប្រជាជន គឺជាកិច្ចការដ៏មានសារៈសំខាន់។ ក៏ប៉ុន្តែ អ្វីដែលរឹតតែសំខាន់ជាងនេះទៅទៀតនោះ គឺប្រសិទ្ធភាព នៃការអនុវត្ត ដើម្បីប្រែក្លាយគោលនយោបាយ ឬកម្មវិធី កែទម្រង់ទាំងឡាយ ដែលយើងបានដាក់ចេញមកនោះ ឱ្យស្តែងឡើងជាលទ្ធផលក្នុងភាពជាក់ស្តែង តាមការរំពឹងទុក។ នេះ គឺជាចំណុចសំខាន់ ដែលយើងត្រូវពង្រឹង ចាប់ពីពេលនេះតទៅ។ ក្នុងស្មារតីនេះ សម្តេចក៏បានលើកឡើងជារឿយៗកន្លងមកហើយដែរថា អាណត្តិទី៧ នេះ គឺជាអាណត្តិនៃការពង្រឹងគុណភាព និងសមត្ថភាពស្ថាប័ន លើមូលដ្ឋានដែលយើងមានស្រាប់ជាជាងការពង្រីក។ ក្នុងន័យនេះ ដើម្បីឱ្យគោលនយោបាយ និងការកែទម្រង់របស់យើង មានប្រសិទ្ធភាព និងផ្តល់ផលជាក់ស្តែង បានល្អតាមការរំពឹងចង់បាន សម្តេច សូមផ្តល់អនុសាសន៍ឱ្យគ្រប់ក្រសួង ស្ថាប័នទាំងអស់ នៅគ្រប់កម្រិត ត្រូវប្រកាន់យក "អភិក្រមធ្វើការប្រទាក់ក្រឡាគ្នាជារដ្ឋាភិបាលទាំងមូល" (Whole of government approach) ឬ "អភិក្រមឯកភាពនៃប្រព័ន្ធតួអង្គតែមួយ" ទាំងនៅក្នុងដំណាក់កាលរៀបចំ និងដំណាក់កាលអនុវត្ត នូវគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីនានា ជាពិសេសចំពោះការងារដែលមានចរិតអន្តរវិស័យ មានភាពប្រទាក់ក្រឡាគ្នា និងត្រូវការកិច្ចសហការរវាងតួអង្គច្រើន ចៀសវាងធ្វើការងារដាច់ដោយដុំៗ ដែលជាហេតុអាចនាំទៅដល់ការបាត់បង់នូវប្រសិទ្ធភាព និងប្រសិទ្ធផល នៃការងារ ក៏ដូចជាបង្កនូវភាពមិនច្បាស់លាស់ ក្នុងការទទួលខុសត្រូវ។ បច្ចុប្បន្ន យើងមានយន្តការប្រទាក់ក្រឡាអន្តរកែទម្រង់មួយ ដើម្បីសម្របសម្រួលរវាងកម្មវិធីកែទម្រង់គន្លឹះចំនួន៤ គឺ៖ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីកែទម្រង់តាមបែបវិមជ្ឈការ និងវិសហមជ្ឈការ និងកម្មវិធីកែទម្រង់ប្រព័ន្ធយុត្តិធម៌។ ក្នុងស្មារតីជានាដ៏រុញបង្កើនប្រសិទ្ធភាពការងារ សម្តេចសូមលើកទឹកចិត្តឱ្យពង្រឹង

និងក្នុងករណីចាំបាច់ ពិនិត្យកែសម្រួលយន្តការនេះផងដែរ ដើម្បីឱ្យយន្តការនេះ ក្លាយទៅជាគំរូមួយ ក្នុងការអនុវត្ត "អភិក្រមរដ្ឋាភិបាលទាំងមូល" ឬ "អភិក្រមជីវភាព នៃប្រព័ន្ធតួអង្គតែមួយ" ដូចដែល សម្តេច បានលើកឡើងពីខាងលើ

៣.នៅក្នុងគោលដៅ នៃ "ការពង្រឹងគណនេយ្យភាពសមិទ្ធកម្ម" ដែលសំដៅទៅដល់ការទទួលខុសត្រូវផ្អែកលើលទ្ធផលការកែទម្រង់របស់រាជរដ្ឋាភិបាលកម្ពុជា បានឈានចូលមកដល់ដំណាក់កាលយុទ្ធសាស្ត្រកម្រិតខ្ពស់ ដែលជាគោលដៅដ៏ចម្បងរបស់យើងនោះ គឺការប្រែប្រួលជាសារវ័ន្ត ផ្នែកគោលនយោបាយ និងយុទ្ធសាស្ត្រអាទិភាព ដែលសំដៅដល់ការពង្រឹងប្រសិទ្ធភាព គុណភាព និងការទទួលខុសត្រូវលើលទ្ធផល នៃការអនុវត្តរបស់ស្ថាប័នសាធារណៈ និងមន្ត្រីរាជការ ក្នុងក្របខ័ណ្ឌរាជរដ្ឋាភិបាលទាំងមូល។ ក្នុងន័យនេះ សម្រាប់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាមួយនឹងការទទួលបាននូវការផ្ទេរសិទ្ធិអំណាច ក្នុងការគ្រប់គ្រងធនធានហិរញ្ញវត្ថុរបស់ខ្លួន ក្រសួង ស្ថាប័ននីមួយៗនឹងត្រូវមានការទទួលខុសត្រូវខ្ពស់ លើការប្រើប្រាស់ថវិកា ឱ្យបានប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ព្រមទាំងចំគោលដៅកំណត់ ពោលគឺ ម្ខាងត្រូវទទួលខុសត្រូវលើការសម្រេចឱ្យបាន នូវគោលបំណងគោលនយោបាយ បេសកកម្ម និងសូចនាករលទ្ធផលរំពឹងទុករបស់ខ្លួន អនុលោមតាមគោលការណ៍ នៃ"ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ" និងម្ខាងទៀត ត្រូវទទួលខុសត្រូវយ៉ាងម៉ឺងម៉ាត់ លើការប្រើប្រាស់ថវិកាដែលត្រូវបានអនុម័តផ្តល់ជូន ឱ្យបានប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ព្រមទាំងធានាបាននូវ "តម្លៃ នៃលុយ" ស្របតាមបទប្បញ្ញត្តិ នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាធរមាន។ ក្នុងស្មារតីនេះ សម្តេច សូមស្នើថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃគ្រប់ក្រសួង ស្ថាប័ន ដែលជាតួអង្គនិម្មាបនករ និងប្រតិបត្តិករ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ផ្តោតការយកចិត្តទុកដាក់លើកិច្ចការគន្លឹះមួយចំនួន ដោយរួមបញ្ចូលនូវ៖ (១)ត្រូវបង្កើនភាពជាម្ចាស់ក្នុងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅតាមក្រសួង ស្ថាប័ន ដោយរដ្ឋមន្ត្រី និងប្រធានស្ថាប័ន ត្រូវជំរុញអនុវត្តប្រកបដោយភាពជាម្ចាស់ នូវកិច្ចការកែទម្រង់ការគ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈ ទៅតាមគោលការណ៍រួមរបស់រាជរដ្ឋាភិបាល (២)ត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវ "ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ" ឆ្នាំ២០២៣ និងត្រូវរៀបចំបទដ្ឋានគតិយុត្តចាំបាច់ទាំងឡាយ សម្រាប់អនុវត្តច្បាប់នេះ ឱ្យបានទាន់ពេល (៣)ត្រូវបន្តជំរុញអនុវត្តយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិកា និងយុទ្ធសាស្ត្រកែទម្រង់ពាក់ព័ន្ធផ្សេងទៀត ឱ្យសម្រេចបានលទ្ធផលតាមការគ្រោងទុក (៤)ត្រូវជំរុញការរៀបចំ និងការអនុវត្តវិមជ្ឈការហិរញ្ញវត្ថុ ឱ្យកាន់តែមានប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព (៥)ត្រូវជំរុញការរៀបចំ និងការអនុម័តលើក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម (៦)ត្រូវរៀបចំការវិភាគគ្រប់ជ្រុងជ្រោយ ដើម្បីកំណត់កម្រិតស្មុគស្មាញ នៃបញ្ហាទាំងអស់ នៅក្នុងកិច្ចដំណើរការកែទម្រង់ប្រព័ន្ធថវិកា ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងត្រូវស្វែងរកយុទ្ធសាស្ត្រដោះស្រាយ ឱ្យចំចរិត នៃបញ្ហានីមួយៗ សំដៅធានាថា ទិសដៅយុទ្ធសាស្ត្រ នៃការកែទម្រង់ប្រព័ន្ធថវិកា ផ្អែកលើគោលការណ៍ "គណនេយ្យភាពសមិទ្ធកម្ម" នឹងសម្រេចបានតាមគោលដៅកំណត់ (៧)ត្រូវបន្តធ្វើការសិក្សាលើក្របខ័ណ្ឌសិទ្ធិអំណាច និងបន្ទាត់គណនេយ្យភាព ដែលត្រូវបានដាក់ចេញកន្លងមកក្នុងក្របខណ្ឌការអនុវត្តថវិកាកម្មវិធី និងអង្គភាពថវិកា តាំងពីកម្រិតគោលបំណង គោលនយោបាយ កម្រិតកម្មវិធី រហូតដល់កម្រិតសកម្មភាពប្រតិបត្តិ ហើយរៀបចំបន្សីជាមួយនឹងរចនាសម្ព័ន្ធរបស់ស្ថាប័ន

៤.សម្តេច សូមលើកទឹកចិត្ត ដល់គណៈកម្មាធិការដឹកនាំការងារកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យបន្តជំរុញលើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយរួមទាំង និង

ប្រទាក់ក្រឡាគ្នា ជាមួយនឹងកម្មវិធីកែទម្រង់ផ្សេងទៀតរបស់រាជរដ្ឋាភិបាល

៥.ដើម្បីធានាបាននូវប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ក្នុងការអនុវត្តការងាររបស់ខ្លួន រាជរដ្ឋាភិបាល ត្រូវការជាចាំបាច់នូវប្រព័ន្ធត្រួតពិនិត្យ តាមដាន និងវាយតម្លៃប្រកបដោយសង្គតិភាព និងគុណភាព។ បច្ចុប្បន្ន យើងមានមុខងារសវនកម្ម និងអធិការកិច្ច ដែលកំពុងអនុវត្តដោយក្រសួង ស្ថាប័ននានារួមមាន៖ អាជ្ញាធរសវនកម្មជាតិ ក្រសួងអធិការកិច្ច ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមុខងារសាធារណៈ ព្រមទាំងសវនកម្មផ្ទៃក្នុង និងអធិការកិច្ចនៅតាមក្រសួង ស្ថាប័ននីមួយៗ។ ក្រៅពីប្រព័ន្ធត្រួតពិនិត្យអនុលោមភាពនេះ យើងក៏បាន និងកំពុងប្រើប្រាស់វិធីសាស្ត្រ "ត្រួតពិនិត្យ តាមដាន និងវាយតម្លៃ" (M&E) ផងដែរ។ ប្រព័ន្ធត្រួតពិនិត្យទាំងនេះ ពិតជាមានសារៈសំខាន់មិនអាចខ្វះបាន សម្រាប់ការពង្រឹងប្រសិទ្ធភាព ក្នុងការអនុវត្តមុខងារ និងភារកិច្ចរបស់ក្រសួង ស្ថាប័ន ក៏ដូចជាក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ដូចនេះ ទន្ទឹមនឹងការផ្ទេរសិទ្ធិអំណាច មុខងារ និងការគ្រប់គ្រងថវិកា ទៅកាន់អង្គភាពថវិកានានា ក៏ត្រូវមានការធានាផងដែរថា មុខងារត្រួតពិនិត្យទាំងនេះ ត្រូវបានពង្រឹង ដើម្បីជាកញ្ចក់ឆ្លុះដ៏ស័ក្តិសិទ្ធ សម្រាប់ជួយដល់ក្របខ័ណ្ឌបន្ទាត់គណនេយ្យភាព ឱ្យមានដំណើរការល្អ។ យ៉ាងណាមិញ រាជរដ្ឋាភិបាលក៏ទទួលស្គាល់ដែរថា ការអនុវត្តមុខងារអធិការកិច្ច សវនកម្ម ត្រួតពិនិត្យ តាមដាន និងវាយតម្លៃ ដោយក្រសួង ស្ថាប័នច្រើនផ្សេងគ្នា ក៏អាចបង្កើតជាបញ្ហាប្រឈមមួយចំនួន ដែលដាក់បន្ទុកលើប្រសិទ្ធភាពការងារ នៃវិស័យសាធារណៈ និងវិស័យឯកជនផងដែរ។ សម្តេច ក៏សូមលើកទឹកចិត្តឱ្យគណៈកម្មាធិការដឹកនាំ ការងារកែទម្រង់ការងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជំរុញធ្វើការសិក្សា និងស្នើឡើងនូវក្របខ័ណ្ឌធ្វើសុខដុមនីយកម្មមុខងារប្រព័ន្ធអធិការកិច្ច និងសវនកម្ម ដើម្បីជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេចឱ្យបានឆាប់ផងដែរ

៦.សម្តេច ក៏សូមគូសរំលេចបន្ថែមនូវភាពចាំបាច់ នៃការផ្សារភ្ជាប់ "ការពង្រឹងគណនេយ្យភាពសមិទ្ធកម្ម" នៅក្នុងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទៅនឹង "ការលើកតម្កើងវប្បធម៌គុណាធិបតេយ្យ" ផងដែរ ពោលគឺការប្រកាន់យកគោលការណ៍ "គុណភាព សមត្ថភាព និងគុណាធិបតេយ្យ" ជាវប្បធម៌ការងារ ពិសេសនៅក្នុងការគ្រប់គ្រងធនធានមនុស្ស។ ប្រការនេះ សំដៅដល់ភាពចាំបាច់ក្នុងការផ្តល់នូវឱកាស និងការលើកទឹកចិត្ត ទាំងផ្នែកហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ ប្រកបដោយសមធម៌ និងយុត្តិធម៌ ជូនដល់មន្ត្រី បុគ្គលិកគ្រប់ជាន់ថ្នាក់ ដោយផ្អែកលើគុណសម្បត្តិ ស្របតាមគុណវុឌ្ឍិ បទពិសោធន៍ សមត្ថភាព ឆន្ទៈ និងវិន័យ ក្នុងការបំពេញការងារ។ គោលការណ៍នេះ ត្រូវអនុវត្តមិនត្រឹមតែក្នុងក្របខ័ណ្ឌ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប៉ុណ្ណោះទេ ប៉ុន្តែវាត្រូវតែក្លាយទៅជាគោលការណ៍អាទិភាពមួយរបស់រាជរដ្ឋាភិបាល សម្រាប់ពង្រឹងអភិបាលកិច្ច និងសមត្ថភាពស្ថាប័ន នូវគ្រប់កម្រិត

៧.ចំណុចចុងក្រោយដែលសម្តេចចង់លើក គឺពាក់ព័ន្ធទៅនឹងភាពចាំបាច់ ក្នុងការបន្តជ្រោងឱ្យកាន់តែខ្ពស់នូវ "ស្មារតីកែទម្រង់"។ រយៈពេល២០ឆ្នាំកន្លងមកនេះ កម្ពុជាបានធ្វើដំណើរឆ្លងកំណាត់ផ្លូវដ៏វែងឆ្ងាយ នៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ជាការពិត សមិទ្ធផលទាំងឡាយ នៃការកែទម្រង់នេះ មិនមែនទទួលបានមកដោយងាយស្រួលនោះទេ។ ជាសត្យានុម័ត ទាំងក្នុងអតីតកាល ទាំងក្នុងបច្ចុប្បន្នកាល និងតទៅអនាគតកាល គ្មានកិច្ចការកែទម្រង់ណាមួយដែលងាយស្រួលនោះទេ ហើយក៏មិនមានសមិទ្ធផលណាមួយ នៃកិច្ចការកែទម្រង់ ដែលអាចសម្រេចបានមក ដោយគ្មានការបង់ថ្លៃនោះដែរ។ ដូចសម្តេចធ្លាប់បានលើកឡើង ក្នុងវេទិកាមួយចំនួនកន្លងទៅ កិច្ចការកែទម្រង់ដែលជោគជ័យ ត្រូវតែផ្អែកលើកត្តាសំខាន់បួន គឺ៖ (១)ត្រូវមានចក្ខុវិស័យច្បាស់លាស់ (២)

ត្រូវមានការប្តេជ្ញាចិត្តខ្ពស់ (៣)ត្រូវមានការចូលរួមដោយស្មោះត្រង់ (៤)ត្រូវមានការលះបង់។ លើមូលដ្ឋាននេះ សម្តេច គូសបញ្ជាក់ជាថ្មីម្តងទៀតថា រាជរដ្ឋាភិបាលអាណត្តិទី៧ នឹងបន្តប្រកាន់ខ្ជាប់នូវអភិក្រមទាំង៥ប្រការរបស់ សម្តេចតេជោ អតីតនាយករដ្ឋមន្ត្រី សម្រាប់ការបំពេញការងាររបស់ខ្លួន ដែលជាស្មារតីបុរេសកម្ម ភ្ញាក់រលឹក និងម៉ឺងម៉ាត់ ក្នុងការកែទម្រង់មុតស្រួច ស៊ីជម្រៅ និង គ្រប់ជ្រុងជ្រោយ ពោល គឺ៖ ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់។

- ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៤ នៅសាកលវិទ្យាល័យជាតិគ្រប់គ្រងសាខាវាលស្បូវ សម្ពោធអគារសាកលវិទ្យាល័យជាតិគ្រប់គ្រងសាខាវាលស្បូវ ក្នុងពិធីប្រគល់សញ្ញាបត្រជូននិស្សិតជាង៥ពាន់នាក់ សម្តេច បានលើកទឹកចិត្ត និងផ្តល់ទស្សនៈមួយចំនួន ដើម្បីរួមចំណែកដល់ការលើកកម្ពស់គុណភាពអប់រំ នៅកម្ពុជា ដូចតទៅ៖

១.ក្រសួងអប់រំ យុវជន និងកីឡា ត្រូវបន្តយកចិត្តទុកដាក់ឱ្យកាន់តែខ្ពស់លើការអភិវឌ្ឍធនធានមនុស្ស ទាំងបរិមាណ និងគុណភាព ដើម្បីឆ្លើយតបឱ្យកាន់តែប្រសើរទៅនឹងតម្រូវការ និងការកើនឡើងនៃការប្រកួតប្រជែងក្នុងទីផ្សារការងារ ព្រមទាំងការអភិវឌ្ឍសង្គម សេដ្ឋកិច្ច ជាពិសេសក្នុងបរិការណ៍ការប្រកួតប្រជែងលើគ្រប់ទិដ្ឋភាព ទាំងភូមិសាស្ត្រនយោបាយ សេដ្ឋកិច្ច និងសង្គម ក៏ដូចជាការរីកលូតលាស់យ៉ាងឆាប់រហ័ស នៃបច្ចេកវិទ្យា ការអភិវឌ្ឍសង្គម សេដ្ឋកិច្ច ឆ្ពោះទៅរកការប្រើប្រាស់បច្ចេកវិទ្យា និងការផ្លាស់ប្តូរនិម្មាបនកម្មសកល ដើម្បីបង្កើនភាពធន់ និងកសាងសង្គមសេដ្ឋកិច្ចឌីជីថលរឹងមាំ

២.ក្រសួងអប់រំ យុវជន និងកីឡា ត្រូវបន្តលើកកម្ពស់ការអប់រំឌីជីថល ដើម្បីរួមចំណែក កសាងពលរដ្ឋឌីជីថល និងបង្កើនសមត្ថភាពសិស្ស និស្សិត លើវិស័យឌីជីថល សំដៅបង្កើនប្រសិទ្ធភាព នៃការបង្រៀន និងការរៀនតាមប្រព័ន្ធឌីជីថលព្រមទាំងលើកកម្ពស់ស្វ័យសិក្សារបស់សិស្ស និស្សិត។ ក្នុងន័យនេះ ក្រសួងអប់រំ យុវជន និងកីឡា ត្រូវសហការជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ធ្វើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថលនៅតាមសាលារៀន ជាពិសេសសាលារៀននៅទីជនបទ និងតំបន់ដាច់ស្រយាល ដើម្បីជំរុញការបណ្តុះបណ្តាលតាមប្រព័ន្ធអនឡាញ ប្រកបដោយប្រសិទ្ធភាព និងចីរភាព ព្រមទាំងលើកទឹកចិត្តឱ្យមានការសិក្សាស្រាវជ្រាវ និងការរៀនមួយជីវិតសម្រាប់ទាំងអស់គ្នា

៣.គ្រឹះស្ថានឧត្តមសិក្សាត្រូវបន្តកែទម្រង់ប្រព័ន្ធសិក្សាឱ្យកាន់តែល្អប្រសើរ និងអភិវឌ្ឍកម្មវិធីសិក្សាថ្មីៗ ស្របតាមឧត្តមានុវត្តតំបន់ និងអន្តរជាតិ ដោយផ្តោតការយកចិត្តទុកដាក់បន្ថែមលើពុទ្ធិ និងជំនាញផ្នែកបច្ចេកវិទ្យា និងឌីជីថល ស្របតាមនិន្នាការ នៃសេដ្ឋកិច្ច និងសង្គម តម្រូវការនៃទីផ្សារការងារ និងបដិវត្តឧស្សាហកម្មទី៤

៤.សាកលវិទ្យាល័យជាតិគ្រប់គ្រង និងគ្រឹះស្ថានឧត្តមសិក្សាដទៃទៀត ត្រូវបង្កើនកិច្ចសហប្រតិបត្តិការជាមួយគ្រឹះស្ថានឧត្តមសិក្សា និងគ្រឹះស្ថានស្រាវជ្រាវជាតិ-អន្តរជាតិ សម្រាប់ធ្វើការសិក្សាស្រាវជ្រាវរួមគ្នា ដកស្រង់បទពិសោធន៍ និងធ្វើទស្សនកិច្ចសិក្សាទៅវិញទៅមក ដើម្បីទទួលបានចំណេះដឹងថ្មីៗ ការពិសោធជាក់ស្តែង និងឧត្តមានុវត្ត សំដៅបង្កើនគុណភាព នៃការអប់រំ ការបណ្តុះបណ្តាល និងការសិក្សាស្រាវជ្រាវឱ្យកាន់តែប្រសើរ ជាមួយនឹងការផ្លាស់ប្តូរ និស្សិតអាហារូបករណ៍រវាងសាកលវិទ្យាល័យដៃគូ

៥.សាកលវិទ្យាល័យត្រូវបន្តអភិវឌ្ឍសមត្ថភាពជាប្រចាំ និងបង្កើនការសិក្សាស្រាវជ្រាវបែបវិទ្យាសាស្ត្រតាមជំនាញឯកទេសរៀងៗខ្លួន ដើម្បីលើកកម្ពស់គុណភាព និងប្រសិទ្ធភាព នៃការបង្រៀន និងការផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្តជាក់ស្តែង ដើម្បីផ្ទេរចំណេះជាក់ស្តែង ទាំងទ្រឹស្តី ការអនុវត្ត និងឧត្តមានុវត្ត ជូនដល់សិស្ស និស្សិត។

- ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៤ នៅសណ្ឋាគារសុខាភ្នំពេញ ក្នុងពិធីសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៣ និងលើកទិសដៅឆ្នាំ២០២៤ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងផ្សព្វផ្សាយផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៩។ ដើម្បីជំរុញការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនឱ្យកាន់តែមានប្រសិទ្ធភាព សម្តេចបវរធិបតី នាយករដ្ឋមន្ត្រី បានផ្តល់អនុសាសន៍បន្ថែមមួយចំនួន សម្រាប់យកទៅអនុវត្តបន្តដូចខាងក្រោម៖

១.សម្តេច សូមស្នើឱ្យគ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ វិស័យឯកជន និងបងប្អូនប្រជាពលរដ្ឋទាំងអស់ ត្រូវចាត់ទុកបញ្ហាគ្រឿងញៀនជាបញ្ហារួម ដែលត្រូវចូលរួមទាំងអស់គ្នា ស្របតាមអភិក្រម "ជរភាពនៃប្រព័ន្ធតួអង្គតែមួយ" និងសហថាមពល ដើម្បីទប់ស្កាត់ និងប្រយុទ្ធប្រឆាំង សំដៅឈានដល់ការលុបបំបាត់ពីកម្ពុជា។ ក្នុងន័យនេះ គ្រប់ថ្នាក់ដឹកនាំក្រសួង ស្ថាប័ន ក្រុមហ៊ុនឯកជន រោងចក្រ សហគ្រាស និងសមាជិកគ្រួសារត្រូវធ្វើការអប់រំ ក្រើនរំលឹកពីផលប៉ះពាល់ និងវិនាសកម្ម នៃគ្រឿងញៀន ព្រមទាំងមានវិធានការម៉ឺងម៉ាត់ និងតឹងរ៉ឹងបំផុត ចំពោះការប្រើប្រាស់គ្រឿងញៀន។ ត្រូវនិយាយថា "ទេ" ដាច់ខាតចំពោះគ្រឿងញៀន!

២.អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវរៀបចំចងក្រងខ្លឹមសារអប់រំ អំពីផលប៉ះពាល់ នៃគ្រឿងញៀន និងធ្វើការផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹង តាមគ្រប់មធ្យោបាយ ដល់ប្រជាជនឱ្យបានទូលំទូលាយ។ ជាមួយគ្នានេះ សម្តេច សូមឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធ ជាពិសេសក្រសួងព័ត៌មាន ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងធម្មការ និងសាសនា និងក្រសួងទេសចរណ៍ ត្រូវចូលរួមសហការជាមួយអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន លើការងារដ៏សំខាន់នេះ ដើម្បីបញ្ជ្រាបការយល់ដឹងអំពីបញ្ហាគ្រឿងញៀន និងផ្សព្វផ្សាយទូលំទូលាយ ទាំងនៅតាមសាលារៀន វត្តអារាម សិល្បៈកំសាន្ត កីឡា និងវេទិកានានា

៣.អាជ្ញាធរមានសមត្ថកិច្ចតាមព្រំដែន ជាពិសេសក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ និងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ត្រូវពង្រឹងការទប់ស្កាត់ និងបង្ក្រាបករណីនាំចូលគ្រឿងញៀនតាមព្រំដែន ផ្លូវគោក ផ្លូវទឹក ផ្លូវអាកាស និងបញ្ញើប្រៃសណីយ៍ ជាពិសេសមកពីតំបន់ត្រីកោណមាស។ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវសហការជាមួយដៃគូអន្តរជាតិ ក្នុងការផ្លាស់ប្តូរព័ត៌មានអំពីចរាចរគ្រឿងញៀនឆ្លងដែនខុសច្បាប់

៤.មន្ត្រីអនុវត្តច្បាប់ជាពិសេស គណៈបញ្ជាការឯកភាពរាជធានី ខេត្ត ត្រូវចាត់វិធានការយ៉ាងតឹងរ៉ឹង និងម៉ឺងម៉ាត់ជាទីបំផុត ចំពោះករណីចែកចាយ និងប្រើប្រាស់គ្រឿងញៀននៅក្នុងសហគមន៍។ សម្តេច សូមកោតសរសើរចំពោះអគ្គស្នងការដ្ឋាននគរបាលជាតិ ក៏ដូចជាគណៈបញ្ជាការឯកភាពរាជធានីភ្នំពេញ ដែលកន្លងមកបានធ្វើការបង្ក្រាបករណីចែកចាយ និងប្រើប្រាស់គ្រឿងញៀននៅតាមក្លឹបកំសាន្ត និងKTV។ សម្រេច បានឱ្យគណៈបញ្ជាការឯកភាពរាជធានី ខេត្ត ត្រូវយកចិត្តទុកដាក់ខ្ពស់លើបញ្ហានេះ ដោយត្រូវចាត់វិធានការទាំងរដ្ឋបាល និងវិធានការច្បាប់ចំពោះទីតាំងដែលមានការចែកចាយ និងប្រើប្រាស់គ្រឿងញៀន ជាពិសេសត្រូវក្តាប់ និងកំណត់ឱ្យបាននូវអត្តសញ្ញាណម្ចាស់ទីតាំងពិតប្រាកដ និងត្រូវចាត់វិធានការឱ្យដល់ឫសគល់។ ចំពោះការប្រើប្រាស់គ្រឿងញៀននៅជនបទ សម្តេច សូមឱ្យអាជ្ញាធរថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ ត្រូវលុបបំបាត់ទាំងស្រុង ដោយត្រូវបង្ក្រាបមេក្លោង និងបណ្តាញចែកចាយតាមភូមិ ឃុំ សង្កាត់ និងត្រូវសហការជាមួយឪពុកម្តាយ អាណាព្យាបាល ប្រមូល[illegible]ពីសហគមន៍ ដើម្បីមកទទួលការបន្សាប ព្យាបាល និងស្តារនីតិសម្បទា នៅតាមមណ្ឌលរដ្ឋ និង[illegible]

៥.អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវសហការជាមួយគណៈកម្មាធិការទទួលបន្ទុក[illegible]

នីតិសម្បទាអ្នកញៀនគ្រឿងញៀន ជាពិសេសក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងសុខាភិបាល ពង្រឹងគុណភាព នៃការបន្សាប និងព្យាបាលអ្នកញៀនគ្រឿងញៀន ដោយក្នុងនោះត្រូវគិតគូរ ពីការរៀបចំស្តង់ដានីតិវិធីអនុវត្តន៍ (SOP) ឱ្យបានច្បាស់លាស់ នៃវិធីសាស្ត្រការព្យាបាលអ្នកញៀនគ្រឿងញៀន និង សហការជាមួយអង្គការសុខភាពពិភពលោក ដើម្បីខិតខំស្រាវជ្រាវរកវិធីសាស្ត្រព្យាបាលថ្មីៗដែលមានប្រសិទ្ធភាព កាន់តែល្អប្រសើរ។ សម្តេច សូមលើកទឹកចិត្តការវិនិយោគ ក្នុងការបើកមជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទាឯកជន ទន្ទឹមនេះ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវសហការជាមួយ ស្ថាប័នពាក់ព័ន្ធ កំណត់ស្តង់ដា និងលក្ខខណ្ឌច្បាស់លាស់ក្នុងការគ្រប់គ្រង ហើយរាល់មជ្ឈមណ្ឌលឯកជន ត្រូវតែស្ថិតក្រោមការត្រួតពិនិត្យរបស់រដ្ឋ ដើម្បីធានាប្រសិទ្ធភាពលើការងារដ៏សំខាន់នេះ

៦.ស្ថាប័នអនុវត្តច្បាប់ អាជ្ញាធរមានសមត្ថកិច្ច ជាពិសេសក្រសួងយុត្តិធម៌ ត្រូវយកចិត្តទុកដាក់លើករណីផ្តន្ទាទោសឧក្រិដ្ឋជនគ្រឿងញៀនឱ្យបានធ្ងន់ធ្ងរ និងយុត្តិធម៌បំផុត ចៀសវាងការដោះលែងឧក្រិដ្ឋជនពាក់ព័ន្ធនឹងគ្រឿងញៀន ឬការបន្ធូរបន្ថយទោសណាមួយ។ សម្តេចសូមគាំទ្រចំណាត់ការរបស់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ក្នុងការផ្សាយព័ត៌មានជាសាធារណៈអំពីចំណាត់ការលើសំណុំរឿងគ្រឿងញៀន ដើម្បីបង្ហាញពីតម្លាភាពនៃការផ្តន្ទាទោសបទល្មើសគ្រឿងញៀន។ ពាក់ព័ន្ធនឹងបញ្ហានេះ សម្តេច សូមឱ្យបន្តអនុវត្តទិសស្លោក ៣កុំ ១រាយការណ៍ គឺកុំពាក់ព័ន្ធ កុំធ្វើអន្តរាគមន៍ កុំបន្ធូរបន្ថយ និង ត្រូវរាយការណ៍

៧.អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវសហការជាមួយក្រុមការងារអន្តរក្រសួង គ្រប់គ្រងសារធាតុញៀន និងសារធាតុគីមីផ្សំ ដែលរាជរដ្ឋាភិបាលទើបបង្កើតឡើងថ្មីៗនេះ គ្រប់គ្រង និងលុបបំបាត់ករណីនាំចូលសារធាតុញៀន និងគីមីផ្សំ ការលួចលាក់កែច្នៃ និងផលិតគ្រឿងញៀន ដោយត្រូវរៀបចំជា SOP ច្បាស់លាស់ក្នុងការត្រួតពិនិត្យគ្រប់គ្រង។ គណៈបញ្ជាការឯកភាពរាជធានី ខេត្ត ត្រូវបង្កើនការត្រួតពិនិត្យរដ្ឋបាល ឱ្យហ្មត់ចត់ជាប់ជាប្រចាំ និងយកចិត្តទុកដាក់ខ្ពស់ ក្នុងការកំណត់ទីតាំងដែលសង្ស័យប្រើប្រាស់ លួចកែច្នៃ ផលិត ជាពិសេស ទីតាំងនៅតំបន់ដាច់ស្រយាល ត្រូវបង្កើតការត្រួតពិនិត្យរដ្ឋបាលឱ្យម៉ត់ចត់ជាប់ជាប្រចាំ

៨.អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិ ទាំងទ្វេភាគី ពហុភាគី ក្នុងតំបន់ និងសកល ពីព្រោះថាបញ្ហាគ្រឿងញៀន គឺជាបញ្ហាសកល ដែលទាមទារនូវវិធានការជាសកល និងគ្រប់ស្ថាប័នអនុវត្តច្បាប់នៅក្នុងតំបន់ និងសកល ត្រូវបង្កើនកិច្ចសហការរួមគ្នាជាកម្លាំងតែមួយ ក្នុងការប្រយុទ្ធប្រឆាំងនឹងបញ្ហាសកលនេះ។ ជាមួយនឹងកិច្ចសហការអន្តរជាតិនេះ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវបន្តសហការផ្លាស់ប្តូរព័ត៌មានជាប់ជាប្រចាំ និងខិតខំកៀរគរជំនួយពីបណ្តាប្រទេសជាមិត្ត អង្គការជាតិ និងអន្តរជាតិ លើការងារកសាងសមត្ថភាពមន្ត្រី ជំនួយសម្ភារៈបច្ចេកទេសប្រឆាំងគ្រឿងញៀន និងការងារបន្សាបសារធាតុញៀនមុនពេលដុតបំផ្លាញ ដែលបញ្ហាទាំងនេះ ដែលបញ្ហាទាំងនេះទាមទារឱ្យមានការជួយជ្រោមជ្រែងពីបណ្តាភាគីជាមិត្ត។

- ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ នៅទីស្តីការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៣ និងលើកទិសដៅការងារឆ្នាំ២០២៤ របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ សម្តេចបវរធិបតី នាយករដ្ឋមន្ត្រី បានផ្តល់អនុសាសន៍ចំនួន ១០ចំណុច រួមមាន៖

១.ត្រូវចូលរួមពន្លឿនការធ្វើបរិវត្តកម្មឧស្សាហកម្មកម្ពុជា ពីឧស្សាហកម្មអតិពលកម្ម ទៅជាឧស្សាហកម្មផ្អែកលើ

ជំនាញ និងចំណេះដឹង ដោយតភ្ជាប់ទៅនឹងខ្សែច្រវាក់តម្លៃសកល ធ្វើសមាហរណកម្មទៅក្នុងបណ្តាញផលិតកម្មតំបន់ និងអភិវឌ្ឍន៍កន្សោមផលិតកម្មប្រទាក់ក្រឡា តាមរយៈការលើកកម្ពស់ផលិតភាពឧស្សាហកម្ម ការពង្រឹងសុវត្ថិភាពការងារ និងបរិស្ថាន និងការវាយតម្លៃការទទួលស្គាល់សមត្ថភាពរបស់អង្គភាពវាយតម្លៃអនុលោមភាព ដើម្បីធានាបាននូវសមត្ថភាពប្រកួតប្រជែងរបស់កម្ពុជាទាំងក្នុងតំបន់ និងសកល។ ខ្ញុំសូមគាំទ្រគំនិតផ្តួចផ្តើម របស់ក្រសួង ក្នុងការរៀបចំចងក្រងជាសម្ព័ន្ធ នៃបណ្តាមន្ទីរពិសោធន៍ជាតិ ដើម្បីបំពេញឱ្យគ្នាទៅវិញទៅមក និងបង្កើតបានជាប្រព័ន្ធអេកូឡូស៊ីនៃហេដ្ឋារចនាសម្ព័ន្ធគុណភាពជាតិមួយ (Quality Infrastructure) ដែលនឹងគាំទ្រដល់ធុរកិច្ចនៅកម្ពុជា ហើយក៏សូមលើកទឹកចិត្តឱ្យបណ្តាមន្ទីរពិសោធន៍ជាតិ ចូលរួមសហការ និងលើកកម្ពស់សមត្ថភាពខ្លួន

២.ត្រូវជំរុញការរៀបចំការចុះបញ្ជីតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម CamDX ឱ្យបានរួចរាល់ត្រឹមដំណាច់ឆ្នាំ២០២៤ ព្រមទាំងត្រូវបន្តពង្រឹងសមត្ថភាពមន្ត្រីជំនាញទទួលបន្ទុក និងធ្វើការផ្សព្វផ្សាយឱ្យកាន់តែទូលាយអំពីអត្ថប្រយោជន៍នៃការចុះបញ្ជីតាមប្រព័ន្ធអនឡាញនេះ។ ជាមួយនេះ ត្រូវរៀបចំទិន្នន័យទីតាំងរោងចក្រតាមប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS) ដើម្បីផ្តល់សុក្រឹតភាពក្នុងការគ្រប់គ្រង ព្យាយាមទាញយកផលប្រយោជន៍ពីកម្មសិទ្ធិឧស្សាហកម្ម លើមូលដ្ឋាននៃកិច្ចសហប្រតិបត្តិការភាពជាដៃគូជាក់លាក់ទៅវិញទៅមក និងបង្កើនទំនុកចិត្តក្នុងផលិតកម្ម និងធុរកិច្ច។ លើសពីនេះ ត្រូវពង្រឹងជំនាញផ្នែកបច្ចេកទេសយានយន្ត យានយន្តអគ្គិសនី និងអេឡិចត្រូនិក ក្នុងវិស័យឧស្សាហកម្ម ដោយយកចិត្តទុកដាក់ចំពោះការដំឡើង ការផ្គុំ ឬពាក់កណ្តាលផលិតកម្ម

៣.ត្រូវដឹកនាំ និងជំរុញ ចលនាការបង្កើនផលិតកម្ម និងផលិតភាព នៃឧស្សាហកម្មក្នុងស្រុក ជាពិសេសការផលិតវត្ថុធាតុដើម និងផលិតផលពាក់កណ្តាលសម្រេច ពីធនធានដែលមានក្នុងស្រុក ដើម្បីកសាងខ្សែច្រវាក់ផ្គត់ផ្គង់មួយដែលជួយកាត់បន្ថយការពឹងផ្អែកលើការនាំចូល បង្កើតតម្លៃបន្ថែមខ្ពស់ និងបង្កើនការងារជូនផលិតករ និងអ្នកកែច្នៃក្នុងស្រុកផ្សេងទៀត

៤.ចូលរួមសិក្សាស្រាវជ្រាវអំពីធនធានដែលមានសក្តានុពលសម្រាប់ការអភិវឌ្ឍកសិឧស្សាហកម្ម និងសិក្សាអំពីលទ្ធភាពបង្កើតសួនឧស្សាហកម្មរបស់ជាតិមួយ ដែលអាចសម្រួលគ្រប់នីតិវិធី និងបែបបទគយ ពន្ធដារ បរិស្ថាន ពាណិជ្ជកម្ម សេវាកម្ម ឡូជីស្ទិក និងកិច្ចការទាំងឡាយដែលពាក់ព័ន្ធនឹងការស្នើសុំបង្កើតឧស្សាហកម្មក្នុងតំបន់នេះ។ លើសពីនេះ ត្រូវបន្តជំរុញការបង្កើតបណ្តុំសួនសហគ្រាសធុនតូច និងមធ្យម (SMEs Cluster) ដែលដោះស្រាយបញ្ហានគរូបនីយកម្ម និងទាក់ទាញវិនិយោគិនថ្មីៗ ជាពិសេសក្នុងវិស័យបច្ចេកវិទ្យា ដែលនឹងបង្កើតបានជាប្រព័ន្ធប្រទាក់ក្រឡាគ្នា និងទ្រទ្រង់គ្នាទៅវិញទៅមករវាងសហគ្រាសធុនតូច និងមធ្យម (SMEs) និងវិនិយោគផ្ទាល់ពីបរទេស (FDI)។ ដោយឡែករាជរដ្ឋាភិបាល នឹងពិនិត្យលទ្ធភាពបន្ថែមទៀតលើកញ្ចប់ថវិកាដែលមានស្រាប់ របស់ធនាគារសហគ្រាសធុនតូច និងមធ្យមកម្ពុជា ដើម្បីបង្កលក្ខណៈងាយស្រួលដល់សហគ្រាសធុនតូច និងមធ្យម ក្នុងការទទួលបានកម្ចីទំហំធំ និងរយៈពេលយូរជាងមុន

៥.ត្រូវពន្លឿនការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការផ្ទេរបច្ចេកវិទ្យា សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់ប្រមូលផ្តុំសហគ្រាសធុនតូច និងមធ្យម សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតសហភាពសមាគមសហគ្រាសធុនតូច និងមធ្យមកម្ពុជា និងសេចក្តីព្រាងអនុក្រឹត្យស្តីពីការស្រាវជ្រាវ និងការអភិវឌ្ឍ

៦.ពិនិត្យលទ្ធភាពក្នុងការចូលរួមអនុវត្តការងារ នៅក្នុងគំនិតផ្តួចផ្តើមស្តីពីការបង្កើត "មជ្ឈមណ្ឌល[illegible]ធុរកិច្ច

និងSMEs ក្នុងការចាប់យកឌីជីថល" ដើម្បីចូលរួមបណ្តុះផ្នត់គំនិតសហគ្រិនភាព និងលើកកម្ពស់ការប្រើប្រាស់ និងការចាប់យកបច្ចេកវិទ្យាឌីជីថល ក្នុងអាជីវកម្ម សំដៅបង្កើនប្រសិទ្ធភាពប្រតិបត្តិការធុរកិច្ច និងបង្កើនលទ្ធភាពពង្រីកទីផ្សារទាំងក្នុងតំបន់ និងសកល។ ក្នុងទិសដៅនេះ ត្រូវបន្តដឹកនាំ និងពង្រីកអាណត្តិរបស់សហគ្រិនខ្មែរឱ្យក្លាយជាកាតាលីករ នៃប្រព័ន្ធអេកូឡូស៊ីសហគ្រិនភាព និងជាស្ពានគាំទ្រការបង្កើត និងការអភិវឌ្ឍវិស័យថ្មីៗទៀត

៧.ត្រូវបន្តការយកចិត្តទុកដាក់ខ្ពស់ ក្នុងការពង្រឹងការគ្រប់គ្រង និងការអភិរក្សដីស្រែអំបិល នៅខេត្តកំពត ខេត្តកែប ដែលជាកេរដំណែលពីដូនតា និងជំរុញការផលិតអំបិលដែលរាជរដ្ឋាភិបាលចាត់ទុកជាទំនិញយុទ្ធសាស្ត្រ ឱ្យដើរព្រមគ្នានឹងវិធានការដោះស្រាយបញ្ហាដីស្រែអំបិល ដែលមិនមានសក្តានុពល

៨.ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងភាគីពាក់ព័ន្ធត្រូវសហការជាមួយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ អំពីច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត ដើម្បីឱ្យការផ្គត់ផ្គង់ទឹកស្អាតសម្រេចបានលក្ខខណ្ឌគោលទាំង៤ គឺគុណភាព សុវត្ថិភាព និរន្តរភាព និងថ្លៃសមរម្យ។ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវបន្តពង្រីកវិសាលភាព នៃការផ្គត់ផ្គង់ទឹកស្អាតតាមបំពង់ជូនប្រជាពលរដ្ឋ ទាំងនៅទីប្រជុំជន និងជនបទ ដោយពង្រឹងការលើកទឹកចិត្តដល់ការវិនិយោគផលិតទឹកស្អាតខ្នាតធំ ឬមធ្យម ដើម្បីជួយទ្រទ្រង់តំបន់ដែលប្រឈមនឹងកង្វះប្រភពទឹក ឬខ្វះធនធានហិរញ្ញវត្ថុ។ ទន្ទឹមនេះ ក្រសួងត្រូវបន្តអនុវត្តគោលនយោបាយថ្លៃទឹកស្អាតឱ្យបានម៉ឺងម៉ាត់ តែទន់ភ្លន់ ជាមួយនឹងការគិតគូរដល់ភាពសុខដុមនីយកម្មរវាងអ្នកផលិត និងអ្នកប្រើប្រាស់ហើយត្រូវផ្តល់អាទិភាពដល់ប្រជាជនក្រីក្រ និងមានជីវភាពខ្សត់ខ្សោយរួមទាំងបងប្អូនកម្មករ សិស្ស និងនិស្សិត ដែលស្នាក់នៅតាមបន្ទប់ជួល ក្នុងការទទួលបានថ្លៃទឹកស្អាតមួយសមរម្យ។ លើសពីនេះ ត្រូវជំរុញការរៀបចំបង្កើត និយតករទឹកស្អាត ដើម្បីពង្រឹងនិយតកម្ម និងអាជ្ញាបណ្ណ និងពន្លឿនការរៀបចំអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មូលនិធិអភិវឌ្ឍន៍វិស័យទឹកស្អាត ដើម្បីផ្តល់លទ្ធភាពបន្ថែមទៀតដល់ការជួយអន្តរាគមន៍ដល់ការផ្គត់ផ្គង់ទឹកស្អាត នៅកន្លែងដែលជួបការលំបាកខ្លាំង ឬជួយសម្រួល និងគាំទ្រដល់ប្រជាជនដែលស្ថិតក្នុងចំណាត់ថ្នាក់ប្រភេទក្រ១ ក្រ២

៩.បន្តជំរុញការអភិវឌ្ឍ និងការអនុម័តស្តង់ដាថ្មីៗបន្ថែមទៀត លើមុខទំនិញយុទ្ធសាស្ត សម្រាប់ការនាំចេញទៅកាន់ទីផ្សារអន្តរជាតិ ជាពិសេសទីផ្សារដែលជាដៃគូពាណិជ្ជកម្មសេរីជាមួយកម្ពុជា។ ទន្ទឹមនេះ ត្រូវពង្រឹងប្រព័ន្ធចេញវិញ្ញាបនបត្រ និងអធិការកិច្ច ឱ្យបានត្រឹមត្រូវ ស្របតាមស្តង់ដាអន្តរជាតិ ដើម្បីការពារពីការបង្កគ្រោះមហន្តរាយដល់សុវត្ថិភាព សុខភាពរបស់មនុស្ស សត្វ និងរុក្ខជាតិ ទ្រព្យសម្បត្តិ សន្តិសុខសង្គម និងបរិស្ថាន

១០.ត្រូវសិក្សារៀបចំក្របខ័ណ្ឌអភិវឌ្ឍន៍មូលធនមនុស្សផ្នែកបច្ចេកវិទ្យា សម្រាប់រយៈពេលមធ្យម និងវែង ដោយពិនិត្យបន្ថែមលើការជំរុញការបង្កើតប្រព័ន្ធអេកូវិទ្យារវាងយុវជននវានុវត្តន៍ នវធុរកិច្ច ក្នុងវិស័យបច្ចេកវិទ្យា និងសហគ្រាសធុនតូច និងមធ្យម សំដៅពង្រឹងផលិតភាព ពង្រីកទីផ្សារ បង្កើនប្រសិទ្ធភាព និងពង្រឹងសមត្ថភាពធនធានមនុស្ស ព្រមទាំងលើកកម្ពស់ការចងក្រង និងការទាក់ទាញប្រមូលមូលធន មនុស្សផ្នែកបច្ចេកវិទ្យា ទាំងក្នុងស្រុក និងក្រៅស្រុក។ ទន្ទឹមនេះ ត្រូវជំរុញការរៀបចំគោលនយោបាយ សម្រាប់បង្កើតបរិស្ថានអំណោយផល និងជំរុញការស្រាវជ្រាវ និងអភិវឌ្ឍន៍នៅកម្ពុជា ព្រមទាំងបន្តតម្រង់ទិសចំពោះការអនុវត្ត ផែនទីបង្ហាញផ្លូវវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍កម្ពុជា ឆ្នាំ២០៣០ និង របៀបវារៈស្រាវជ្រាវជាតិ ហើយបន្តជំរុញការរៀបចំសួនវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (STI Park) សារមន្ទីរវិទ្យាសាស្ត្រ (Science Museum) ក៏ដូចជាការរៀបចំ និងការ[illegible]កម្ពុជា

ទៅមជ្ឈមណ្ឌលផ្ទេរបច្ចេកវិទ្យាអាស៊ាន ( ASEANTechnology Transfer Hub )

១១.បន្តចូលរួមកាន់តែសកម្មក្នុងការងារកែទម្រង់របស់រាជរដ្ឋាភិបាល ជាពិសេសរដ្ឋាភិបាលឌីជីថល ការអភិវឌ្ឍធនធានមនុស្ស និងការលើកកម្ពស់សមត្ថភាពស្ថាប័ន ដោយឈរលើគោលការណ៍គុណាធិបតេយ្យ តាមរយៈការជំរុញការផ្តល់សេវាសាធារណៈតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន និងតាមយន្តការច្រកចេញ-ចូលតែមួយ ទាំងនៅក្រសួង និងមន្ទីររាជធានី ខេត្ត សំដៅកែលម្អការផ្តល់សេវាសាធារណៈ ជូនធុរជន និងប្រជាពលរដ្ឋឱ្យកាន់តែមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងខិតជិតប្រជាជន ស្របតាមអភិក្រម "ធ្វើឱ្យលឿន ធ្វើឱ្យបាន និង ធ្វើឱ្យតម្លាភាព"

១២.ពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងការប្រមូលចំណូលថវិកាជាតិ ពីការផ្តល់សេវាសាធារណៈនានាក្នុងដែនសមត្ថកិច្ចរបស់ក្រសួង ស្របតាមគោលនយោបាយ និងបទប្បញ្ញត្តិជាធរមាន ពិសេសយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម និង កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

១៣.ពន្លឿនការរៀបចំផែនការសកម្មភាពលម្អិត និងសូចនាករគន្លឹះ នៃការអនុវត្តយុទ្ធសាស្ត្រជាតិស្តីអំពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្នាំ២០២៣-២០២៨ ដោយក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវផ្តល់កិច្ចសហប្រតិបត្តិការឱ្យបានសកម្មបំផុតជាមួយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នៅក្នុងការអនុវត្តកិច្ចការដ៏សំខាន់នេះ ជាពិសេសសូមក្រសួង ស្ថាប័នពាក់ព័ន្ធផ្តល់នូវធាតុចូលរបស់ខ្លួនដល់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ឱ្យបានទាន់ពេល និងសូមត្រៀមអនុវត្តសកម្មភាពរបស់ខ្លួនឱ្យបានប្រសិទ្ធខ្ពស់បំផុត។

- ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៤ នៅសាលមហោស្រព និងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ ប្រកាសទទួលស្គាល់ជ័យលាភី អង្គភាពផ្តល់សេវាសាធារណៈគំរូ អនុវិទ្យាល័យ សាលាបឋមសិក្សា និងមណ្ឌលសុខភាព សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី បានផ្តល់អនុសាសន៍ចំនួន ៥ចំណុចរួមមាន៖

១.ដំណើរការ នៃការវាយតម្លៃ និងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូ ក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល មានទំនាក់ទំនងផ្ទាល់ជាមួយការជំរុញវិធានការគន្លឹះ ក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ វិធានការគន្លឹះក្នុងវិស័យអប់រំ និងវិធានការគន្លឹះក្នុងវិស័យសុខាភិបាល។ ក្នុងន័យនេះ ក្រសួងមុខងារសាធារណៈ គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវពិនិត្យ និងរៀបចំផែនការសកម្មភាព ដែលប្រទាក់ក្រឡា និងគាំទ្រគ្នាមិនត្រឹមតែក្នុងគោលបំណងវាយតម្លៃស្វែងរកអង្គភាពគំរូប៉ុណ្ណោះទេ ប៉ុន្តែត្រូវផ្តល់នូវការគាំទ្រឱ្យបានពេញលេញដល់គ្រឹះស្ថានអប់រំ និងអង្គភាពសុខាភិបាលនៅមូលដ្ឋានទាំងអស់ ឱ្យមានសមត្ថភាពផ្តល់សេវាសមស្រប និងប្រកបដោយគុណភាពដល់ប្រជាពលរដ្ឋ

២.គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវបន្តបញ្ជ្រាបការយល់ដឹងឱ្យបានទូលំទូលាយ និងការទទួលយកលក្ខណៈវិនិច្ឆ័យគោលទាំង៨ លក្ខណៈវិនិច្ឆ័យរង និងលក្ខណៈវិនិច្ឆ័យលម្អិត ដែលត្រូវបានប្រើប្រាស់ជាមូលដ្ឋាន នៃការវាយតម្លៃ ដើម្បីអង្គភាពអាចប្រើប្រាស់ ប្រកបដោយប្រសិទ្ធភាពក្នុងការកំណត់អំពីភាពខ្លាំង និងភាពខ្សោយរបស់សាលាមត្តេយ្យសិក្សា សាលាបឋមសិក្សា អនុវិទ្យាល័យ វិទ្យាល័យ មណ្ឌលសុខភាព មន្ទីរពេទ្យបង្អែកដែលផ្តល់សេវាសំណុំសកម្មភាពកម្រិត១ កម្រិត២ និងកម្រិត៣ [illegible] ជាមូលដ្ឋានសម្រាប់ដាក់ចេញនូវវិធានការសមស្របដែលល្អសម្រាប់អង្គភាពជាបន្ត

៣.គណៈកម្មការវាយតម្លៃអង្គភាព ផ្តល់សេវាសាធារណៈថ្នាក់ជាតិ ត្រូវសិក្សាពីលទ្ធភាពក្នុងការ [illegible]

នៃការអនុវត្តការវាយតម្លៃអង្គភាព ផ្តល់សេវាសាធារណៈទៅអង្គភាព ឬស្ថាប័នផ្សេងៗទៀត ទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ក្រោមជាតិ ដើម្បីជំរុញឱ្យបានខ្លាំងក្លា ចលនា នៃប្រឡងប្រណាំងការផ្តល់សេវាសាធារណៈ និងភាពជាគំរូ នៃអង្គភាពផ្តល់សេវាសាធារណៈ

៤.គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ ត្រូវធ្វើការផ្សព្វផ្សាយ និងជំរុញចលនាប្រកួតប្រជែងការផ្តល់សេវាសាធារណៈ ទៅដល់គ្រប់សាលារៀន មណ្ឌលសុខភាព និងមន្ទីរពេទ្យនៅមូលដ្ឋាន ឱ្យបានទូលំទូលាយ រៀបចំឱ្យមានករណីសិក្សា និងចងក្រងនូវបទពិសោធល្អៗស្តីពីឧត្តមានុភាពនិង នវានុវត្តន៍នៃសាលារៀន និងមន្ទីរពេទ្យដែលទទួលបានជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូ ព្រមទាំងរៀបចំឱ្យមានទស្សនកិច្ចសិក្សា និងចែករំលែកបទពិសោធន៍ល្អៗទាំងក្នុង និងក្រៅប្រទេស

៥.គ្រប់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបន្តយកចិត្តទុកដាក់ក្នុងការជំរុញ ពង្រឹង និងកែប្រែឥរិយាបទរបស់មន្ត្រីរាជការក្នុងការផ្តល់សេវាសាធារណៈ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ មានឆន្ទៈម្ចាស់ការ ភក្ដីភាព មនសិការវិជ្ជាជីវៈ និងវប្បធម៌សេវាសាធារណៈ ព្រមទាំងត្រូវធ្វើការត្រួតពិនិត្យឡើងវិញទៅលើរចនាសម្ព័ន្ធ មុខងារ តួនាទី និងភារកិច្ចរបស់ខ្លួន ជាពិសេសត្រូវយកចិត្តទុកដាក់ក្នុងការពិនិត្យនិង ធ្វើបច្ចុប្បន្នភាពទៅលើគោលការណ៍ បែបបទ និងនីតិវិធី ព្រមទាំងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធទៅនឹងការផ្តល់សេវាសាធារណៈ ទៅតាមករណីចាំបាច់ ដើម្បីពង្រឹងការគ្រប់គ្រង ការកែលម្អ និងពង្រឹងគុណភាព និងប្រសិទ្ធភាព នៃការផ្តល់សេវាសាធារណៈ ជូនប្រជាពលរដ្ឋ ឱ្យកាន់តែល្អប្រសើរឡើង និងប្រកបដោយប្រសិទ្ធភាពខ្ពស់ ដោយឈរលើគោលការណ៍តម្លាភាព គណនេយ្យភាព និងសុចរិតភាព។ ជាមួយគ្នានេះ សម្តេច សូមចូលរួមអបអរសាទរ ចំពោះអង្គភាពដែលទទួលបានជ័យលាភី ជាអង្គភាព ផ្តល់សេវាសាធារណៈគំរូ និងសូមលើកទឹកចិត្ត ចំពោះអង្គភាពដែលមិនទាន់បានទទួលជ័យលាភី ឱ្យបន្តនូវកិច្ចខិតខំ ប្រឹងប្រែង ដើម្បីកែលម្អ ពង្រឹង និងលើកកម្ពស់គុណភាព និងប្រសិទ្ធភាព នៃការផ្តល់សេវាសាធារណៈជូនប្រជាជន ក្នុងមូលដ្ឋានរបស់ខ្លួនឱ្យកាន់តែល្អប្រសើរឡើង។

- ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៤ នៅវិមានសន្តិភាព ក្នុងពិធីប្រគល់ប្រាក់រង្វាន់លើកទឹកចិត្តរបស់រាជរដ្ឋាភិបាល ជូនជ័យលាភីមេដាយមាស ប្រាក់ និងមេដាយសំរឹទ្ធិគ្រូបង្វឹក និងគ្រូជំនួយពីការប្រកួតកីឡាជ្រើសរើសជើងឯកពិភពលោក ជើងឯកអាស៊ីអាគ្នេយ៍ ជើងឯកអាស៊ី និងការប្រកួតជ្រើសរើសជើងឯក សាកលវិទ្យាល័យអាស៊ាន សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី បានផ្តល់អនុសាសន៍ចំនួន៥ចំណុចរួមមាន៖

១.ក្រសួងអប់រំ យុវជន និងកីឡា ដោយសហការជាមួយ សហព័ន្ធកីឡាជាតិត្រូវរៀបចំយន្តការគាំទ្របណ្តុះបណ្តាល និងលើកទឹកចិត្តដល់កីឡាករ និងកីឡាការិនីនៅគ្រប់កម្រិត ដើម្បីពង្រឹងសមត្ថភាពក្នុងការប្រកួតប្រជែង ឱ្យកាន់តែមានគុណភាពខ្ពស់ សម្រាប់លើកស្ទួយកីឡាជាតិ ទៅក្នុងតំបន់ និងសកលលោក

២.ក្រសួងអប់រំ យុវជន និងកីឡា និងសហព័ន្ធកីឡាជាតិ ត្រូវបង្កើនការយកចិត្តទុកដាក់ សម្រិតសម្រាំង និងបណ្តុះបណ្តាល ធនធានយុវជន ដែលមានទេពកោសល្យក្នុងផ្នែកកីឡា ដើម្បីលើកកម្ពស់គុណភាព និងសមត្ថភាព កីឡា សម្រាប់ការប្រកួតក្នុងព្រឹត្តិការណ៍ថ្នាក់តំបន់ និងអន្តរជាតិ នាពេលអនាគត

៣.ខ្ញុំសូមលើកទឹកចិត្តឱ្យគ្រូបង្វឹក បងប្អូនកីឡាករ កីឡាការិនីទាំងអស់ ខិតខំហ្វឹកហាត់កីឡា[illegible] របស់ខ្លួនជាប្រចាំឱ្យជាប់មិនដាច់ពីព្រោះ ការកសាងសមត្ថភាពកីឡា ត្រូវការរយៈពេលយូរ និងត្រូវ[illegible]

ស្រេចជាមុន ក្នុងការចូលរួមការប្រកួតប្រជែងនានា ទាំងកម្រិតជាតិ តំបន់ និងសកល

៤.គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា និងសហព័ន្ធកីឡាជាតិ ត្រូវបង្កើនកិច្ចសហការ ទាំងបច្ចេកទេស និងបទពិសោធជាមួយក្រុមប្រឹក្សាអូឡាំពិកអាស៊ី គណៈកម្មាធិការជាតិអូឡាំពិក នៃប្រទេសសមាជិក ក្រុមប្រឹក្សាសហព័ន្ធកីឡាអាស៊ីអាគ្នេយ៍ ក្រុមប្រឹក្សាសហព័ន្ធកីឡាអាស៊ានប៉ារ៉ា និងស្ថាប័នកីឡាអន្តរជាតិ ក្នុងការបណ្តុះបណ្តាល និងការអភិវឌ្ឍកម្រិតបច្ចេកទេសកីឡា ដល់កីឡាករ និង កីឡាការិនីកម្ពុជា ឱ្យបានដល់កម្រិតខ្ពស់ដែលអាចធ្វើទៅបាន ដើម្បីឱ្យកីឡាករ និងកីឡាការិនីកម្ពុជា អាចចូលរួមកាន់តែទូលំទូលាយប្រកបដោយសមត្ថភាពកាន់តែប្រសើរ ក្នុងព្រឹត្តិការណ៍អន្តរជាតិនានានៅថ្ងៃអនាគត។

-ថ្ងៃទី៧ ខែមីនា ឆ្នាំ២០២៤ នៅសាលមហោស្រព និងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ អបអរសាទរ "ទិវាវប្បធម៌ជាតិ៣មីនា" លើកទី២៦ ឆ្នាំ២០២៤ សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី បានផ្តល់អនុសាសន៍ចំនួន ៧ចំណុចរួមមាន៖

១.ការផលិត និងការច្នៃប្រឌិតផលិតផលសិល្បៈនៅមានកម្រិតកំណត់ ជាមួយថ្លៃខ្ពស់ដែលការណ៍នេះធ្វើឱ្យផលិតផលរបស់យើងពុំមានភាពប្រកួតប្រជែង។ សម្តេច ស្នើឱ្យក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សិក្សាលើវិធានការលើកទឹកចិត្តចាំបាច់នានា ដើម្បីជំរុញការផលិត និងការច្នៃប្រឌិតផលិតផលសិល្បៈ ឱ្យមានភាពទាក់ទាញ និងភាពប្រកួតប្រជែងខ្ពស់

២.ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងស្ថាប័នពាក់ព័ន្ធ ត្រូវពង្រឹងការងារពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ទប់ស្កាត់ការលួចចម្លងស្នាដៃ ធ្វើវិសោធនកម្មក្របខ័ណ្ឌគតិយុត្តពាក់ព័ន្ធ ឱ្យត្រូវនឹងស្ថានភាពជាក់ស្តែងនៃបច្ចេកវិទ្យា និងកិច្ចសហការអន្តរជាតិ

៣.ដើម្បីពង្រឹងកិច្ចសហការ និងរៀនសូត្រពីបទពិសោធនានាទាំងក្នុង និងក្រៅប្រទេស ដែលទទួលបានជោគជ័យ លើវិស័យឧស្សាហកម្មវប្បធម៌ និងច្នៃប្រឌិត សម្តេច សូមលើកទឹកចិត្តឱ្យក្រសួងវប្បធម៌ វិចិត្រសិល្បៈ និងវិស័យឯកជន ត្រូវបញ្ជូនមន្ត្រី សិល្បករ សិល្បការិនី សិប្បករទៅសិក្សាដកពិសោធន៍ និងសហការជាមួយដៃគូក្នុងការរៀបចំវគ្គបណ្តុះបណ្តាលជំនាញក្នុងស្រុក។ ជាមួយគ្នានេះ គួរពង្រឹងបន្ថែមនូវកិច្ចការស្រាវជ្រាវ បោះពុម្ពផ្សាយ ព្រមទាំងប្រើប្រាស់នូវបច្ចេកទេសវិទ្យាថ្មីៗ ដើម្បីធ្វើបរមូបនីយកម្មវិស័យនេះ

៤.ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ ត្រូវបន្តយកចិត្តទុកដាក់ថែរក្សាការពារ និងបង្ក្រាបរាល់បទល្មើសឱ្យបានទាន់ពេល ប្រកបដោយប្រសិទ្ធភាពនៅតាមទីតាំងតំបន់ប្រាសាទ រមណីយដ្ឋានប្រវត្តិសាស្ត្រ វត្តអារាម សំណង់ប្រវត្តិសាស្ត្រ និងសំណង់ ដែលមានអាយុកាលរាប់រយឆ្នាំ នៅតាមមូលដ្ឋាននៅទូទាំងប្រទេស។ ត្រូវបន្តរួមគ្នាធ្វើបញ្ជីសារពើភ័ណ្ឌ គ្រប់ទីតាំងនៃបេតិកភណ្ឌរូបិយទាំងនោះ ឱ្យបានសព្វគ្រប់ ដើម្បីចៀសវាងការរំលោភបំពាន ហើយត្រូវបន្តទាមទារយកមកវិញនូវបដិមានានារបស់ជាតិ ដែលត្រូវបានបាត់បង់កន្លងមកក្នុងអំឡុងសម័យសង្គ្រាម

៥.ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវបន្តកិច្ចសហការជាមួយក្រសួងទេសចរណ៍ ដើម្បីផ្សព្វផ្សាយ[illegible] ទេសចរណ៍វប្បធម៌ជាតិ ឱ្យបានកាន់តែទូលំទូលាយក្នុងគ្រប់រូបភាព សម្រាប់ទេសចរណ៍ជាតិ និងអន្តរជាតិ សំដៅ លើកតម្លៃវប្បធម៌ជាតិ រួមចំណែកជំរុញកំណើន សេដ្ឋកិច្ចជាតិ និងកាត់បន្ថយភាពក្រីក្រ ៕

៦.សម្តេច សូមគាំទ្រចំពោះកិច្ចសហការរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងក្រសួងព័ត៌មាន ដែលបានធ្វើឱ្យវិស័យភាពយន្តភាគខ្មែរ បាននិងកំពុងមានភាពរីកចម្រើនគួរឱ្យកត់សម្គាល់ តាមរយៈការកំណត់ម៉ោងសម្រាប់ធ្វើការចាក់ផ្សាយភាពយន្តភាគខ្មែរ។ ជាមួយគ្នានេះ អាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ ត្រូវសហការជួយសម្រួលផ្តល់ទីតាំងក្នុងដែនដីរបស់ខ្លួន ដើម្បីសម្រួលដំណើរការនៃការថត និងផលិតខ្សែភាពយន្ត

៧.ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវបន្តកិច្ចសហការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បំផុសសកម្មភាពគ្រប់ស្ថានទូត និងស្ថានកុងស៊ុលកម្ពុជាប្រចាំនៅបរទេស រៀបចំព្រឹត្តិការណ៍វប្បធម៌ខ្មែរឱ្យបានទៀងទាត់ជារៀងរាល់ឆ្នាំ ដើម្បីផ្សព្វផ្សាយវប្បធម៌ជាតិ ជាមួយនឹងការពង្រឹងនយោបាយវប្បធម៌ការទូត ហើយត្រូវបំផុសឱ្យសហគមន៍ខ្មែរនៅបរទេស ចូលរួមរៀបចំកម្មវិធីទិវាវប្បធម៌ជាតិឱ្យបានអធិកអធម និងទូលំទូលាយ។

- ថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៤ នៅសាលមហោស្រព និងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ បើកវេទិការដ្ឋាភិបាលឌីជីថល លើកទី១ ដែលរៀបចំដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី បានលើកឡើងថា វេទិកានេះនឹងមានការរៀបចំនូវកិច្ចពិភាក្សាផងដែរ ដូច្នេះ ដើម្បីជាធាតុចូលបន្ថែមដល់កិច្ចពិភាក្សា សម្តេច សូមស្នើឱ្យអង្គវេទិកា ផ្តោតការយកចិត្តទុកដាក់លើចំណុចជាគន្លឹះចំនួន៥ ដូចខាងក្រោម៖

១.ការឆ្លើយតបនឹងការវិវត្តយ៉ាងឆាប់រហ័ស នៃបច្ចេកវិទ្យាឌីជីថលថ្មីៗ ជាពិសេសបច្ចេកវិទ្យាបញ្ញា សិប្បនិម្មិត (Generative AI) ដែលម្យ៉ាងនាំឱ្យមានការជំរុញនវានុវត្តន៍ និងបង្កើនផលិតភាព និងម្យ៉ាងទៀត នាំឱ្យមានកំណើននៃលំហូរទិន្នន័យឯកជនប្រជាពលរដ្ឋ និងការប្រើប្រាស់ ទិន្នន័យទាំងនោះឆ្លងកាត់ព្រំដែន ដែលបង្កជាការព្រួយបារម្ភដល់ការយកប្រៀបផ្នែកពាណិជ្ជកម្ម ការបំពានឯកជនភាពរបស់ប្រជាពលរដ្ឋ និងការគំរាមកំហែងសន្តិសុខសាយប័រជាដើម

២.ការសម្រួចបន្ថែមលើវិធានការគោលនយោបាយពាក់ព័ន្ធ និងការអនុវត្តកម្មវិធីបរិវត្តកម្មរដ្ឋាភិបាលឌីជីថល ដោយប្រើប្រាស់អភិក្រម "រដ្ឋាភិបាលទាំងមូល" (Open Whole-of-Government Approach) និងការបើកចំហសម្រាប់ការចូលរួមពីគ្រប់តួអង្គ

៣.ការធ្វើសុខដុមនីយកម្មលើគោលនយោបាយ បទប្បញ្ញត្តិ ស្តង់ដារវាងប្រទេសក្នុងតំបន់ ដើម្បីសម្រួលដល់ការធ្វើពាណិជ្ជកម្ម និងសេវាឌីជីថល ក៏ដូចជាការពង្រឹងនូវការចែករំលែកចំណេះដឹង និងបទពិសោធន៍

៤.ការកំណត់ចលករគន្លឹះ ជំរុញការកសាងមូលធនមនុស្សឌីជីថល និងវិធីសាស្ត្រជំរុញសន្ទុះ នៃការបង្កើនសមត្ថភាពចាប់យក និងប្រើប្រាស់បច្ចេកវិទ្យាឌីជីថលរបស់ប្រជាពលរដ្ឋ

៥.ការពង្រឹងយន្តការតំបន់ ដើម្បីឆ្លើយតបនឹងបញ្ហាសន្តិសុខសាយប័រ និងបទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យាជាអាទិ៍៖ ការឆបោកតាមប្រព័ន្ធអនឡាញ (Online scam) និងព័ត៌មានក្លែងក្លាយ។

**៣.៧.ការងារទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវ**

ក.ទទួលពាក្យបណ្តឹងចំនួន១៥បណ្តឹង (អគ្គនាយកដ្ឋានអធិការកិច្ចចំនួន៩បណ្តឹង និងមន្ទីររាជធានី ខេត្តចំនួន៦បណ្តឹង)

១.ឈ្មោះ គុន បាន នៅភូមិព្រៃកែស ឃុំដំណាក់តន្ទ្រួតជើង ស្រុកកំពង់ត្រាច ខេត្តកំពត និងឈ្មោះ អ៊ុំ... នៅភូមិពងទឹក ឃុំព្រៃរំដេង ស្រុកមេសាង ខេត្តព្រៃវែង ស្នើសុំជួយអន្តរាគមន៍ចាត់ក្រុមការងារចុះអង្កេតស្រាវជ្រាវ និង

ធ្វើអធិការកិច្ច ដីទំហំ១៤ហិកតា ស្ថិតនៅភូមិឬទ្ធី២ ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ដែលមានប្រជាពលរដ្ឋចំនួន២៥គ្រួសារ ស្នើសុំចុះបញ្ជីជាកម្មសិទ្ធិមិនបាន ដោយសារថាមានការពាក់ព័ន្ធជាមួយឈ្មោះ ឡុង សុខន

២.ឈ្មោះ ទន់ គីមហួយ មេធាវី តំណាងឱ្យទណ្ឌិតចំនួន១៤នាក់ កំពុងជាប់ឃុំនៅមណ្ឌលកែប្រែទី១ ព្រៃស (ម១) ប្ដឹងមន្ត្រីឈ្មោះ លឹម ប៊ុនឃៀន អត្តលេខ ០២១១ មានតួនាទីជាអនុប្រធានមណ្ឌល (ម១) ព្រៃស បានយកឈ្មោះថ្នាក់ដឹកនាំ ជាអគ្គនាយកដ្ឋានពន្ធនាគារ នៃក្រសួងមហាផ្ទៃ ប្រើប្រាស់ដើម្បីគម្រាមទារប្រាក់ប្រចាំខែ គម្រាមប្ដូរពួកគាត់ទៅគុកនៅខេត្តឆ្ងាយ និងមិនឱ្យជួបបងប្អូនដែលត្រូវមកសួរសុខទុក្ខ

៣.ឈ្មោះ ឈុន ចាន់ណាល់ នៅភូមិកាតាយ ឃុំសូយោង ស្រុកបារាយ ខេត្តកំពង់ធំ ជាតំណាងប្រជាពលរដ្ឋចំនួន៨គ្រួសារ ស្នើសុំក្រសួងចុះធ្វើអធិការកិច្ច និងជួយពន្លឿនការដោះស្រាយបណ្ដឹងចំនួន៣ ពាក់ព័ន្ធករណីវិវាទដីធ្លីទីបញ្ចុះសព ស្ថិតនៅតំបន់ទួលតាហង្ស (ទួលតាផាត់) ភូមិឫស្សីល៍ ឃុំស្វាយភ្លើង ស្រុកតាំងគោក (អតីតស្រុកបារាយណ៍) ខេត្តកំពង់ធំ

៤.ដីការបញ្ជូនលេខ ២០៦ ខន/០២៤ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៤ របស់ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី ករណីលិខិតចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២៤ របស់ឈ្មោះ ហ៊ន សៈមុន្នី ហៅ ហ៊ននី នៅភូមិព្រែកស្វាយ សង្កាត់កោះរ៉ុង ក្រុងកោះរ៉ុង ខេត្តព្រះសីហនុ គោរពស្នើសុំ សម្ដេចមហាបវរធិបតី នាយករដ្ឋមន្ត្រី ជួយស្រាវជ្រាវប្រវត្តិនៃការកាន់កាប់ដីមុន និងក្រោយពេលដាក់ដីជាឧទ្យានជាតិរាម និងអ្នកដែលបានកាន់កាប់ដី អាស្រ័យផលយូរឆ្នាំលើដីទំហំ២៣២,៩៩៥ម៉ែត្រការ៉េ ស្ថិតនៅទល់មុខព្រលានយន្តហោះអន្តរជាតិរាម ខេត្តព្រះសីហនុ លើលិខិត (របាយការណ៍) លេខ៣៥៤៧ សជណ.បស្ក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៣ របស់ក្រសួងបរិស្ថាន ដែលពុំបានដាក់បញ្ចូលនូវឯកសារដីរបស់គាត់មួយចំនួនក្នុងឯកសាររបាយការណ៍

៥.ឈ្មោះ ជា សុខហេង នៅភូមិ៧ សង្កាត់ទឹកល្អក់ ខណ្ឌទួលគោក រាជធានីភ្នំពេញ ស្នើសុំក្រសួងអធិការកិច្ចជួយអន្តរាគមន៍ករណីបុគ្គល៥រូប ឈ្មោះ សុខ រ៉ាថន ឈ្មោះ កែវ ចាន់ ឈ្មោះ សុខ ឡី ឈ្មោះ ឌី ជុំ ដែលបានប្រើប្រាស់អំណាចរំលោភយកដីរបស់គាត់ទំហំ១៥ហិកតា នៅភូមិពូធឿង ឃុំបិទត្រាំង ស្រុកព្រៃនប់ (ក្រុងព្រះសីហនុ) ខេត្តព្រះសីហនុ

៦.ពាក្យបណ្ដឹងឈ្មោះ កៀង ផល្លាកូល និងឈ្មោះ កៀង វីរៈកូល នៅផ្ទះលេខ១E0 ផ្លូវ២៥៧ សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ប្ដឹងឈ្មោះ អ៊ុក សុផាន់ណារី ថាបានរំលោភកាន់កាប់ទ្រព្យសម្បត្តិរបស់គាត់មានដីទំហំ៥៧៦ម៉ែត្រការ៉េ និងផ្ទះលេខ១E0 និងE1 (១០.៤០ម៉ែត្រx១៨.៣០ម៉ែត្រ) មានទីតាំងដូចខាងលើ

៧.ពាក្យស្នើសុំចុះអង្កេតស្រាវជ្រាវករណីភាពមិនប្រក្រតី គម្រោងអភិវឌ្ឍន៍ទេសចរណ៍ផ្សារភ្ជាប់នឹងធម្មជាតិខ្នាតតូចរបស់លោកស្រី ស៊ីង សុខអាង ក្នុងការអនុវត្ត ដែលស្ថិតនៅចំណុចជើងភ្នំ១,៥០០ ក្នុងភូមិដីក្រហម ឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់

៨.ឈ្មោះ មាន សុវណ្ណា ឈ្មោះ សាំង គឹមឡេង និងឈ្មោះ ខូវ សេងគង់ ជាមន្ត្រីគម្រោងក្នុងនាយកដ្ឋានប្រែប្រួលអាកាសធាតុ នៃអគ្គនាយកដ្ឋានគោលនយោបាយ និងយុទ្ធសាស្ត្រ ក្រសួងបរិស្ថាន ស្នើសុំជួយអន្តរាគមន៍ករណីឯកឧត្តម ស៊ុំ ធី អគ្គនាយកស្ដីទី ឯកឧត្តម ហេង ចាន់ធឿន អគ្គនាយករង និងលោកស្រី [illegible] វិចិត្រា អនុប្រធាននាយកដ្ឋាន បង្កភាពមិនប្រក្រតី ក្នុងការអនុវត្តការងារខុសពីវិជ្ជាជីវៈ ផ្ទុយពីអ្វីដែល[illegible]

ពិសេសបានគម្រាម បំភ័យដល់ពួកគាត់ឱ្យលាឈប់ពីការងារ និងបញ្ឈប់ពួកគាត់ពីការងារដោយមិនបានបញ្ជាក់ពីមូលហេតុឱ្យបានច្បាស់លាស់ (ទទួលតាមអនឡាញ)

៩.ឈ្មោះ ង៉ែត ថន នៅភូមិជ្រោយអំពិល សង្កាត់ក្បាលកោះ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ស្នើសុំក្រសួងជួយពិនិត្យដោះស្រាយដើម្បីឱ្យគាត់បានចុះបញ្ជីជាលក្ខណៈប្រព័ន្ធនូវដីលំនៅដ្ឋានទំហំ៨ម៉ែត្រx២៥ម៉ែត្រស្ថិតនៅភូមិជ្រោយអំពិល សង្កាត់ក្បាលកោះ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ដែលគាត់បានរស់នៅតាំងពីឆ្នាំ១៩៨៥មកម្ល៉េះ (ទទួលតាមអនឡាញ)

១០.ឈ្មោះ ហេន ស៊ូនី នៅភូមិច្រប់ ឃុំក្បាលរមាស ស្រុកសេសាន ខេត្តស្ទឹងត្រែង ប្ដឹងអាជ្ញាធរ និងសមត្ថកិច្ចភូមិ ឃុំ ពីបទឃុបឃិតគ្នារំលោភយកដីរបស់គាត់ ស្ថិតនៅភូមិច្រប់ ឃុំក្បាលរមាស ស្រុកសេសាន ខេត្តស្ទឹងត្រែង

១១.ឈ្មោះ សន ម៉ុន នៅភូមិថ្មលាត សង្កាត់ស្រះឫស្សី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង តំណាងឱ្យប្រជាពលរដ្ឋចំនួន៥គ្រួសារ ស្នើសុំជួយអន្តរាគមន៍ករណីអាជ្ញាធរសុរិយោដីមិនចេញបណ្ណកម្មសិទ្ធិដីចំនួន៦ទីតាំង ស្ថិតនៅភូមិស្រែពោធិ៍ សង្កាត់ស្រះឫស្សី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង

១២.ឈ្មោះ អឹម គន្ធា និងឈ្មោះ ណុប ភ័ក្រសាវិន នៅភូមិ៣ សង្កាត់កណ្ដាលជុំ ឈ្មោះ អ៊ុត វុទ្ធី និងឈ្មោះ អៀង ស្រីតូច នៅភូមិកាប់ទូក សង្កាត់កណ្ដាលជុំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ និងឈ្មោះ យ៉ុង ភារិន នៅភូមិ៣ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ តំណាងឱ្យប្រជាពលរដ្ឋ ប្ដឹងឈ្មោះ ឈួន សុខលី នៅភូមិក្រាំងខ្ចាយ ឃុំតាំងស្យា ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ (ជាម្ចាស់ដីដើម) និងឈ្មោះ ទិត តុន នៅភូមិអង្គសេរី សង្កាត់រការធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ (ប្រធានក្រុមហ៊ុនពុះដីឡូតិ៍) មិនព្រមប្រគល់ដីចំនួន៦២ឡូតិ៍ជូនប្រជាពលរដ្ឋចំនួន៣០គ្រួសារ ដែលបានបង់ប្រាក់ជូនក្រុមហ៊ុនពុះដីឡូតិ៍បានជាង៩៣% នៃថ្លៃទិញ-លក់ដីឡូតិ៍រួចហើយ ស្ថិតនៅភូមិកាប់ទូក សង្កាត់កណ្ដាលជុំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ

១៣.ឈ្មោះ វ៉ាត វ៉ាន់ នៅភូមិអំពិលដាំទឹក ឃុំវិហារហ្លួង ស្រុកពញាឮ ខេត្តកណ្ដាល ប្ដឹងសុំឱ្យមន្ត្រីសុរិយោដីស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ចុះវាយតម្លៃ និងវាស់វែងដីមួយកន្លែងទំហំ៨,០០០ម៉ែត្រការ៉េ ស្ថិតនៅភូមិត្រពាំងចំបក់ ឃុំលង្វែក ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ដែលបានកាន់កាប់ និងអាស្រ័យផលតាំងពីឆ្នាំ១៩៨០ រហូតដល់បច្ចុប្បន្ន

១៤.ឈ្មោះ ឡាយ សុទ្ធី និងប្រពន្ធឈ្មោះ តាន់ គឹមលី នៅភូមិទួលគោក សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្ដឹងឈ្មោះ យោគ ស្លេះ ជាអនុភូមិកំពង់ត្រឡាចក្រោម ឃុំកំពង់ត្រឡាច ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង បានរុះរើបង្គោលរបង កាត់លួសរបង ដីកប៉សពដូនតារបស់គាត់ ស្ថិតនៅភូមិអ្នកតាហាង ឃុំកំពង់ត្រឡាច ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង

១៥.ឈ្មោះ យាន តុប នៅភូមិវាលវង្វៀង ឃុំច្រេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ប្ដឹងអនុប្រធានភូមិកំពង់ក្ដារ និងចាស់ព្រឹទ្ធាចារ្យភូមិកំពង់ក្ដារ បានឈូសឆាយដីផ្លូវសាធារណៈ ដែលគាត់ធ្វើដំណើរ[illegible]ចូលធ្វើស្រែប្រាំង ស្ថិតនៅចំណុចព្រៃជគ្រុំ ក្នុងភូមិកំពង់ក្ដារ ឃុំកំពង់ត្រឡាច ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង

ខ.៣ពាក្យបណ្ដឹងរង់ចាំការសម្រេចពីថ្នាក់ដឹកនាំក្រសួងចំនួន១៥បណ្ដឹង

១.ឈ្មោះ លឹម ខេមរា តំណាងឱ្យឈ្មោះ មូស្ដាក អាម៉ាដ នៅផ្លូវ៣ប៉េតេ ភូមិ[illegible] ៥

ខណ្ឌមានជ័យ រាជធានីភ្នំពេញ ស្នើសុំជួយអន្តរាគមន៍កាន់កាប់ដីទំហំ៥០០ហិកតាមានទីតាំងនៅភូមិគីរីវ័ន្ត និងភូមិស្ទឹងឆាយ ឃុំស្ទឹងឆាយ ភូមិចម្ការហ្លួង និងភូមិបឹងត្រាច ឃុំចម្ការហ្លួង ស្រុកកំពង់សិលា ខេត្តកោះកុង (បច្ចុប្បន្នខេត្តព្រះសីហនុ) ដែលត្រូវបានឈ្មោះ ហង្ស សាមឿន និងបក្ខពួករំលោភយកទៅចុះបញ្ជីជាកម្មសិទ្ធិផ្ទាល់ខ្លួន

២.ឈ្មោះ ព្រីង ណាង ឈ្មោះ ម៉ោញ នន ឈ្មោះ ទូច ពោ និងឈ្មោះ នួន ចាន់ តំណាងប្រជាពលរដ្ឋចំនួន ៣៦៧គ្រួសារ នៅខេត្តកំពង់ធំ ស្នើសុំជួយអន្តរាគមន៍រកយុត្តិធម៌ និងមានចំណាត់ការចំពោះ លោក ហេង មនោ អតីតមេឃុំផាត់សណ្តាយ លោក ឡាង សារ៉ូ អភិបាលរង ស្រុកកំពង់ស្វាយ និងលោក សុខ ហៃ អភិបាលរងខេត្តកំពង់ធំ ដែលបានយកដីរបស់ប្រជាពលរដ្ឋ នៅតំបន់វាលស្រង៉ែទំហំ១,៦០០ហិកតា ដែលបានកាត់ឆ្វៀលតាមសជណា ឆ្នាំ២០១៥ របស់រាជរដ្ឋាភិបាលរួចហើយនោះ យកទៅជួលឱ្យគេ និងបែងចែកឱ្យបក្ខពួករបស់ខ្លួន ចំនួន៦បណ្តឹង

៣.ឈ្មោះ គុន បាន នៅភូមិព្រៃកែស ឃុំដំណាក់តន្ទួតជើង ស្រុកកំពង់ត្រាច ខេត្តកំពត និងឈ្មោះ អ៊ុច ថា នៅភូមិពងទឹក ឃុំព្រៃរំដេង ស្រុកមេសាង ខេត្តព្រៃវែង ស្នើសុំជួយអន្តរាគមន៍ចាត់ក្រុមការងារចុះអង្កេតស្រាវជ្រាវ និងធ្វើអធិការកិច្ច ដីទំហំ១៤ហិកតា ស្ថិតនៅភូមិឫទ្ធី២ ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ដែលមានប្រជាពលរដ្ឋចំនួន២៥គ្រួសារ ស្នើសុំចុះបញ្ជីជាកម្មសិទ្ធិមិនបាន ដោយសារថាមានការពាក់ព័ន្ធជាមួយឈ្មោះ ឡុង សុខន

៤.ឈ្មោះ ទន់ គឹមហួយ មេធាវី តំណាងឱ្យទណ្ឌិតចំនួន១៤នាក់ កំពុងជាប់ឃុំនៅមណ្ឌលកែប្រែទី១ ព្រៃស (ម១) ប្តឹងមន្ត្រីឈ្មោះ លឹម ប៊ុនឃៀន អត្តលេខ ០២១១ មានតួនាទីជាអនុប្រធានមណ្ឌល (ម១) ព្រៃស បានយកឈ្មោះថ្នាក់ដឹកនាំ ជាអគ្គនាយកដ្ឋានពន្ធនាគារ នៃក្រសួងមហាផ្ទៃ ប្រើប្រាស់ដើម្បីគម្រាមទារប្រាក់ប្រចាំខែ គម្រាមប្តូរពួកគាត់ទៅគុកនៅខេត្តឆ្ងាយ និងមិនឱ្យជួបបងប្អូនដែលត្រូវមកសួរសុខទុក្ខ

៥.ឈ្មោះ មាន សុវណ្ណា ឈ្មោះ សាំង គឹមឡេង និងឈ្មោះ ខូវ សេងគង់ ជាមន្ត្រីគម្រោងក្នុងនាយកដ្ឋានប្រែប្រួលអាកាសធាតុ នៃអគ្គនាយកដ្ឋានគោលនយោបាយ និងយុទ្ធសាស្ត្រ ក្រសួងបរិស្ថាន ស្នើសុំជួយអន្តរាគមន៍ករណីឯកឧត្តម ស៊ុំ ធី អគ្គនាយកស្តីទី ឯកឧត្តម ហេង ចាន់ធឿន អគ្គនាយករង និងលោកស្រី ឃ្លោក វិចិត្ររដ្ឋា អនុប្រធាននាយកដ្ឋាន បង្កភាពមិនប្រក្រតី ក្នុងការអនុវត្តការងារខុសពីវិជ្ជាជីវៈ ផ្ទុយពីអ្វីដែលថ្នាក់ដឹកនាំបានណែនាំ ពិសេសបានគម្រាម បំភ័យដល់ពួកគាត់ឱ្យលាឈប់ពីការងារ និងបញ្ឈប់ពួកគាត់ពីការងារដោយមិនបានបញ្ជាក់ពីមូលហេតុឱ្យបានច្បាស់លាស់ (ទទួលតាមអនឡាញ)

៦.ឈ្មោះ ង៉ែត ថន នៅភូមិជ្រោយអំពិល សង្កាត់ក្បាលកោះ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ស្នើសុំក្រសួងជួយពិនិត្យដោះស្រាយដើម្បីឱ្យគាត់បានចុះបញ្ជីជាលក្ខណៈប្រព័ន្ធនូវដីលំនៅដ្ឋានទំហំ៨ម៉ែត្រx២៥ម៉ែត្រស្ថិតនៅភូមិជ្រោយអំពិល សង្កាត់ក្បាលកោះ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ដែលគាត់បានរស់នៅតាំងពីឆ្នាំ១៩៨៥មកម្ល៉េះ (ទទួលតាមអនឡាញ)

៧.ឈ្មោះ ឈុន ចាន់ណាល់ នៅភូមិកាតាយ ឃុំសូយោង ស្រុកបារាយ ខេត្តកំពង់ធំ ជាតំណាងប្រជាពលរដ្ឋចំនួន៨គ្រួសារ ស្នើសុំក្រសួងចុះធ្វើអធិការកិច្ច និងជួយពន្លឿនការដោះស្រាយបណ្តឹងចំនួន៣ ពាក់ព័ន្ធករណីវិវាទដីផ្លូវទីបញ្ចុះសព ស្ថិតនៅតំបន់ទួលតាហង្ស (ទួលតាផាត់) ភូមិឫស្សីល៍ ឃុំស្វាយភ្លើង ស្រុក[illegible] (អតីតស្រុកបារាយណ៍) ខេត្តកំពង់ធំ

៨.ដីការបញ្ជូនលេខ ២០៦ ខន/០២៤ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៤ របស់ខុទ្ទកាល័យ[illegible]មហាបវរធិបតី

នាយករដ្ឋមន្ត្រី ករណីលិខិតចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២៤ របស់ឈ្មោះ ហ៊ន សៈមុន្នី ហៅ ហ៊ននី នៅភូមិព្រៃកស្វាយ សង្កាត់កោះរ៉ុង ក្រុងកោះរ៉ុង ខេត្តព្រះសីហនុ គោរពស្នើសុំ សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី ជួយស្រាវជ្រាវប្រវត្តិនៃការកាន់កាប់ដីមុន និងក្រោយពេលដាក់ដីជាឧទ្យានជាតិរាម និងអ្នកដែលបានកាន់កាប់ដី អាស្រ័យផលយូរឆ្នាំលើដីទំហំ២៣២,៩៩៥ម៉ែត្រការ៉េ ស្ថិតនៅទល់មុខព្រលានយន្តហោះអន្តរជាតិរាម ខេត្តព្រះសីហនុ លើលិខិត (របាយការណ៍) លេខ៣៥៤៧ សជណ.បស្ក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៣ របស់ក្រសួងបរិស្ថាន ដែលពុំបានដាក់បញ្ចូលនូវឯកសារដីរបស់គាត់មួយចំនួនក្នុងឯកសាររបាយការណ៍

៩.ឈ្មោះ ជា សុខហេង នៅភូមិ៧ សង្កាត់ទឹកល្អក់ ខណ្ឌទួលគោក រាជធានីភ្នំពេញ ស្នើសុំក្រសួងអធិការកិច្ចជួយអន្តរាគមន៍ករណីបុគ្គល៥រូប ឈ្មោះ សុខ រ៉ាថន ឈ្មោះ កែវ ចាន់ ឈ្មោះ សុខ ឡី ឈ្មោះ ឌី ជុំ ដែលបានប្រើប្រាស់អំណាចរំលោភយកដីរបស់គាត់ទំហំ១៥ហិកតា នៅភូមិពូធឿង ឃុំបិទត្រាំង ស្រុកព្រៃនប់ (ក្រុងព្រះសីហនុ) ខេត្តព្រះសីហនុ

១០.ពាក្យបណ្តឹងឈ្មោះ កៀង ផល្លាកុល និងឈ្មោះ កៀង វីរៈកុល នៅផ្ទះលេខ១E0 ផ្លូវ២៥៧ សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ប្តឹងឈ្មោះ អ៊ុក សុផាន់ណារី ថាបានរំលោភកាន់កាប់ទ្រព្យសម្បត្តិរបស់គាត់មានដីទំហំ៥៧៦ម៉ែត្រការ៉េ និងផ្ទះលេខ១E0 និងE1 (១០.៤០ម៉ែត្រx១៨.៣០ម៉ែត្រ) មានទីតាំងដូចខាងលើ

១១.ឈ្មោះ ខន ចាន់លីដា នៅភូមិព្រៃកដូនហែម ឃុំព្រៃកអំពិល ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ស្នើសុំជួយរកយុត្តិធម៌ជូនគាត់ ដើម្បីបានចូលកាន់កាប់ដីរបស់គាត់ ស្ថិតនៅផ្លូវ៥៦០ ភូមិ១១ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ

១២.ឈ្មោះ រី ណូយែល នៅផ្ទះលេខ៣២១ ផ្លូវ២៨ ភូមិព្រែកហ្លួង ឃុំព្រែកហ្លួង ស្រុកឯកភ្នំ ខេត្តបាត់ដំបង និងឈ្មោះ ខៃ ណារិន នៅភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ស្នើសុំបើកការស៊ើបអង្កេតស្រាវជ្រាវរកការពិតរឿងវិវាទដីធ្លីរបស់ពួកគាត់ជាមួយឈ្មោះ សៀង ចាន់ហេង និងឈ្មោះ ស៊ី វុទ្ធី ស្ថិតនៅភូមិសាស្ត្រ ភូមិទួលសាលា ឃុំស្អាងភ្នំ ស្រុកស្អាង ខេត្តកណ្តាល ចំនួន៣ប័ណ្ណ របស់ឈ្មោះ រី ណូយែល និងចំនួន១៧ប័ណ្ណ របស់ឈ្មោះ សៀង ចាន់ហេង ស្ថិតនៅឃុំបឹងខ្យាង ឃុំព្រែកស្លែង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល

១៣.ឈ្មោះ ម៉ែន សារ៉ុម និងប្រពន្ធឈ្មោះ ស្រ៊ុន ឆេង នៅផ្ទះលេខ២៦E0 ផ្លូវលេខ៦៣ សង្កាត់ផ្សារថ្មីទី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ស្នើសុំជួយអន្តរាគមន៍បញ្ជាក់ពីលទ្ធផលការដោះស្រាយវិវាទរបស់ឈ្មោះ ឡុង ដារ៉ា ដែលបានប្តឹងឧកញ៉ា ជួន កុល ឧកញ៉ា ប៊ុន ជេស និងឈ្មោះ ស្រ៊ុន ឆេង ពីបទប្រើអំណាចឃុបឃិតគ្នាកសាងឯកសារបន្លំយកដីរបស់គាត់ទំហំ២២,១៣៤ម៉ែត្រការ៉េ ស្ថិតនៅភូមិដួង សង្កាត់ព្រែកញ្ចៅ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ

១៤.ឈ្មោះ រ័ត្ន សុខទី និងប្រពន្ធឈ្មោះ សាង ង៉ែត (យ៉ាន់ ជ្រក់) (ស្លាប់) នៅផ្ទះ៣៨៦ ផ្លូវ៣៧១ ភូមិព្រែកតាគង់១ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ ស្នើសុំជួយអន្តរាគមន៍រកយុត្តិធម៌ ដើម្បីបានទទួលប្រាក់គោលនយោបាយសមរម្យពីក្រុមហ៊ុនបុរីប៉េងហួត បុរីជីបម៉ុង និងបុគ្គលពាក់ព័ន្ធលើដី៥ទីតាំងមានទំហំ៣០,៨៣៦ម៉ែត្រការ៉េ និងពីក្រុមហ៊ុនអាយអិនជីហូលឌីងមានដីទំហំ៥ហិកតា ស្ថិតនៅភូមិព្រែកថ្លឹង សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ព្រមទាំងស្នើសុំកាត់ឆ្វៀលដីទំហំ១២,៦៥០ម៉ែត្រការ៉េ និងដីទំហំ៧,៤៩៤.៤៥ម៉ែត្រការ៉េ ស្ថិតនៅភូមិខ្វា សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ធ្វើប័ណ្ណកម្មសិទ្ធិស្របច្បាប់



ក្រសួងអធិការកិច្ច

១៥.ឈ្មោះ អ៊ុក ជី នៅភូមិត្រពាំងឫស្សី ឃុំដំណាក់សុក្រំ ស្រុកដងទង់ ខេត្តកំពត ស្នើសុំជួយដោះស្រាយករណីដីទំនាស់ចំនួន១១កន្លែង ស្ថិតនៅភូមិភ្នំលាវ ឃុំពងទឹក និងភូមិកែវក្រសាំង ឃុំកែប ស្រុកដំណាក់ចង្អើរ ខេត្តកែប ដែលត្រូវបានបុគ្គលមួយចំនួន ប្រើអំពើហិង្សា រំលោភដណ្តើមចូលកាន់កាប់។

គ.ពាក្យបណ្តឹងបានបញ្ជូនទៅស្ថាប័នផ្សេងដោះស្រាយចំនួន២បណ្តឹង

១.ឈ្មោះ អ៊ុង ចាន់ថន នៅផ្ទះលេខ២៤១ ផ្លូវ៤៥៤ ភូមិ៨ សង្កាត់ទួលទំពូង១ ខណ្ឌចំការមន រាជធានីភ្នំពេញ ស្នើសុំឯកឧត្តមរដ្ឋមន្ត្រីក្រសួងអធិការកិច្ច ជួយចាត់គណៈប្រតិភូចុះអង្កេតស្រាវជ្រាវភាពមិនប្រក្រតីក្នុងការចេញប័ណ្ណកម្មសិទ្ធិលើក្បាលដីលេខ០៧៧៨ ស្ថិតនៅភូមិអណ្តូងតាសី សង្កាត់ព្រៃឆ្លាក់ ក្រុងស្វាយរៀង ខេត្តស្វាយរៀង (បានបញ្ជូនទៅមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្តស្វាយរៀង)

២.ឈ្មោះ ជាម ស៊ីថុល ជាទីប្រឹក្សាក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ប្តឹងតវ៉ាចំពោះសមត្ថកិច្ចបង្ក្រាបបទល្មើសគ្រឿងញៀន ដែលមានសកម្មភាពល្មើសច្បាប់ និងបានបំពានធ្ងន់ធ្ងរមកលើឈ្មោះ អេន សុជាតិ ពាក់ព័ន្ធនឹងករណីបង្ក្រាបគ្រឿងញៀន នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២១ (បានបញ្ជូនទៅក្រសួងមហាផ្ទៃ)។

ឃ.ពាក្យបណ្តឹងដែលជាសមត្ថកិច្ចក្រសួងចំនួន១បណ្តឹង

-ពាក្យស្នើសុំចុះអង្កេតស្រាវជ្រាវករណីភាពមិនប្រក្រតីគម្រោងអភិវឌ្ឍន៍ទេសចរណ៍ផ្សារភ្ជាប់នឹងធម្មជាតិខ្នាតតូចរបស់លោកស្រី ស៊ឹង សុខអាង ក្នុងការអនុវត្ត ដែលស្ថិតនៅចំណុចជើងភ្នំ១,៥០០ ក្នុងភូមិដីក្រហម ឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់។

ង.ពាក្យបណ្តឹងដែលមន្ទីររាជធានី ខេត្តសម្រេចតម្កល់ទុកមិនចាត់ការចំនួន១បណ្តឹង

-ឈ្មោះ ភន ពៅ និងប្រពន្ធឈ្មោះ ជា ឈុនលេង នៅភូមិជ្រោយជ្រៃ ឃុំសំបួរ ស្រុកល្វាឯម ខេត្តកណ្តាល ស្នើសុំជួយអន្តរាគមន៍ដោះស្រាយករណីភាពមិនប្រក្រតី របស់ឈ្មោះ វីរៈ សារាយ លោកអភិបាលរងស្រុកល្វាឯម និងបក្ខពួក ដែលបានរំលោភអំណាច បំពានទៅនឹងនីតិវិធីតុលាការ ដកហូតយកដីភូមិលំនៅដ្ឋាន ដែលជាកម្មសិទ្ធិរបស់ពួកគាត់ ទទឹងទំហំ៤ម៉ែត្រ និងបណ្តាយទំហំ៦១.៣៦ម៉ែត្រ ស្ថិតនៅភូមិជ្រោយជ្រៃ ឃុំសំបួរ ស្រុកល្វាឯម ខេត្តកណ្តាល បើកផ្លូវទុកសម្រាប់ឱ្យឡានដឹកដីធ្វើអាជីវកម្មដឹកដីលក់។

ច.ពាក្យបណ្តឹងកំពុងសម្របសម្រួលថ្នាក់ក្រសួងចំនួន២បណ្តឹង

១.ឈ្មោះ ធយ ស្រីពៅ នៅភូមិព្រែកតាបែន ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល ពាក់ព័ន្ធករណីទំនាស់ដីធ្លីទំហំ២៤,៥៤២ម៉ែត្រការ៉េ ស្ថិតនៅភូមិចំបក់មាស សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ (អតីតភូមិព្រែកតាបែន ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល)

២.ឈ្មោះ គឹម រតនា មេធាវីតំណាងដោយអាណត្តិឱ្យលោកស្រី ធយ ស្រីពៅ ស្នើសុំជួយអន្តរាគមន៍ឱ្យអញ្ជើញឈ្មោះ តេង ហឿង ដែលអះអាងថាដីទំនាស់ទំហំ២៤,៥៤២ម៉ែត្រការ៉េ មានប័ណ្ណសម្គាល់ម្ចាស់អចលនវត្ថុរួចហើយ ស្ថិតនៅភូមិព្រែកតាបែន ស្រុកមុខកំពូល ខេត្តកណ្តាល ជាដីរបស់ខ្លួនតាមរយៈលោក ប្រាក់ វីខន។

ឆ.ពាក្យបណ្តឹងកំពុងចុះអង្កេតស្រាវជ្រាវចំនួន២៣បណ្តឹង (អគ្គនាយកដ្ឋានអធិការកិច្ចចំនួន១៩បណ្តឹង និងមន្ទីររាជធានី ខេត្តចំនួន៤បណ្តឹង)៖

១.ពាក្យស្នើសុំចុះអង្កេតស្រាវជ្រាវករណីភាពមិនប្រក្រតីគម្រោងអភិវឌ្ឍន៍ទេសចរណ៍ផ្សារភ្ជាប់នឹងធម្មជាតិ

ខ្នាតតូចរបស់លោកស្រី ស៊ឹង សុខអាង ក្នុងការអនុវត្ត ដែលស្ថិតនៅចំណុចជើងភ្នំ១,៥០០ ក្នុងភូមិដីក្រហម ឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់

២.ឈ្មោះ ហង់ សុគន្ធ នៅភូមិដីវីជាន់ខ្លា សង្កាត់ដីវីជាន់ខ្លា ក្រុងស្ទឹងសែន ខេត្តកំពង់ធំ តំណាងឱ្យឈ្មោះ សុខ មុន្នី និងឈ្មោះ ប៉េង ចន្នី និងជាម្ចាស់ភាគហ៊ុនស្ថានីយបូមទឹកប្រឡាយព្រះគន្លង និងប្រឡាយព្រះស្នែង ស្ថិតនៅភូមិខ្យាច់ជីរស់ ឃុំកំពង់គោ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ស្នើសុំជួយអន្តរាគមន៍ធ្វើអធិការកិច្ចចំពោះភាពមិនប្រក្រតីរបស់រដ្ឋបាលខេត្តកំពង់ធំ លើករណីទិញផ្តាច់ស្ថានីយបូមទឹកឯកជនចំនួន១៩ស្ថានីយ នៅទូទាំងខេត្តកំពង់ធំ

៣.ឈ្មោះ កៅ ឡាយ និងប្រពន្ធឈ្មោះ យស់ ពេញ នៅភូមិឥន្ទជិត ឃុំឈើទាល ស្រុកបាណន់ ខេត្តបាត់ដំបង ប្តឹងបដិសេធលិខិតលេខ១៧៥៦ សជណ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២២ របស់សាលាខេត្តបាត់ដំបង ដែលថាដីស្រែរបស់គាត់ទំហំ៨,១០០ម៉ែត្រការ៉េ ជាដីរដ្ឋ

៤.ឈ្មោះ ហាក់ លីណា នៅភូមិកំពង់ក្រែង ឃុំកំពង់ក្រែង ស្រុកទឹកឈូ ខេត្តកំពត ស្នើសុំក្រសួងបង្កើតក្រុមការងារចុះស្រាវជ្រាវករណីឈ្មោះ មីន កុអាណា ធ្វើរបងបិទផ្លូវលំសាធារណៈ ស្ថិតនៅភូមិកំពង់ក្រែង ឃុំកំពង់ក្រែង ស្រុកទឹកឈូ ខេត្តកំពត

៥.ឈ្មោះ ហ្វាន់ ទី និងប្រពន្ធឈ្មោះ ហេង មុយ នៅភូមិកម្មករ សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង ស្នើសុំជួយអន្តរាគមន៍ស៊ើបអង្កេតភាពមិនប្រក្រតីនៃសេចក្តីសម្រេចរបស់រដ្ឋបាលខេត្តបាត់ដំបង ករណីវិវាទដីធ្លីរបស់គាត់ជាមួយឈ្មោះ ញឹម សុគន្ធ

៦.ឈ្មោះ វ៉ាន់ សារឿន តំណាងឱ្យឈ្មោះ យ៉ា សុជាតិ នៅភូមិចក ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ ស្នើសុំជួយអន្តរាគមន៍ទៅរដ្ឋបាលខេត្តបន្ទាយមានជ័យ ដើម្បីចុះស្រាវជ្រាវករណីអាជ្ញាធរភូមិ សង្កាត់ មិនព្រមចេញប័ណ្ណកម្មសិទ្ធិដីចំនួន២កន្លែង ស្ថិតនៅភូមិទួលពង្រ សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ឱ្យឈ្មោះ យ៉ា សុជាតិ

៧.ឈ្មោះ ខៃ ណារិន នៅផ្ទះលេខ៣ ផ្លូវលេខ១១០បេ ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ គោរពស្នើសុំសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី ជួយអន្តរាគមន៍មកសម្តេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ចាត់គណៈប្រតិភូចុះអង្កេតស្រាវជ្រាវរកយុត្តិធម៌ជូនគាត់ ករណីលោកជំទាវឧកញ៉ា សៀង ចាន់ហេង ប្រឌិតរឿងរ៉ាវក្លែងបន្លំឯកសារ បំភាន់ការពិត កុហកថ្នាក់ដឹកនាំ និងអាជ្ញាធរមានសមត្ថកិច្ចក្នុងបំណងបិទបាំងភាពទុច្ចរិតរបស់ខ្លួន ដើម្បីរំលោភយកដីរបស់គាត់ទំហំ៣៦១,៦២៣.៧៥ម៉ែត្រការ៉េ ស្ថិតនៅចំណុចទួលអញ្ចាញ ភូមិទួលសាលា ឃុំស្អាងភ្នំ ស្រុកស្អាង ខេត្តកណ្តាល

៨.ឈ្មោះ ឌុន សុខុម នៅផ្ទះលេខ៥៣ ផ្លូវ២៤បេតេ ភូមិត្នោតជ្រុំ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ ជាម្ចាស់ដី និងជាអ្នកតំណាងឱ្យឈ្មោះ ឈាង ពន្លក និងឈ្មោះ អៀង រតនា ស្នើសុំជួយអន្តរាគមន៍ករណីដីកំពុងមានទំនាស់មួយកន្លែងទំហំ៣២ហិកតា ស្ថិតនៅភូមិព្រែកសង្កែរ សង្កាត់ទឹកថ្លា ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ

៩.ឈ្មោះ សួន គឹមសុង ឈ្មោះ សឿន ស្រី ឈ្មោះ មួង ចន្ធូក ឈ្មោះ ចន លី និងឈ្មោះ សាម គៀក នៅភូមិកំពង់ស្វាយ ឃុំកំពង់ស្វាយ ស្រុកកៀនស្វាយ ខេត្តកណ្តាល គោរពស្នើសុំ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី ជួយអន្តរាគមន៍មកសម្តេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនង

ជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ចាត់គណៈប្រតិភូចុះអង្កេតស្រាវជ្រាវរកយុត្តិធម៌ជូនគាត់ ករណីលោក អៀង ណារិន (ឧត្តមសេនីយ៍ទោ នៃកងយោធពលខេមរភូមិន្ទ) ឈ្មោះ យិន កេតុមរៈ និងបក្ខពួកបានរំលោភយកដីទំហំ៩០ហិកតា ស្ថិតនៅភូមិព្រៃកតានប់ ឃុំកំពង់ស្វាយ ស្រុកកៀនស្វាយ ខេត្តកណ្តាល

១០.ឈ្មោះ សួន គឹមសុង ឈ្មោះ សឿន ស្រី ឈ្មោះ មួង ចន្ទូក ឈ្មោះ ចន លី និងឈ្មោះ សាយ គៀក នៅភូមិកំពង់ស្វាយ ឃុំកំពង់ស្វាយ ស្រុកកៀនស្វាយ ខេត្តកណ្តាល គោរពស្នើសុំសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ជួយអន្តរាគមន៍មកសម្តេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ចាត់គណៈប្រតិភូចុះអង្កេតស្រាវជ្រាវរកយុត្តិធម៌ជូនគាត់ ករណីលោក អៀង ណារិន (ឧត្តមសេនីយ៍ទោ នៃកងយោធពលខេមរភូមិន្ទ) ឈ្មោះ យិន កេតុមរៈ និងបក្ខពួកបានរំលោភយកដីទំហំ៩០ហិកតា ស្ថិតនៅភូមិព្រៃកតានប់ ឃុំកំពង់ស្វាយ ស្រុកកៀនស្វាយ ខេត្តកណ្តាល

១១.ឈ្មោះ ផូ កុន ឈ្មោះ ឈុន សំអិន ឈ្មោះ វ៉ា វីល្បៀ ឈ្មោះ តាំង បូនី ឈ្មោះ ចា គង្គា ឈ្មោះ ហេង រដ្ឋា និងឈ្មោះ ឈីវ វៃយ តំណាងប្រជាពលរដ្ឋចំនួន២០៥គ្រួសារ មានផ្ទះ ចម្ការ និងដីស្រែ ស្ថិតក្នុងភូមិ៤ គឺភូមិតិត្ថបញ្ញោ ភូមិសំរោង ភូមិចែងម៉ែង សង្កាត់សំរោងក្រោម និងភូមិកាកាប២ សង្កាត់កាកាប២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ស្នើសុំឯកឧត្តមរដ្ឋមន្ត្រីក្រសួងអធិការកិច្ច មេត្តាចាត់គណៈប្រតិភូចុះអង្កេតស្រាវជ្រាវ រកយុត្តិធម៌ជូនប្រជាពលរដ្ឋចំនួន២០៥គ្រួសារ ពាក់ព័ន្ធនឹងផ្ទៃដីទំហំ៥០ហិកតា៤១អា២៧សង់ទីអា ដែលស្ថិតក្នុងភូមិ៤ គឺភូមិតិត្ថបញ្ញោ ភូមិសំរោង ភូមិចែងម៉ែង សង្កាត់សំរោងក្រោម និងភូមិកាកាប២ សង្កាត់កាកាប២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

១២.ឈ្មោះ លឹម គឹម ស៊ា នៅផ្ទះលេខ១១១អឺ២ ភូមិ៤ ផ្លូវ២១៧ សង្កាត់អូរឫស្សីទី៣ ខណ្ឌ៧មករា រាជធានីភ្នំពេញ តំណាងឱ្យឈ្មោះ ហួន លីមីង ស្នើសុំជួយអន្តរាគមន៍ឱ្យឈ្មោះ ហួន លីមីង បានកាន់កាប់ដីទំហំ ៤៩៩,៧៩៨ ម៉ែត្រការ៉េ ដែលមានប័ណ្ណសម្គាល់អចលនវត្ថុ ស្ថិតនៅភូមិសុវណ្ណគិរី ឃុំខ្ទុំក្រាំង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ

១៣.ឈ្មោះ អ៊ុច សម្បត្តិ នៅផ្ទះលេខ៨១១ ផ្លូវលេខ៩៣ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ ឈ្មោះ វ៉ាន់ ស្រីពៅ នៅភូមិ៣ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ប្តឹងឈ្មោះ លី សុខង៉ឹម ឈ្មោះ អាន គឹមហឿន ឈ្មោះ ហ៊ូ យ៉ៃ ឈ្មោះ ហឹម សុកល ឈ្មោះ ស៊ី ប្រុស ឈ្មោះ រស់ យ៉ាន ឈ្មោះ តាក់ សីឡៅ និងបក្ខពួក បានប្រើហិង្សា និងឯកសារមិនត្រឹមត្រូវ បានរំលោភយកដីរបស់គាត់ទំហំ២៣៩,៤២៦ម៉ែត្រការ៉េ ស្ថិតនៅភូមិពូធឿង ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ

១៤.ឈ្មោះ ផុន សុខឃៀង និងឈ្មោះ ញ៉ាន សំអាត នៅស្រុកបាធាយ ខេត្តកំពង់ចាម ប្តឹងឈ្មោះ ទេព ភីរម្យ និងបក្ខពួក ដែលបានលួចលក់ដីរបស់ពួកគាត់ទំហំ៨ហិកតា ស្ថិតនៅភូមិចុង ឃុំសំបូរ ស្រុកបាធាយ ខេត្តកំពង់ចាម

១៥.ឈ្មោះ យ៉ាន់ សុឃឿន នៅក្រុមទី១១ ភូមិ៣ សង្កាត់លេខ២ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ប្តឹងឈ្មោះ លី សុខង៉ឹម ឈ្មោះ ហ៊ូ យៃ ឈ្មោះ អាន គឹមហឿន ឈ្មោះ ហឹម សុកល ឈ្មោះ ស៊ី ប្រុស ឈ្មោះ រស់ យ៉ាន និងឈ្មោះ តាក់ សីឡៅ បានឃុបឃិតគ្នាប្រើប្រាស់អំណាចដោយខុសច្បាប់ ធ្វើការឈូសឆាយរំលោភយកដីចំការរបស់គាត់ទំហំ៧៩,៥០៥ម៉ែត្រការ៉េ ស្ថិតនៅភូមិចំណោតរាម ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ

១៦.ឈ្មោះ ប៉ែន វ៉ានី នៅភូមិ៤ ផ្លូវទេពផន សង្កាត់ផ្សារដេប៉ូ ខណ្ឌទួលគោក រាជធានីភ្នំពេញ ប្តឹងឈ្មោះ អ៊ុង ស្មាង ឈ្មោះ អ៊ុង រដ្ឋា ឈ្មោះ លឹម សុវណ្ណនី ឈ្មោះ កែវ ពត ឈ្មោះ ខៀវ វណ្ណៈ ឈ្មោះ ខៀវ វុទ្ធី និងបក្ខពួក បានប្រើប្រាស់

កងកម្លាំងប្រដាប់អាវុធទាំងបំពាន រំលោភយកដីរបស់ពួកគាត់ទំហំ៩ហិកតា ស្ថិតនៅភូមិ១ ឃុំអូរត្រេះ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ

១៧.ឈ្មោះ សួន សុខុម និងឈ្មោះ ស្រេង ឫទ្ធី (ព្រំ រិទ្ធី) នៅខេត្តបន្ទាយមានជ័យ ប្តឹងឈ្មោះ យឹម សុផាត ឈ្មោះ អ៊ុំ យ៉ាត ឈ្មោះ ជួប ដែត ឈ្មោះ ទូច វ៉ាន់ និងឈ្មោះ អឹម សារ៉េន បានអូសទាញប្រជាពលរដ្ឋពីខេត្តផ្សេងៗ មករំលោភយកដីរបស់ពួកគាត់ទំហំ១១៥ហិកតា នៅភូមិអូរអំពិល ឃុំទួលពង្រ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ អតីតភូមិស្មើសាមគ្គី សង្កាត់និមិត្ត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ

១៨.ប្រជាពលរដ្ឋចំនួន៥៤គ្រួសារ នៅភូមិបន្លាស្អិត សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ និងឈ្មោះ អ៊ិត ភូម្រា តំណាងលោកស្រី កែវ បូ៉ា ស្នើសុំជួយអន្តរាគមន៍រកយុត្តិធម៌ ដើម្បីរក្សាផ្លូវសាធារណៈ និងផ្លូវឡើងហែម ស្ថិតនៅតំបន់មាស ណារិទ្ធ ក្នុងភូមិបន្លាស្អិត សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ

១៩.ឈ្មោះ អ៊ុច សាម៉ន និងឈ្មោះ គ្រួច សេរីរិទ្ធិ ប្តឹងឈ្មោះ ខៀវ វុទ្ធី ឈ្មោះ ខៀវ វណ្ណៈ ឈ្មោះ លីម ផន ឈ្មោះ ប្រាក់ ស្រី និងឈ្មោះ យឹម សុវណ្ណនី បានរំលោភលើដីកម្មសិទ្ធិរបស់ពួកគាត់ដែលមានទំហំ២២៩,៨០០ម៉ែត្រការ៉េ ស្ថិតនៅចំណុចវាលអង្គុញ ក្រុមទី៤ ភូមិ១ ឃុំអូរត្រេះ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ

២០.ឈ្មោះ ផាត់ សុភ័ន តំណាងឱ្យប្រជាពលរដ្ឋចំនួន៥គ្រួសារ នៅភូមិក្បាលថ្នល់ ឃុំផ្សារ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង ប្តឹងឈ្មោះ សុច ចាន់គា បានរំលោភយកដីចំការពីងពង់របស់ពួកគាត់ នៅខាងក្រោយផ្ទះ ស្ថិតនៅភូមិក្បាលថ្នល់ ឃុំផ្សារ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង

២១.ឈ្មោះ ឡៀប សុម៉េត នៅភូមិឡទឹកត្រី សង្កាត់កំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ប្តឹងឈ្មោះ ជួន ធៀប និងឈ្មោះ ចាន់ វណ្ណា (ប្តីប្រពន្ធ) នៅភូមិស្វាយជ្រុំថ្មី ឃុំស្វាយជ្រុំ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង បានរំលោភបំពានដីរបស់គាត់ ស្ថិតនៅភូមិចាន់ត្រក ឃុំក្រាំងស្គារ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង

២២.ឈ្មោះ វ៉ាត វ៉ាន់ នៅភូមិអំពិលដាំទឹក ឃុំវិហារហ្លួង ស្រុកពញាឮ ខេត្តកណ្តាល ប្តឹងសុំឱ្យមន្ត្រីសុរិយោដី ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ចុះវាយតម្លៃ និងវាស់វែងដីមួយកន្លែងទំហំ៨,០០០ម៉ែត្រការ៉េ ស្ថិតនៅភូមិត្រពាំងចំបក់ ឃុំលង្វែក ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ដែលបានកាន់កាប់ និងអាស្រ័យផលតាំងពីឆ្នាំ១៩៨០ រហូតដល់បច្ចុប្បន្ន

២៣.ឈ្មោះ ឡាយ សុទ្ធី និងប្រពន្ធឈ្មោះ តាន់ គីមលី នៅភូមិទួលគោក សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្តឹងឈ្មោះ យោគ ស្លេះ ជាអនុភូមិកំពង់ត្រឡាចក្រោម ឃុំកំពង់ត្រឡាច ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង បានរុះរើបង្គោលរបង កាត់លួសរបង ជីកប់សពដូនតារបស់គាត់ ស្ថិតនៅភូមិអ្នកតាហាង ឃុំកំពង់ត្រឡាច ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង។

ជ.ពាក្យបណ្តឹងត្រៀមចុះអង្កេតស្រាវជ្រាវចំនួន៦បណ្តឹង

១.ឈ្មោះ សួស ប៉ា ឈ្មោះ ឌុល ឡេម និងឈ្មោះ ឃីន គា តំណាងឱ្យប្រជាពលរដ្ឋចំនួន[illegible]គ្រួសារ ស្នើសុំឯកឧត្តមរដ្ឋមន្ត្រីក្រសួងអធិការកិច្ច ជួយចាត់គណៈប្រតិភូចុះអង្កេតស្រាវជ្រាវករណីជនឈ្មោះ [illegible] មន្ត្រីកងរាជអាវុធហត្ថខេត្តកំពង់ស្ពឺ បានរំលោភយកដីរបស់ពួកគាត់ទំហំជាង២០០ហិកតា ស្ថិតនៅភូមិ[illegible] ឃុំតាសាល ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ៥

២.ឈ្មោះ តាន់ ភនសិលា និងឈ្មោះ ម៉ៅ សម្បត្តិ នៅផ្ទះលេខ១២២E០ ផ្លូវ១៣០ ភូមិ១ សង្កាត់ផ្សារកណ្ដាល២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ស្នើសុំឯកឧត្តមរដ្ឋមន្ត្រីក្រសួងអធិការកិច្ច ជួយចាត់គណៈប្រតិភូចុះអង្កេតស្រាវជ្រាវករណីឈ្មោះ សោម សុគន្ធ ឈ្មោះ សែម សុធារី ឈ្មោះ ខ្លូត ភាព (មេភូមិភ្នំក្រិញ)ឈ្មោះ សែម សុខន ព្រមទាំងបក្ខពួក រួមជាមួយអាជ្ញាធរមានសមត្ថកិច្ច បានឃុបឃិតគ្នារំលោភយកដីរបស់ពួកគាត់ទំហំ១,៤១៣ម៉ែត្រការ៉េ ស្ថិតនៅភូមិភ្នំក្រិញ ឃុំស្ទឹងត្រង់ ស្រុកសាលាក្រៅ ខេត្តប៉ៃលិន

៣.ឈ្មោះ ស៊ី វុទ្ធី នៅភូមិព្រែកប៉ាង ឃុំកោះខែល ស្រុកស្អាង ខេត្តកណ្ដាល តំណាងប្រជាពលរដ្ឋចំនួន៦គ្រួសារ ជាអ្នករងគ្រោះបាត់បង់ដីធ្លី ស្នើសុំសម្ដេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ជួយអន្តរាគមន៍ចាត់ឱ្យមានការធ្វើអធិការកិច្ចចុះអង្កេតស្រាវជ្រាវជាក់ស្ដែងអំពីប្រវត្តិ នៃការគ្រប់គ្រងដីធ្លីទំហំ៣០ហិកតា ស្ថិតនៅភូមិវាលធំ ឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ និងធ្វើរបាយការណ៍គោរពជូន សម្ដេចតេជោ នាយករដ្ឋមន្ត្រី ពិនិត្យ និងសម្រេច ដើម្បីផ្ដល់យុត្តិធម៌ដល់ពួកគាត់ជាម្ចាស់ដីពិតប្រាកដ ដែលកំពុងរងនូវការបាត់បង់ដីធ្លីនេះ

៤.ឈ្មោះ ម៉ី ជួង មានភរិយាឈ្មោះ ទៀវ សំណាង នៅភូមិត្រោកលិច ឃុំស្រែថ្មី ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ស្នើសុំឯកឧត្តមរដ្ឋមន្ត្រីក្រសួងអធិការកិច្ច មេត្តាចាត់គណៈប្រតិភូចុះស្រាវជ្រាវរកយុត្តិធម៌ ករណីឈ្មោះ ហ៊ិន ញៀន មេភូមិល្បើកស្វាយ ឈ្មោះ ឆាយ សុផៃ មេភូមិចក់ពួក ឈ្មោះ លី សោន អតីតមេឃុំស្វាយចេក លោកស្រី ជ្រូក សុផល អតីតមេឃុំស្វាយចេក ឈ្មោះ មាស សត្រាវុធ ប្រធានការិយាល័យភូមិបាលស្រុកស្វាយចេក បានឃុបឃិតគ្នា ប្រើអំណាចរំលោភយកដីរបស់គាត់មានទំហំ៥០ហិកតា ស្ថិតនៅភូមិល្បើកស្វាយ ឃុំចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ទៅលក់ឱ្យអ្នកដទៃ

៥.ឈ្មោះ ភ្លូ បោន ឈ្មោះ ឃ្លោក លាំ ឈ្មោះ ចិន ជឿន ឈ្មោះ យឹក វ៉ៃ និងឈ្មោះ ចឹក វ៉ា តំណាងប្រជាពលរដ្ឋចំនួន១៣១គ្រួសារ ស្ថិតនៅភូមិស្រយ៉ង់ត្បូង ភូមិម្រេច ឃុំស្រយ៉ង់ ភូមិក្លាក់ ឃុំត្បែង២ ស្រុកគូលែន ខេត្តព្រះវិហារ ស្នើសុំឯកឧត្តមរដ្ឋមន្ត្រីក្រសួងអធិការកិច្ច មេត្តារៀបចំក្រុមការងារចុះអង្កេតស្រាវជ្រាវដល់ទីតាំងដីដែលប្រជាពលរដ្ឋចំនួន១៣១គ្រួសារ ដែលបានរស់នៅ និងអាស្រ័យផលជាក់ស្ដែងលើដីទំហំ៦៤៩.៤១ហិកតា ជាប់ពាក់ព័ន្ធទៅនឹងអនុក្រឹត្យលេខ១៥ អនក្រ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១១ របស់រាជរដ្ឋាភិបាល និងស្នើសុំកាត់ឆ្វៀលដីក្នុងទីតាំងរស់នៅជាក់ស្ដែងរបស់ពួកគាត់ ចេញពីអនុក្រឹត្យ ត្រង់ចំណុចភូមិក្លាក់ ស្ថិតក្នុងឃុំត្បែង២ ភូមិម្រេច និងភូមិស្រយ៉ង់ត្បូង ស្ថិតនៅក្នុងឃុំស្រយ៉ង់ ស្រុកគូលេន ខេត្តព្រះវិហារ

៦.ឈ្មោះ សឿន ប៊ុនធឿន នៅខេត្តប៉ៃលិន និងឈ្មោះ អ៊ុក គ្រេវ នៅខេត្តកែប ប្ដឹងរដ្ឋបាលខេត្តកែប ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកែប អភិបាលស្រុកដំណាក់ចង្អើរ និងអាជ្ញាធរពាក់ព័ន្ធ រួមទាំងបុគ្គលសមគំនិតទាំងអស់ ពីបទក្លែងបន្លំឯកសារ និងមិនព្រមប្រគល់បណ្ណកម្មសិទ្ធ (ប្លង់រឹង) ជូនពួកគាត់លើផ្ទៃដីទំហំ៧៦៥,០០០ម៉ែត្រការ៉េ ស្ថិតនៅភូមិទួលសាង៉ា ឃុំអង្កោល ស្រុកដំណាក់ចង្អើរ ខេត្តកែប។

ឈ.ពាក្យបណ្ដឹងបានទទួលការឆ្លើយតបចំនួន១បណ្ដឹង

-ឈ្មោះ ភួង សុភាព នៅភូមិឫស្សីចារ ឃុំថ្មគ្រែ ស្រុកចិត្របុរី ខេត្តក្រចេះ (ឆ្លើយតបតាមរយៈលិខិតលេខ២៦ ទ.រ.ព.អ.ក្រច ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២៣ របស់មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចក្រចេះ)។

៣.ពាក្យបណ្តឹងក្រសួងបានធ្វើលិខិតជំរុញការដោះស្រាយ គឺធ្វើលិខិតតឿនទារលទ្ធផល នៃការដោះស្រាយ ចំនួន២២បណ្តឹង

១.ពាក្យស្នើសុំជួយអន្តរាគមន៍របស់ឈ្មោះ សាយ មង្គល ហៅសាយ យ៉ាន ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៥ ស្នើរដ្ឋបាលខេត្តកំពង់ឆ្នាំង ផ្តល់របាយការណ៍ស្តីពីលទ្ធផល នៃការដោះស្រាយ

២.ឈ្មោះ សុខ ម៉ៅ និងប្រពន្ធឈ្មោះ មាស អន ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៥ ស្នើរដ្ឋបាលខេត្តកំពង់ឆ្នាំង ផ្តល់របាយការណ៍ស្តីពីលទ្ធផល នៃការដោះស្រាយ

៣.ឈ្មោះ អ៊ុំ សារឿន ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៤ ស្នើរដ្ឋបាលខេត្តកំពង់ស្ពឺផ្តល់របាយការណ៍ស្តីពីលទ្ធផល នៃការដោះស្រាយ

៤.ឈ្មោះ ប៉ែន ប៊ុនណារី ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្នើរដ្ឋបាលខេត្តកំពង់ស្ពឺផ្តល់របាយការណ៍ស្តីពី លទ្ធផល នៃការដោះស្រាយ

៥.ឈ្មោះ ប៉ាក ចាន់ផល និងប្រពន្ធឈ្មោះ និងប្រពន្ធឈ្មោះ អៀង ប៉ុណ្ណា ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៩ ស្នើរដ្ឋបាលខេត្តកំពង់ស្ពឺផ្តល់របាយការណ៍ស្តីពីលទ្ធផល នៃការដោះស្រាយ

៦.ពាក្យស្នើសុំជួយអន្តរាគមន៍របស់ឈ្មោះ ហ៊ឹម ប៊ុនហេង ឈ្មោះ គង់ ចាន់ និងឈ្មោះ ង៉ាន សុខគា ចុះថ្ងៃ ទី៩ ខែមីនា ឆ្នាំ២០២២ ស្នើរដ្ឋបាលខេត្តកំពង់ស្ពឺផ្តល់របាយការណ៍ស្តីពីលទ្ធផល នៃការដោះស្រាយ

៧.ពាក្យស្នើសុំជួយអន្តរាគមន៍របស់ឈ្មោះ ជា សារឿន ឈ្មោះ នូ មីន ឈ្មោះ ម្លិះ សារឿន និងឈ្មោះ ឈិន ឆេងលី ចុះថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៣ ស្នើរដ្ឋបាលខេត្តកំពង់ស្ពឺផ្តល់របាយការណ៍ស្តីពីលទ្ធផល នៃការដោះស្រាយ

៨.ពាក្យស្នើសុំជួយអន្តរាគមន៍របស់ឈ្មោះ ហ៊ឹម មួយយ៉ាន ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣ ស្នើរដ្ឋបាល ខេត្តកំពង់ស្ពឺផ្តល់របាយការណ៍ស្តីពីលទ្ធផល នៃការដោះស្រាយ

៩.ឈ្មោះ ឈឹម ឡុងឡាញ់ និងប្រពន្ធឈ្មោះ ញឹម រ៉េត ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្នើមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្តបាត់ដំបងផ្តល់របាយការណ៍ស្តីពីលទ្ធផល នៃការដោះស្រាយ

១០.ឈ្មោះ ខៀវ ឈុន និងប្រពន្ធឈ្មោះ លី ស៊ីវហុង ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៥ ស្នើរដ្ឋបាលខេត្ត បាត់ដំបងផ្តល់របាយការណ៍ស្តីពីលទ្ធផល នៃការដោះស្រាយ

១១.ពាក្យស្នើសុំជួយអន្តរាគមន៍របស់ឈ្មោះ សាត ឡាឌី ឈ្មោះ ភួន ខុន និងឈ្មោះ វ៉ាត់ សាវ៉ាង ចុះ ថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៦ ស្នើរដ្ឋបាលខេត្តបាត់ដំបងផ្តល់របាយការណ៍ស្តីពីលទ្ធផល នៃការដោះស្រាយ

១២.ពាក្យស្នើសុំជួយអន្តរាគមន៍របស់ឈ្មោះ ញ៉ែម ច័ន្ទនី តំណាងឱ្យឈ្មោះ ម៉េង អ៊ីវ ចុះថ្ងៃទី២ ខែមករា ឆ្នាំ២០១៧ ស្នើរដ្ឋបាលខេត្តបាត់ដំបងផ្តល់របាយការណ៍ស្តីពីលទ្ធផល នៃការដោះស្រាយ

១៣.ពាក្យស្នើសុំជួយអន្តរាគមន៍របស់ឈ្មោះ ណុប ពិសិដ្ឋ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០២០ ស្នើរដ្ឋបាល ខេត្តពោធិ៍សាត់ផ្តល់របាយការណ៍ស្តីពីលទ្ធផល នៃការដោះស្រាយ

១៤.ឈ្មោះ ថន ចាន់ថុន ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្នើរដ្ឋបាលខេត្តព្រះសីហនុផ្តល់របាយការណ៍ស្តីពី លទ្ធផល នៃការដោះស្រាយ

១៥.ពាក្យស្នើសុំជួយអន្តរាគមន៍របស់ឈ្មោះ សេង ឡាវ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៧ ស្នើរដ្ឋបាលខេត្ត

ពោធិ៍សាត់ផ្តល់របាយការណ៍ស្តីពីលទ្ធផល នៃការដោះស្រាយ

១៦.ឈ្មោះ សេង សីង្ហហេង មេធាវីតំណាងឱ្យឈ្មោះ ធូ សុន ឈ្មោះ សាន ចន្ថា និងឈ្មោះ នួន ណាន់ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៩ ស្នើរដ្ឋបាលខេត្តព្រះសីហនុផ្តល់របាយការណ៍ស្តីពីលទ្ធផល នៃការដោះស្រាយ

១៧.ឈ្មោះ ប៉ែន ពៅ ឈ្មោះ រស់ តូច និងឈ្មោះ ហ៊ី ហៀង ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨ ស្នើរដ្ឋបាលខេត្តព្រះសីហនុផ្តល់របាយការណ៍ស្តីពីលទ្ធផល នៃការដោះស្រាយ

១៨.ពាក្យស្នើសុំជួយអន្តរាគមន៍របស់ឈ្មោះ ទី ប៉ូលីរតនា ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៩ ស្នើរដ្ឋបាលខេត្តព្រះសីហនុផ្តល់របាយការណ៍ស្តីពីលទ្ធផល នៃការដោះស្រាយ

១៩.ពាក្យស្នើសុំជួយអន្តរាគមន៍របស់ឈ្មោះ ស៊ិន សុវណ្ណារី ឈ្មោះ ស៊ិន សុវណ្ណអន ឈ្មោះ ស៊ិន សុខគឿន ឈ្មោះ អ៊ឹង លីតាំង និងឈ្មោះ អ៊ឹង ប៊ុនតុង ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២២ ស្នើរដ្ឋបាលខេត្តព្រះសីហនុផ្តល់របាយការណ៍ស្តីពីលទ្ធផល នៃការដោះស្រាយ

២០.ពាក្យស្នើសុំជួយអន្តរាគមន៍របស់ឯកឧត្តម តាក វណ្ណថា ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ ស្នើរដ្ឋបាលខេត្តព្រះសីហនុផ្តល់របាយការណ៍ស្តីពីលទ្ធផល នៃការដោះស្រាយ

២១.ពាក្យស្នើសុំជួយអន្តរាគមន៍របស់ឈ្មោះ ព្រំ សុម៉ាលី ឈ្មោះ ឈុន សុគន្ធារី និងឈ្មោះ អ៊ុក សារ៉ែន ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២២ ស្នើរដ្ឋបាលខេត្តព្រះសីហនុផ្តល់របាយការណ៍ស្តីពីលទ្ធផល នៃការដោះស្រាយ

២២.ឈ្មោះ ធីម ថាវី ជាប្រពន្ធឈ្មោះ ឡេង ប៊ុនធឿន (ស្លាប់) និងឈ្មោះហង្ស ម៉ាលី ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២ ស្នើរដ្ឋបាលខេត្តព្រះសីហនុផ្តល់របាយការណ៍ស្តីពីលទ្ធផល នៃការដោះស្រាយ។

ង.ពាក្យបណ្តឹងបានបញ្ចប់ការដោះស្រាយចំនួន៥បណ្តឹង (មន្ទីររាជធានី ខេត្តចំនួន៥បណ្តឹង)

១.ឈ្មោះ គុន ឡាយ នៅភូមិអំពិលទឹក ឃុំចាន់សែន ស្រុកសាមគ្គីមុនីជ័យ ខេត្តកំពង់ស្ពឺ ប្តឹងឈ្មោះ ឆាយ លីយាង នៅភូមិទ្រា១ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ បានធ្វើរបងថ្មរំលោភចូលព្រំដីស្រែរបស់គាត់ ដែលមានក្បាលដីលេខ៥៥៧ ទំហំទទឹងប្រហែល៣ម៉ែត្រ សម្រុង១០០ម៉ែត្រ កន្ទុយដីទទឹង១ម៉ែត្រ និងសម្រុង ១០០ម៉ែត្រ ស្ថិតនៅភូមិអំពិលទឹក ឃុំចាន់សែន ស្រុកសាមគ្គីមុនីជ័យ ខេត្តកំពង់ស្ពឺ (ករណីនេះបានបញ្ចប់ដោយការសម្របសម្រួល)

២.ឈ្មោះ ប៉ាន សារ៉ែន នៅភូមិត្រពាំងកក់ ឃុំពោធិ៍អង្ក្រង ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ ប្តឹងឈ្មោះ សឿង សារ៉ាត់ និងប្តីឈ្មោះ ឡុង ថុល នៅភូមិត្រពាំងកក់ ឃុំពោធិ៍អង្ក្រង ស្រុកបសេដ្ឋ បានបំផ្លិចបំផ្លាញទ្រព្យសម្បត្តិអ្នកដទៃ រុករានព្រំប្រទល់ ដុតរបងព្រំប្រទល់ ដកបង្គោលព្រំប្រទល់ដី និងរំកិលព្រំប្រទល់ ស្ថិតនៅភូមិត្រពាំងកក់ ឃុំពោធិ៍អង្ក្រង ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ (ករណីនេះបានបញ្ចប់ដោយការសម្របសម្រួល)

៣.ឈ្មោះ ហ៊ុល ហួត និងប្រពន្ធឈ្មោះ សាវ ម៉ៃ នៅភូមិក្រាំងស្លែង ឃុំព្រៃក្រសាំង ស្រុកសាមគ្គីមុនីជ័យ ខេត្តកំពង់ស្ពឺ ប្តឹងឈ្មោះ សំរិត សាម៉ុន នៅភូមិក្រាំងស្លែង ឃុំព្រៃក្រសាំង ស្រុកសាមគ្គីមុនីជ័យ សុំទាមទារដីកេរ្តិ៍មរតក បន្សល់ទុកពីឪពុកម្តាយ ដែលឈ្មោះ សំរិត សាម៉ុន (ជាកូនចិញ្ចឹម) បានរំលោភយកដីចំនួន១០កន្លែង ដីស្រែចំនួន ៩កន្លែងទំហំប្រហែល១១,២៥១.៦ម៉ែត្រការ៉េ និងដីលំនៅដ្ឋានចំនួន១កន្លែងដែលមានទំហំប្រហែល ១[illegible]០ម៉ែត្រការ៉េ ស្ថិតនៅភូមិក្រាំងស្លែង ឃុំព្រៃក្រសាំង ស្រុកសាមគ្គីមុនីជ័យ ខេត្តកំពង់ស្ពឺ (ករណីនេះបានបញ្ចប់ដោយការសម្របសម្រួល)

៤.ឈ្មោះ សែម សុភាព និងប្ដីឈ្មោះ ប៉ាត ដា នៅភូមិព្រៃមាន់ ឃុំស្រែថ្មី ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ស្នើសុំជួយអន្តរាគមន៍សម្របសម្រួលវិវាទព្រំដីស្រែប្រាំង ជាមួយឈ្មោះ ង៉ាក់ ធិ និងប្រពន្ធឈ្មោះ ប្រាក់ សំអឿន ស្ថិតនៅភូមិកណ្ដាល សង្កាត់ផ្សារឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង (ករណីនេះ ភាគីទាំងពីរបានព្រមព្រៀងគ្នាបញ្ចប់ទំនាស់ ដោយឯកភាពគ្នាបោះបង្គោលព្រំដីចំការចំនួន៦បង្គោល គឺថ្ម២ និងឈើ៤ ប្រវែង៤០០ម៉ែត្រ ហើយសន្យាមិនរំលោភបំពានគ្នាទៅវិញទៅមក និងមិនប្រើហិង្សាលើគ្នា)

៥.ឈ្មោះ យាន គុប នៅភូមិវាលរវៀង ឃុំច្រេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ប្ដឹងអនុប្រធានភូមិកំពង់ក្ដារ និងចាស់ព្រឹទ្ធាចារ្យ ភូមិកំពង់ក្ដារ បានឈូសឆាយដីផ្លូវសាធារណៈ ដែលគាត់ធ្វើដំណើរចេញ-ចូលធ្វើស្រែប្រាំង ស្ថិតនៅចំណុចព្រៃជគ្រុំ ក្នុងភូមិកំពង់ក្ដារ ឃុំកំពង់ត្រឡាច ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង (ករណីនេះ ក្រុមការងារមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្តកំពង់ឆ្នាំង សហការជាមួយអាជ្ញាធរមូលដ្ឋាន ចុះពិនិត្យ សម្របសម្រួល និងដោះស្រាយ គឺភាគីទាំងពីរបានព្រមព្រៀងគ្នាបញ្ចប់ទំនាស់ ដោយភាគីអនុប្រធានភូមិកំពង់ក្ដារ និងចាស់ព្រឹទ្ធាចារ្យភូមិកំពង់ក្ដារ បានចាក់បំពេញដីធ្វើផ្លូវជូនវិញ)។

**៤.សកម្មភាពការងារសវនកម្មផ្ទៃក្នុង**

- បានចុះធ្វើសវនកម្មផ្ទៃក្នុងលើការគ្រប់គ្រងប្រើប្រាស់ សម្ភារបរិក្ខារបច្ចេកទេស នៅតាមបណ្ដានាយកដ្ឋាននានា បានចំនួន៨អង្គភាពក្នុងនោះមាន៖ នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានបុគ្គលិក និងធនធានមនុស្ស នាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ នាយកដ្ឋានផែនការ និងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ នាយកដ្ឋានអធិការកិច្ចទី១ នាយកដ្ឋានអប់រំផ្សព្វផ្សាយច្បាប់ និងនាយកដ្ឋានទំនាក់ទំនងជាមួយរាជរដ្ឋាភិបាល និងរដ្ឋសភា ព្រឹទ្ធសភា បានបញ្ចប់លើការងារត្រួតពិនិត្យទាំងស្រុង និងកំពុងរៀបចំរបាយការណ៍ដាក់ជូនឯកឧត្តមរដ្ឋមន្ត្រី។

**៥.សកម្មភាពការងារវិទ្យាស្ថានជាតិអធិការកិច្ច**

- បានពង្រឹងការគ្រប់គ្រងការងាររដ្ឋបាល និងចរន្តការងារទូទៅរបស់វិទ្យាស្ថាន
- បានបូកសរុបរបាយការណ៍ប្រចាំខែមីនា និងត្រីមាសទី១ឆ្នាំ២០២៤
- បានរៀបចំបញ្ចប់ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៥-២០២៧
- បានរៀបចំផែនការការងារ និងរបាយការណ៍តាមដានវឌ្ឍនភាពការងារប្រចាំសប្ដាហ៍
- បានរៀបចំបញ្ចប់សេចក្ដីព្រាងដំបូងសៀវភៅកម្រងអនុសាសន៍សម្ដេចធិបតី ពីថ្ងៃទី២២ ខែសីហា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣
- បានរៀបចំបញ្ចប់សេចក្ដីព្រាងដំបូងព្រឹត្តិបត្រអធិការកិច្ចត្រីមាសទី១ ឆ្នាំ២០២៤
- បានចុះស្ទង់មតិស្ដីពីការអភិវឌ្ឍមូលធនមនុស្សក្នុងវិស័យអធិការកិច្ច នៅមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចចំនួន៤មន្ទីរ
- បានទទួលសៀវភៅអានចម្រុះមុខវិជ្ជាចំនួន១៩ក្បាល ដាក់បន្ថែមក្នុងបណ្ណាល័យ
- បានផ្សព្វផ្សាយអំពីសកម្មភាពថ្នាក់ដឹកនាំក្រសួង វិទ្យាស្ថាន និងលិខិតផ្សេងៗ ក្នុងផេករបស់វិទ្យាស្ថានចំនួន[illegible]លើក
- បានស្រាវជ្រាវប្រមូលផ្ដុំលិខិតបទដ្ឋានគតិយុត្តនានាប្រចាំខែមីនាសរុបចំនួន៣១ច្បាប់
- បានទទួលអ្នកចូលចុចLikeចំនួន៣៥៨នាក់ Shareចំនួន១៣៩នាក់ និងCommentចំនួន[illegible]នាក់ លើផេក

របស់វិទ្យាស្ថាន។

## ៥.ការសន្និដ្ឋានវាយតម្លៃ

ក្នុងខែមីនា ឆ្នាំ២០២៤ ក្រសួងបានខិតខំប្រឹងប្រែងអនុវត្តការងាររបស់ខ្លួនទៅតាមបេសកកម្ម ដែលរាជរដ្ឋាភិបាលបានកំណត់ប្រកបដោយជំនាញ និងការទទួលខុសត្រូវខ្ពស់។ ទោះបីជាមានការប្រឈមក្នុងការបំពេញភារកិច្ចក្តី ក៏គ្រប់អគ្គនាយកដ្ឋាន នាយកដ្ឋាន មន្ទីរ អង្គភាពក្រោមឱវាទក្រសួងទាំងអស់ បានបំពេញភារកិច្ចទៅតាមតួនាទីរៀងៗខ្លួន ចូលរួមចំណែកយ៉ាងសកម្ម ក្នុងការកសាងព្រះរាជាណាចក្រកម្ពុជាជានីតិរដ្ឋ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា។

### ក.ចំណុចខ្លាំង

- មានការគាំទ្រពីថ្នាក់ដឹកនាំក្រសួង ជាពិសេសឯកឧត្តមរដ្ឋមន្ត្រី ដែលជានិច្ចជាកាលតែងតែយកចិត្តទុកដាក់អប់រំណែនាំជាប្រចាំដល់មន្ត្រីរាជការគ្រប់រូប ឱ្យខិតខំបញ្ចេញសមត្ថភាពការងារ ត្រូវពង្រឹង និងពង្រីកចំណេះ និងជំនាញឱ្យស្របតាមការវិវត្តន៍ នៃបច្ចេកវិទ្យាពិភពលោក
- មានសាមគ្គីភាពផ្ទៃក្នុង និងការទទួលខុសត្រូវលើការងារ
- មានការបែងចែកតួនាទីភារកិច្ច និងការទទួលខុសត្រូវរបស់ថ្នាក់ដឹកនាំក្រសួង
- មានផែនការសកម្មភាព និងផែនការប្រតិបត្តិការការងារច្បាស់លាស់
- មានរចនាសម្ព័ន្ធគ្រប់គ្រង មានការបែងចែកតួនាទីភារកិច្ច និងរបៀបរបបការងារច្បាស់លាស់
- មន្ត្រីរាជការខិតខំអនុវត្តការងារតាមតួនាទីភារកិច្ចដែលបានកំណត់។

### ខ.ចំណុចខ្វះខាត

- ពុំទាន់មានលិខិតបទដ្ឋានគតិយុត្តគ្រប់គ្រាន់ ពាក់ព័ន្ធនឹងវិស័យអធិការកិច្ច ជាពិសេសសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ច នៅមិនទាន់អនុម័តនៅឡើយ
- ពុំទាន់មានថវិកាបុរេប្រទាន មធ្យោបាយធ្វើដំណើររបស់រដ្ឋ និងសម្ភារបច្ចេកវិទ្យាមិនសមស្រប សម្រាប់ចុះបេសកកម្ម
- ពុំទាន់មានដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិ ជួយគាំទ្រលើវិស័យការងារអធិការកិច្ច ការងារតាមដានការអនុវត្តច្បាប់ ការងារទទួល និងដោះស្រាយបណ្តឹង និងការងារអប់រំផ្សព្វផ្សាយច្បាប់ ឱ្យបានទូលំទូលាយ
- ថវិកាក្រសួង ជាពិសេសបេសកកម្ម និងខ្ទង់មួយចំនួននៅមានកម្រិត ត្រូវកាត់បន្ថយដោយសារបញ្ហាជំងឺកូវីដ-១៩
- កញ្ចប់ថវិការបស់ក្រសួងមិនទាន់ឆ្លើយតបទៅនឹងតម្រូវការ និងទំហំការងារជាក់ស្តែង
- ការដោះស្រាយពាក្យបណ្តឹង នៅមានភាពស្មុគស្មាញ និងអូសបន្លាយ
- វិទ្យាស្ថានជាតិអធិការកិច្ចខ្វះគ្រូ និងឯកសារមេរៀន ដែលជាលក្ខណៈជាតិ។

### គ.បញ្ហាប្រឈម

- កិច្ចសហការរបស់អង្គភាពរងអធិការកិច្ច នៅមានកម្រិត
- នៅពេលចុះធ្វើអធិការកិច្ចមានការអន្តរាគមន៍ពីមុខសញ្ញារងអធិការកិច្ច
- របាយការណ៍អធិការកិច្ចមិនទាន់ឯករាជ្យ ដោយតម្រូវឱ្យប្រធានស្ថាប័ន ឬប្រធានអង្គភាពរងអធិការកិច្ច

ចុះហត្ថលេខាលើលទ្ធផលអធិការកិច្ច

- នៅមានភាពមិនច្បាស់លាស់ និងស្រពិចស្រពិល អំពីតួនាទីភារកិច្ចអធិការកិច្ច ជាពិសេសអធិការកិច្ចផ្អែកលើហានិភ័យ ក្រោយពីចេញអនុក្រឹត្យលេខ១៦៨ អនក្រ.បក ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០២០ ស្តីពីក្របខ័ណ្ឌមុខងាររបស់សវនកម្មផ្ទៃក្នុង និងអធិការកិច្ច ដោយសារតួនាទីភារកិច្ចរបស់ក្រសួងអធិការកិច្ច ស្រដៀងគ្នានឹងស្ថាប័នមួយចំនួន ដូចជា អង្គភាពប្រឆាំងអំពើពុករលួយ អាជ្ញាធរសវនកម្មជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអគ្គាធិការតាមបណ្តាក្រសួង ស្ថាប័ន។

**ឃ.សំណូមពរ**

- ស្នើសុំឱ្យមានកិច្ចសហការល្អរបស់អង្គភាពរងអធិការកិច្ច
- ស្នើសុំពន្លឿនសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ច
- ស្នើសុំក្របខ័ណ្ឌមន្ត្រីរាជការបន្ថែមដើម្បីឆ្លើយតបទៅនឹងតម្រូវការ និងទំហំការងារជាក់ស្តែង
- ស្នើសុំរបាយការណ៍លទ្ធផលអធិការកិច្ចឯករាជ្យ ដោយមិនបាច់ឱ្យប្រធានស្ថាប័ន ឬប្រធានអង្គភាពរងអធិការកិច្ចចុះហត្ថលេខា
- ស្នើសុំថវិកាបន្ថែមសម្រាប់ដំណើរការងាររបស់ក្រសួង ឱ្យកាន់តែមានប្រសិទ្ធភាព និងប្រសិទ្ធផលការងារ។

**III.ទិសដៅការងារបន្ត**

**១.ការងាររដ្ឋបាលកិច្ចការទូទៅ**

១.១.ការងាររដ្ឋបាល

- បន្តអនុវត្តចរន្តការងាររដ្ឋបាលឱ្យកាន់តែប្រសើរ
- បន្តទំនាក់ទំនងជាមួយគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ក្នុងការចូលរួមពិធីបុណ្យជាតិ អន្តរជាតិ និងពិធីបុណ្យផ្សេងៗទៀត។

១.២.ការងារបុគ្គលិក និងធនធានមនុស្ស

- បន្តទំនាក់ទំនង និងសម្របសម្រួលជាមួយក្រសួងមុខងារសាធារណៈលើការងារបុគ្គលិក និងធនធានមនុស្ស
- បន្តអនុវត្តនូវរាល់ព្រះរាជក្រឹត្យ អនុក្រឹត្យ សារាចរណែនាំ លិខិតបទដ្ឋានគតិយុត្តផ្សេងៗ របស់រាជរដ្ឋាភិបាល
- បន្តធ្វើទំនាក់ទំនងជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ពាក់ព័ន្ធនឹងការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ បាត់បង់សម្បទាវិជ្ជាជីវៈ ឬបាត់បង់សមត្ថភាពការងារ
- ពង្រឹងការងារពិនិត្យផ្តល់ទិដ្ឋាការលើរបាយការណ៍ស្តីពីស្ថានភាពរដ្ឋបាល និងស្ថានភាពប្រែប្រួលរបស់មន្ត្រីរាជការថ្នាក់រាជធានី ខេត្ត ឱ្យបានទាន់ពេលវេលា។

១.៣.ការងារហិរញ្ញវត្ថុ និងផ្គត់ផ្គង់

- បន្តទំនាក់ទំនងការងារជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រតនាគារជាតិ និងធនាគារជាតិ ក្នុងកិច្ចការស្នើសុំថវិកានានាតាមខ្ទង់ ជំពូក ដើម្បីបម្រើការងារក្រសួងឱ្យដំណើរការល្អប្រសើរ ដូចជាថវិកាសម្រាប់បៀវត្សដំណើរការរដ្ឋបាលទូទៅ បេសកកម្មក្នុងប្រទេស និងក្រៅប្រទេស។ល។

១.៤.ការងារផែនការ និងស្ថិតិ

- ត្រៀមបំពេញការងារស្នូលរបស់នាយកដ្ឋានក្នុងឆ្នាំ២០២៤ ឱ្យបានកាន់តែប្រសើរឡើង និង[illegible]កំណត់

របស់ថ្នាក់ដឹកនាំ

- បន្តរៀបចំបញ្ចូលធាតុចូលសូចនាករសមិទ្ធកម្ម និងគោលដៅគម្រោងថវិកាកម្មវិធីឆ្នាំ២០២៤ របស់អគ្គនាយកដ្ឋានទាំង៣ និងមន្ទីររាជធានី ខេត្ត

- រៀបចំកែសម្រួល និងបន្ថែមធាតុចូលថ្មីៗមួយចំនួនលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ) ២០២៤-២០២៨ របស់ក្រសួងអធិការកិច្ច ដើម្បីផ្ញើជូនក្រសួងផែនការ

- រៀបចំធាតុចូលសម្រាប់រៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រកម្ពុជាឆ្នាំ២០២៤-២០៣០ ដើម្បីអនុវត្តកម្មវិធីសកម្មភាពនៃសន្និសីទអន្តរជាតិស្តីពីប្រជាជន និងអភិវឌ្ឍន៍

- ត្រៀមរៀបចំទិន្នន័យស្ថិតិផ្លូវការ ដែលមានការចាត់តាំងតាមវិស័យ របស់ក្រសួងអធិការកិច្ចសម្រាប់ឆ្នាំ២០២៣

- កំពុងរៀបចំពិគ្រោះយោបល់កែសម្រួល និងបញ្ចូលសកម្មភាពថ្មីៗមួយចំនួនទៀត លើគម្រោងចងក្រងស្ថិតិទូទៅរបស់ក្រសួងអធិការកិច្ច

- ត្រៀមរៀបចំគម្រោងផ្សេងៗ ដែលជាប្រតិបត្តិការរបស់ក្រសួងអធិការកិច្ច ឱ្យមានសុក្រិតភាព ស័ក្តិសិទ្ធិភាព និងតម្លាភាព

- ត្រៀមរៀបចំបូកសរុបគម្រោងរបាយការណ៍ស្តីពីលទ្ធផលការអនុវត្តថវិកាកម្មវិធីប្រចាំឆ្នាំ២០២៣ របស់អគ្គនាយកដ្ឋានទាំង៣ និងមន្ទីររាជធានី ខេត្តទាំង២៥ នៃក្រសួងអធិការកិច្ច

- ត្រៀមរៀបចំផែនការតាមដានសមិទ្ធកម្មប្រចាំឆ្នាំ២០២៤ របស់អគ្គនាយកដ្ឋានទាំងបី និងមន្ទីររាជធានី ខេត្តនៃក្រសួងអធិការកិច្ច។

**១.៥.ការងារសហប្រតិបត្តិការអន្តរជាតិ**

- បន្តពង្រឹងការគ្រប់គ្រងដឹកនាំក្នុងនាយកដ្ឋាន ប្រកបដោយសុខដុមនីយកម្មការងារ

- រៀបចំសេចក្តីកំណត់បែងចែកភារកិច្ចជូនប្រធាន អនុប្រធាន និងមន្ត្រីតាមការិយាល័យនីមួយៗ

- កោះអញ្ជើញមន្ត្រីដែលអសកម្មមកសួរនាំ និងលើកទឹកចិត្តឱ្យមកបំពេញការងារ

- លើកកម្ពស់ការសិក្សាស្រាវជ្រាវ ចងក្រងឯកសារ ការទំនាក់ទំនង របៀបរបបបំពេញការងារ ស្វែងរកកិច្ចសហប្រតិបត្តិការជាមួយបណ្តាស្ថានទូត និងអង្គការអន្តរជាតិនានា ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល

- ទំនាក់ទំនងសម្របសម្រួលការចាត់បញ្ជូន និងទទួលគណៈប្រតិភូជាន់ខ្ពស់នីតិកម្ម ទៅបំពេញទស្សនកិច្ចនៅសាធារណរដ្ឋសង្គមនិយមវៀតណាម

- ពិនិត្យសម្របសម្រួលជាមួយអធិការកិច្ចរដ្ឋាភិបាល នៃសាធារណរដ្ឋសង្គមនិយមវៀតណាមស្តីពីការធ្វើបច្ចុប្បន្នភាព (MOU) រវាងក្រសួងអធិការកិច្ច និងអធិការកិច្ចរដ្ឋាភិបាល នៃសាធារណរដ្ឋសង្គមនិយមវៀតណាម និងទំនាក់ទំនងសម្របសម្រួលដំណើរទស្សនកិច្ចផ្លូវការរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់ក្រសួងអធិការកិច្ច ដឹកនាំដោយឯកឧត្តមរដ្ឋមន្ត្រី អញ្ជើញទៅបំពេញទស្សនកិច្ច នៅសាធារណរដ្ឋសង្គមនិយមវៀតណាម ចុងខែមេសា ឆ្នាំ២០២៤

- សម្របសម្រួលការងារជាមួយស្ថានទូតសាធារណរដ្ឋប្រជាមានិតចិន ប្រចាំព្រះរាជាណាចក្រកម្ពុជា និងគណៈកម្មាធិការជាតិចិន លើការរៀបចំសេចក្តីព្រាងMOU និងស្នើសុំទស្សនកិច្ចសម្រាប់គណៈប្រតិភូជាន់ខ្ពស់ក្រសួងអធិការកិច្ច នៅសាធារណរដ្ឋប្រជាមានិតចិនឆ្នាំ២០២៤

- លើកកម្ពស់ការបណ្តុះបណ្តាលធនធានមនុស្សរបស់នាយកដ្ឋាន និងក្រសួង

- ត្រៀមអនុវត្តការងារផ្សេងៗដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន ដោយការទទួលខុសត្រូវខ្ពស់។

**២.ការងារទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា ៤**

២.១.ការងារនីតិកម្ម

- បន្តចូលរួមសិក្សាស្រាវជ្រាវ និងប្រមូលឯកសារទាក់ទងនឹងសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តដែលជាតម្រូវការចាំបាច់របស់ក្រសួង

- ត្រៀមចុះស្ទង់មតិច្បាប់ នៅតាមបណ្តាឃុំ ស្រុក នៃខេត្តគោលដៅ សម្រាប់ឆ្នាំ២០២៤

- បន្តទទួលអនុវត្តសកម្មភាពការងារផ្សេងៗទៀត របស់ថ្នាក់ដឹកនាំក្រសួងប្រគល់ឱ្យ។

២.២.ការងារអប់រំផ្សព្វផ្សាយច្បាប់

- សិក្សាស្រាវជ្រាវទៅលើអនុក្រឹត្យស្តីពីការកែសម្រួល និងឯកសារពាក់ព័ន្ធ និងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ដើម្បីពង្រឹងនូវសមត្ថភាពបន្ថែមរបស់មន្ត្រីក្នុងការិយាល័យ

- សិក្សាស្រាវជ្រាវទៅលើច្បាប់ អនុក្រឹត្យស្តីពីការកែសម្រួល និងឯកសារពាក់ព័ន្ធ ដើម្បីចុះធ្វើការស្ទាបស្ទង់ការយល់ដឹងរបស់ប្រជាពលរដ្ឋ តាមផែនការដែលបានកំណត់

- សិក្សាឯកសារច្បាប់ សិក្សាពីកម្រងសំណួរ

- ចុះផ្សព្វផ្សាយច្បាប់ នៅតាមបណ្តាខេត្តគោលដៅ ស្របតាមផែនការឆ្នាំ២០២៤។

២.៣.ការងារទំនាក់ទំនងជាមួយរាជរដ្ឋាភិបាល និងរដ្ឋសភា-ព្រឹទ្ធសភា

- ចូលរួមប្រជុំអន្តរក្រសួងនៅទីស្តីការគណៈរដ្ឋមន្ត្រី

- ត្រៀមរៀបចំធ្វើវេទិកាសាធារណៈ នៅតាមបណ្តាខេត្តគោលដៅ ស្របតាមផែនការឆ្នាំ២០២៤។

**៣.ការងារអធិការកិច្ច**

**៣.១.ការងារអធិការកិច្ចទី១ លើវិស័យសេដ្ឋកិច្ច**

- បន្តចូលរួមកិច្ចប្រជុំការងារក្នុងក្រសួង និងអន្តរក្រសួងតាមការអញ្ជើញ និងចាត់តាំងរបស់ថ្នាក់ដឹកនាំក្រសួង

- ត្រៀមឆ្លងរបាយការណ៍ជាមួយថ្នាក់ដឹកនាំក្រសួងអធិការកិច្ចស្តីពីលទ្ធផលការចុះធ្វើអធិការកិច្ចលើ (១)ការអនុវត្តតួនាទីភារកិច្ច (២)ការគ្រប់គ្រងការផ្តល់សេវាសាធារណៈ ក្នុងការិយបរិច្ឆេទ២០២២ និងបណ្តាឆ្នាំពាក់ព័ន្ធ នៅរាជធានីភ្នំពេញ ខេត្តបន្ទាយមានជ័យ បាត់ដំបង តាកែវ និងខេត្តស្ទឹងត្រែង

- ត្រៀមឆ្លងរបាយការណ៍ជាមួយរដ្ឋបាលខេត្តរតនគិរី ស្ទឹងត្រែង ឧត្តរមានជ័យ និងខេត្តព្រះសីហនុស្តីពីលទ្ធផលការចុះធ្វើអធិការកិច្ចលើ (១)ការអនុវត្តតួនាទីភារកិច្ច (២)ការគ្រប់គ្រងការផ្តល់សេវាសាធារណៈ (៣)ការអនុវត្តគម្រោងសាងសង់ ជួសជុល ថែទាំហេដ្ឋារចនាសម្ព័ន្ធ ក្នុងការិយបរិច្ឆេទ២០២២ និងបណ្តាឆ្នាំពាក់ព័ន្ធ នៅខេត្តរតនគិរី ស្ទឹងត្រែង ឧត្តរមានជ័យ និងខេត្តព្រះសីហនុ។

- ត្រៀមធ្វើអធិការកិច្ចតាមហានិភ័យ និងធ្វើអធិការកិច្ចឡើងវិញ ក្នុងករណីយល់ឃើញថាមិនទាន់ត្រឹមត្រូវ ឬមានការតវ៉ា

- ត្រៀមអនុវត្តការងារតាមផែនការសកម្មភាពឆ្នាំ២០២៤

- ត្រៀមអនុវត្តភារកិច្ចផ្សេងៗទៀតតាមការចង្អុលបង្ហាញរបស់ថ្នាក់ដឹកនាំក្រសួង។

**៣.២.ការងារអធិការកិច្ចទី២ លើវិស័យរដ្ឋបាលទូទៅ**

- ត្រៀមចេញសេចក្តីជូនដំណឹងទៅរដ្ឋបាលខេត្ត រដ្ឋបាលក្រុង-ស្រុក មន្ទីរ-អង្គភាពជុំវិញខេត្ត រដ្ឋបាលក្រោមឱវាទ និងអង្គភាពពាក់ព័ន្ធ ក្នុងខេត្តកោះកុង ព្រៃវែង និងខេត្តកំពង់ចាម ដើម្បីជំរុញឱ្យធ្វើការកែលម្អលើចំណុចខ្វះខាត លើការចុះធ្វើអធិការកិច្ច (១)ការអនុវត្តតួនាទីភារកិច្ច (២)ការគ្រប់គ្រងការផ្តល់សេវាសាធារណៈ (៣)ការអនុវត្ត

គម្រោងសាងសង់ ជួសជុល ថែទាំហេដ្ឋារចនាសម្ព័ន្ធ ក្នុងការិយបរិច្ឆេទ២០២២

- ត្រៀមឆ្លងរបាយការណ៍ជាមួយរដ្ឋបាលខេត្តកណ្តាល កំពង់ស្ពឺ និងខេត្តត្បូងឃ្មុំស្តីពីលទ្ធផលការចុះធ្វើអធិការកិច្ចលើ (១)ការអនុវត្តតួនាទីភារកិច្ច (២)ការគ្រប់គ្រងការផ្តល់សេវាសាធារណៈ (៣)ការអនុវត្តគម្រោងសាងសង់ ជួសជុល ថែទាំហេដ្ឋារចនាសម្ព័ន្ធ ក្នុងការិយបរិច្ឆេទ២០២២ និងបណ្តាឆ្នាំពាក់ព័ន្ធ

- ត្រៀមចុះធ្វើអធិការកិច្ចលើការអនុវត្តតួនាទីភារកិច្ច និងការដឹកនាំគ្រប់គ្រង នៅមណ្ឌលអប់រំកែប្រែទី១ (ព្រៃសរ) មណ្ឌលអប់រំកែប្រែទី២ (ព្រៃសរ) និងអង្គភាពក្រោមឱវាទ គឺពាក្យបណ្តឹងចុះថ្ងៃទី៣ ខែតុលា ឆ្នាំ២០២៣ របស់ទណ្ឌិត(ម១) មានស្នាមមេដៃចំនួន១៥នាក់ និងពាក្យបណ្តឹងចុះថ្ងៃទី៤ ខែតុលា ឆ្នាំ២០២៣ របស់ជនជាប់ឃុំជាស្ត្រី (ម២) មានស្នាមមេដៃចំនួន១៦នាក់

- ត្រៀមចុះធ្វើអធិការកិច្ចលើការអនុវត្តតួនាទីភារកិច្ច និងការដឹកនាំគ្រប់គ្រង នៅវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម អង្គភាពក្រោមឱវាទ និងអង្គភាពពាក់ព័ន្ធ ក្នុងការិយបរិច្ឆេទ២០២២-២០២៣ គឺពាក្យបណ្តឹងអនាមិក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៣ របស់តំណាងមន្ត្រីរាជការ និងនិស្សិត នៃវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម

- ត្រៀមរៀបចំបណ្តុះបណ្តាលផ្ទៃក្នុងស្តីពីការងារអធិការកិច្ច ជូនដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្នុងនាយកដ្ឋាន (ធ្វើបទបង្ហាញដោយលោកប្រធាននាយកដ្ឋាន និងថ្នាក់ដឹកនាំដែលមានបទពិសោធន៍ លើជំនាញអធិការកិច្ច)

- បន្តទទួល និងបូកសរុបរបាយការណ៍ស្តីពីលទ្ធផលអធិការកិច្ចថ្នាក់ក្រោមជាតិ និងធ្វើអធិការកិច្ចឡើងវិញក្នុងករណីយល់ឃើញថាមិនទាន់ត្រឹមត្រូវ ឬមានការតវ៉ា

- ត្រៀមអនុវត្តការងារតាមផែនការសកម្មភាពឆ្នាំ២០២៤។

### ៣.៣.ការងារអធិការកិច្ចទី៣ លើវិស័យសង្គមកិច្ច

- ត្រៀមឆ្លងរបាយការណ៍ជាមួយរដ្ឋបាលខេត្តកំពង់ធំ កំពង់ឆ្នាំង និងខេត្តមណ្ឌលគិរីស្តីពីលទ្ធផលការចុះធ្វើអធិការកិច្ចលើ (១)ការអនុវត្តតួនាទីភារកិច្ច (២)ការគ្រប់គ្រងការផ្តល់សេវាសាធារណៈ (៣)ការអនុវត្តគម្រោងសាងសង់ ជួសជុល ថែទាំហេដ្ឋារចនាសម្ព័ន្ធ ក្នុងការិយបរិច្ឆេទ២០២២ និងបណ្តាឆ្នាំពាក់ព័ន្ធ

- ត្រៀមមន្ត្រីដើម្បីចូលរួមវិភាគ ដោះស្រាយបញ្ហាអធិការកិច្ច អង្កេតស្រាវជ្រាវ និងបញ្ហាផ្សេងៗទៀត

- ត្រៀមបណ្តុះបណ្តាលជំនាញអធិការកិច្ចរយៈពេលខ្លីតាមការិយាល័យទាំងបី

- ត្រៀមអនុវត្តការងារតាមផែនការសកម្មភាពឆ្នាំ២០២៤

- អនុវត្តភារកិច្ចផ្សេងៗទៀត តាមការចង្អុលបង្ហាញរបស់ថ្នាក់ដឹកនាំក្រសួង។

### ៣.៤.ការងារតាមដានការអនុវត្តច្បាប់

- ត្រៀមឆ្លងរបាយការណ៍ជាមួយរដ្ឋបាលខេត្តកណ្តាល ស្វាយរៀង និងខេត្តព្រះសីហនុស្តីពីលទ្ធផលការចុះតាមដានត្រួតពិនិត្យអនុក្រឹត្យលេខ៦៤ អនក្រ.បក ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកំណត់ និងការគ្រប់គ្រងទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ

- ត្រៀមចុះតាមដានត្រួតពិនិត្យអនុក្រឹត្យលេខ១៤៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច នៅខេត្តព្រះវិហារ ក្រចេះ និងខេត្តស្ទឹងត្រែង

- បន្តស្រាវជ្រាវ និងចងក្រងច្បាប់ គោលនយោបាយ យុទ្ធសាស្ត្រ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងអនុសាសន៍របស់នាយករដ្ឋមន្ត្រី

-ពង្រឹងការងារបន្ថែមជាមួយមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចរាជធានី-ខេត្តទាំង២៥

លើវិស័យតាមដានការអនុវត្តច្បាប់

-សិក្សាប្រភពព័ត៌មានពីគ្រប់មជ្ឈដ្ឋានដែលពាក់ព័ន្ធនឹងការរំលោភច្បាប់

- ត្រៀមចុះតាមដានការអនុវត្តអនុសាសន៍របស់នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

- អនុវត្តការងារតាមផែនការសកម្មភាពឆ្នាំ២០២៤

- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការចង្អុលបង្ហាញរបស់ថ្នាក់ដឹកនាំក្រសួង។

៣.៥.ការងារទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវ

- បន្តរង់ចាំទទួលពាក្យបណ្តឹងពីគ្រប់មជ្ឈដ្ឋាននានា រួមទាំងពាក្យបណ្តឹងក្នុងសារព័ត៌មានផងដែរ

- បន្ត និងត្រៀមចុះអង្កេតស្រាវជ្រាវពាក្យបណ្តឹងដែលជាសមត្ថកិច្ចក្រសួង និងពាក្យបណ្តឹងដែលរាជរដ្ឋាភិបាលប្រគល់ជូន

- អនុវត្តការងារតាមផែនការសកម្មភាពឆ្នាំ២០២៤

- អនុវត្តការកិច្ចផ្សេងៗទៀតតាមការចង្អុលបង្ហាញរបស់ថ្នាក់ដឹកនាំក្រសួង។

## ៤.ការងារសវនកម្មផ្ទៃក្នុង

- ត្រៀមលក្ខណៈដើម្បីពន្លឿនការត្រួតពិនិត្យ និងធ្វើសវនកម្មទៅលើអង្គភាពមួយចំនួន ដែលមិនទាន់បានចុះត្រួតពិនិត្យ និងរៀបចំរបាយការណ៍ដាក់ជូនថ្នាក់ដឹកនាំបានជ្រាប

-ត្រៀមលក្ខណៈចូលរួមវគ្គបណ្តុះបណ្តាលកម្មវិធីឌីជីថលដែលបានរៀបចំដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

## ៥.ការងារវិទ្យាស្ថានជាតិអធិការកិច្ច

- បន្តពង្រឹងការគ្រប់គ្រងការងាររដ្ឋបាល និងអនុវត្តការងារតាមតួនាទីភារកិច្ចរបស់វិទ្យាស្ថាន

- បន្តបើកវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈអធិការកិច្ចតាមផែនការដែលរដ្ឋមន្ត្រីបានអនុម័ត

- បន្តស្រាវជ្រាវលិខិតបទដ្ឋានគតិយុត្តនានា

- បន្តស្រាវជ្រាវ និងរៀបចំសៀវភៅកម្រងអនុសាសន៍ សម្តេចធិបតី សម្រាប់វុលបន្ទាប់

- បន្តស្រាវជ្រាវ និងរៀបចំសៀវភៅព្រឹត្តិបត្រអធិការកិច្ច សម្រាប់វុលបន្ទាប់

-បន្តស្រាវជ្រាវ និងត្រៀមទំនាក់ទំនងជាមួយគ្រឹះស្ថានសិក្សា និងដៃគូអភិវឌ្ឍន៍ ដើម្បីស្វែងរកការគាំទ្រ និងកិច្ចសហការ

- អនុវត្តការងារតាមផែនការសកម្មភាពឆ្នាំ២០២៤ របស់វិទ្យាស្ថាន

- អនុវត្តការងារផ្សេងៗតាមការណែនាំ និងចង្អុលបង្ហាញពីថ្នាក់ដឹកនាំ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ** មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ៕

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំរោង ឆស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ[illegible] ឆ្នាំ២០២៤

ក្រសួងអធិការកិច្ច

**ចម្លងជូន**

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី

-ក្រសួងផែនការ

-ឯកសារ កាលប្បវត្តិ